OLD VERSION

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 08-Dec-2015, 13:18
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥**

**ម៉ោង ០៩:០៤នាទី**

**សវនាការលើកទី៣៤២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms. Maddalena Ghezzi)*

កញ្ញា ជា ស៊ីវហ៊ាង

កញ្ញា អេវេលីន ខាំផូស សង់ចេស
*(Ms. Evelyn CAMPOS SANCHEZ)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ដេល លីសាក់ *(Mr. Dale LYSAK)*

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ស្រ៊ា រតនៈ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ(*Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វលក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោកស្រី ទី ស្រ៊ីនណា

លោក ឡោ ជុនធី

លោក សំ សុគង់

លោក វ៉ែន ពៅ

កញ្ញា លីម៉ា ង្វៀន *(Ms.Lyma NGUYEN)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
| --- | --- |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | អង់គ្លេស |
| កញ្ញា លីម៉ា ង្វៀន | អង់គ្លេស |
| លោក 2-TCW-918 | ខ្មែរ |
| លោក ប្រាក់ ឌឿន (2-TCCP-300) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក** 2-TCW-918

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី........................................ ទំព័រ ២
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី........................................ ទំព័រ ១៦

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ប្រាក់ ខឿន** (2-TCCP-300)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................ ទំព័រ ២៨
សួរដោយកញ្ញា លីម៉ា ង្វៀន ផ្តើមពី ........................................ ទំព័រ ៣១
សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្តើមពី........................................ ទំព័រ ៧១

# កិច្ចដំណើរការនីតិវិធី

[០៩:០៤:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-918 បញ្ចប់ ហើយនិងមានដើមបណ្តឹងរដ្ឋប្បវេណីបម្រុងមួយរូបគឺ 2-TCCP-300។

ក្រឡាបញ្ជីសវនាការកញ្ញា ជា ស៊ីវហ៊ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន លើកលែងតែមេធាវីប្រចាំការសម្រាប់លោក ខៀវ សំផន គឺលោក ខលវីន សោនដឺស៍ នឹងមកយឺតបន្តិចនៅព្រឹកនេះ។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះគឺមានរហស្សនាម 2-TCW-918។ លោកនិងមេធាវីប្រឹក្សា លោក ម៉ម រិទ្ធា មានវត្តមានរួចហើយ នៅបន្ទប់សវនាការនេះ។ នៅថ្ងៃនេះដែលមានដើមបណ្តឹងរដ្ឋប្បវេណីបម្រុងមួយរូបដែលមានរហស្សនាម 2-TCCP-300។ សូមអរគុណលោកប្រធាន។

[០៩:០៥:៥៨]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ កញ្ញា ជា ស៊ីវហ៊ង។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ នៅក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមាន

លទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថាមានអាការៈឈឺចង្កេះខ្លាំង មិនអាចអង្គុយយូរបាន និងបានផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះ អនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។ ហើយជាបន្តទៅទៀត អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

[០៩:០៧:៤២]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួលោក លោកស្រីចៅក្រម។ សូមជម្រាបសួលោកមេធាវី ព្រមទាំងភាគីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី! ខ្ញុំមានសំណួរបន្ថែមខ្លះទៀតនៅព្រឹកនេះ ដើម្បីសាកសួរលោក។ កាលពីម្សិលមិញ យើងបានបញ្ចប់នៅពេលរសៀលហ្នឹង ដោយសំណួរមួយដ៏ស្មុគស្មាញ ដែលទាក់ទងទៅនឹងអ្វីដែលលោកឆ្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំមិនប្រាកដថាតើលោកចាំឬក៏អត់នូវអ្វីដែលខ្ញុំអានម្សិលមិញ គឺទាក់ទងទៅនឹងពួកក្បត់ គឺ សោ ភឹម, រស់ ញឹម ហើយនិង ហេង សំរិន ដែលបានចូលជាមួយនឹងវៀតណាម។ ឥឡូវនេះខ្ញុំសូមដកស្រង់ឡើងវិញដើម្បីរំឭកការចង់ចាំរបស់លោក

ហើយបន្ទាប់មកទៀតខ្ញុំនឹងសួរអំពីការប្រជុំ ដែលនៅក្នុងការប្រជុំនេះ គឺគេបាននិយាយអំពីបញ្ហាទាំងអស់នេះ។ ខ្ញុំសូមដកស្រង់៖ ខ្ញុំនឹង -- គឺលោកនិយាយអំពីវៀតណាមចូលមក ព្រោះយើងមានប្រវត្តិជាមួយវៀតណាម។ គឺនិយាយអំពីមេតែ -- គឺនិយាយអំពីជនក្បត់ប្រទេសដូចជា សោ ភឹម, មូល សម្បត្តិ, ហេង សំរិន ហើយនិងអ្នកដទៃទៀតដែលបានចូលរួមជាមួយវៀតណាម។ សោ ភឹម ត្រូវបានចាប់ខ្លួន ហើយ ហេង សំរិន អាចរត់គេចខ្លួនបាន។ គាត់រត់ជាមួយនឹងទាហាន ១.៥០០នាក់ នៅពេលដែលគាត់រត់គេចអស់ប្រាំពីរថ្ងៃ វៀតណាមវាយចូលស្វាយរៀង។ យើងដឹងថាយើងនឹងចាញ់សង្គ្រាមនេះ។ គឺដោយសារយើងនឹងចាញ់សង្គ្រាម យើងចាប់ផ្ដើមរៀបចំនៅក្នុងសហករណ៍នៅស្រុក ហើយនិងការដ្ឋានដទៃទៀត។ យើងជីកដីកប់អំបិល កប់អង្ករនៅសហករណ៍ទាំងអស់។ សូមបញ្ចប់ការដកស្រង់។ ដូច្នេះ ខ្ញុំចង់សួរលោកថាតើលោកចាំទេថាលោកបានឆ្លើយចម្លើយទាំងអស់នេះប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា។ តើលោកចាំទេថាលោកបានធ្លាប់ផ្ដល់ចម្លើយបែបនេះទៅខាង ឌី.ស៊ី.ខេម?

**លោក 2-TCW-918៖**

**ឆ៖** បាទ សូមគោរពលោកប្រធានជាទីគោរព។ ខ្ញុំនឹងបញ្ជាក់បន្ថែមអំពីសំណួរដែលត្រូវឆ្លើយនោះ គឺរឿងរ៉ាវទាំងអស់នេះគឺបាននិយាយក្រៅ – និយាយក្រៅពីសំណួរសួរខ្ញុំពីរឿងអាងត្រពាំងថ្ម ដល់ចប់បញ្ហាអាងត្រពាំងថ្មទៅជារឿងពិភាក្សាលេងក្រៅ ហើយដំណើរការដែលខ្ញុំបានដឹងនិយាយនេះគឺថានៅក្នុងឆ្នាំ៨២ ផែនការ៨២ បានខ្ញុំដឹង បាទមិនមែនដឹងនៅក្នុងឆ្នាំ៧៧, ៧៨ អីទេ។ ម្ល៉ោះហើយបានន័យថា ខ្ញុំឮពីប្រកាសប្រាប់ និយាយប្រាប់នៅព្រំដែននោះ ខ្ញុំក៏ចាំតាមគេទៅ។ អានេះជាការពិភាក្សាលេង តែអ្នកកត់ត្រាកត់បញ្ចូលនៅក្នុងបញ្ហាអាងត្រពាំងថ្មនេះ ខ្ញុំក៏មិនដឹងឆ្លើយយ៉ាងម៉េចដែរមានតែប៉ុណ្ណោះឯង។

[០៩:១២:០៧]

**ស៖** លោកសាក្សី ខ្ញុំមិនប្រាកដថាអ្វីដែលលោកនិយាយត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវនោះទេ ព្រោះនៅក្នុងទំព័រដដែលនេះ គឺឯកសារអង់គ្លេសមានលេខ 00728699, ខ្មែរមានលេខ 00734112 និងបារាំងមានលេខ 01123659។ គឺលោកនិយាយអំពីការប្រជុំមួយដែលនៅពេលប្រជុំហ្នឹងគេនិយាយអំពីបញ្ហានេះ។ អ្វីដែលលោកបាននិយាយអំពីការប្រជុំនេះ គឺលោកនិយាយដូចតទៅនេះ៖ គេសួរលោក គឺខាងមជ្ឈមណ្ឌលឯកសារកម្ពុជាគេបានសួរលោកអំពី អ៊ុំ ចែម ហើយអ្នកស៊ើបអង្កេតសួរថា៖ “លោកមិនដែលធ្លាប់ជួប ឬធ្វើការជាមួយគាត់ទេ? លោកឆ្លើយថា៖ ទេ។ តើលោកដឹងថាគាត់ជាមេស្រុកទេ? លោកឆ្លើយថា៖ បាទ ដឹង នៅពេលដែលវៀតណាមចូលគាត់កោះហៅឲ្យមានការប្រជុំ។ តើអ្នកណាអ្នក

កោះហៅ? តារិន ដែលជាមេតំបន់ ហើយនិងយាយថែម។ ពួកគេកោះហៅឱ្យមានការប្រជុំ។ សំណួរ៖ មុនពេលដែលវៀតណាមចូលស្រុកឬ? លោកឆ្លើយថា៖ មុនពេលដែលវៀតណាមចូលស្រុក។ សំណួរ៖ តើការប្រជុំហ្នឹងគេប្រជុំនៅណាដែរ? គឺប្រជុំនៅស្រី *(តាមការបកប្រែ)* -- ប្រជុំនៅស្វាយឬ? ស្វាយ បាទ នៅពេលនុ៎ង តារិន ជាប្រធានការ -- ជាគណៈអធិបតី។” កាលពីម្សិលមិញ ព្រះរាជអាជ្ញាសួរលោកអំពីសំណួរមួយទាក់ទង តារិន – គឺ តារិន ដែលលោកធ្លាប់ស្គាល់នុ៎ង ហើយព្រះរាជអាជ្ញាក៏បាននិយាយអំពីបញ្ជីឯកសារស-២១ ដែលឯកសារនោះបានបញ្ជាក់ថា តារិន ត្រូវបានគេឃុំខ្លួន ហើយក្រោយមកទៀតត្រូវបានសម្លាប់នៅក្នុងខែវិច្ឆិកា ឆ្នាំ៧៨។ ប្រសិនបើ តារិន ជាគណៈអធិបតីនៃកិច្ចប្រជុំនោះ ហើយយាយថែម បានចូលរួមនៅក្នុងពេលនោះ ហើយលោកនិយាយអំពីការដែលវៀតណាមចូលស្រុក ខ្ញុំចង់បញ្ជាក់ប្រាប់លោកថាការប្រជុំដែលលោកបានស្តាប់ឮអំពីការក្បត់ហ្នឹង គឺប្រហែលជាចុងឆ្នាំ៧៨ អ៎! ចុងឆ្នាំ៧៧ ឬក៏ដើម៧៨ មិនមែនឆ្នាំ៨២ដូចដែលលោកនិយាយនោះទេ។ តើត្រឹមត្រូវទេ?

**ធ៖** រឿងរ៉ាវដែលខ្ញុំបានដឹងនេះ គឺខ្ញុំដឹងនៅឆ្នាំ៨២ទេ។

**ស៖** ឥឡូវនេះ ខ្ញុំសួរលោកអ៊ីចេះវិញ។ តើលោកធ្លាប់ចូលរួមការប្រជុំនៅស្វាយ គឺនៅពេលដែលវៀតណាមវាយចូលស្វាយរៀង ហើយការប្រជុំហ្នឹងដឹកនាំដោយ តារិន ទេ? តើលោកធ្លាប់ចាំថាបានចូលរួមការប្រជុំបែបនេះទេ?

**ធ៖** ការចូលប្រជុំនៅស្វាយ គឺខ្ញុំមិនបានចូលប្រជុំទេ ប៉ុន្តែក្នុងអង្គភាពចល័តបានទៅប្រជុំចំពោះមេដឹកនាំ ដូចប្រធានវរៈ ប្រធានកងអីដែលគេក្តាប់កម្លាំង។ ឯចំណែកខ្ញុំ គឺនៅខាងនេសាទឆ្ងាយ គឺមិនបានទៅប្រជុំទេ ប៉ុន្តែពួកគេទេដែលទៅប្រជុំ បាទ។ តែរូបខ្ញុំផ្ទាល់ គឺមិនបានទៅទេ ទាល់តែគេមកវិញ បានគេនិយាយប្រាប់។

[០៩:១៦:៥៦]

**ស៖** លោកសាក្សី ខ្ញុំសូមអាននូវសម្រង់មួយនៃចម្លើយរបស់លោកទៀត គឺការដែលលោកឆ្លើយអំពីការប្រជុំនោះ លោកឆ្លើយថា៖ “បាទ គ្រប់ស្រុកទាំងអស់មកប្រជុំ ហើយការប្រជុំគេមានផែនការ។ គេមិនជឿយើងទេ ចំពោះផែនការ យើងដឹងថាវៀតណាមវាយចូលដល់ស្វាយរៀងហើយ គេបញ្ជាក់ប្រាប់យើង។ ហើយបន្ទាប់មកទៀត លោកឆ្លើយថា “ខ្ញុំបាននិយាយអំពីអ្វីដែលគេប្រាប់ខ្ញុំ”។ និយាយអ៊ីចឹងមានន័យថា លោកបានចូលរួមនៅក្នុងការប្រជុំដែលដឹកនាំដោយ តារិន ហើយនិង អ៊ុំ ថែម? តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំមិនបានទៅរួមប្រជុំជាមួយ យាយថែម ទេ ប៉ុន្តែកាលប្រជុំនោះ គឺគេប្រជុំរួចហើយ ខាងយាយថែម ខាងតារិនអី ខាងស្រុក ខាងឃុំអី គេប្រជុំរួចហើយ ហើយខ្ញុំដឹងក្រោយ ដោយសារប្រធានខ្ញុំប្រាប់ថា គេឲ្យតាមសហករណ៍ជីកស្រះ អ៎! ជីកកន្លែងសម្រាប់ទុកអង្ករ អំបិល ព្រោះយើងចាញ់យៀកណាម យើងរត់ទៅចូលព្រៃ យប់ឡើងយើងមកយកស្បៀងយកទៅហូប។ អានោះគឺពិតប្រាកដមែន ព្រោះប្រធានខ្ញុំគាត់បាននិយាយប្រាប់ តែឲ្យខ្ញុំបានទៅប្រជុំជាមួយ យាយថែម ខ្ញុំមិនបានទៅទេ ព្រោះខ្ញុំមិនទាន់ស្គាល់ឈ្មោះ មិនទាន់ស្គាល់រូប យាយថែម ទេ ខ្ញុំឮតែឈ្មោះ តែ យាយថែម គណៈស្រុកៗ មិនទាន់បានដែលឃើញរូបគាត់ទេ។

[០៩:១៩:១០]

**ស៖** លោកសាក្សី លោកអាចពន្យល់បានទេ ហេតុអ្វីអ្នកស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានកត់ត្រាទៅ -- កត់ត្រាអ្វីដែលលោកបាននិយាយ ប្រសិនបើលោកមិនបានចូលរួមទេ ហេតុអីក៏គេមានចម្លើយ ឬក៏គេមានកំណត់ត្រាបែបនេះ?

**ឆ៖** ការកត់ត្រានេះ បែបជាច្រឡំថាខ្ញុំទៅប្រជុំ ព្រោះខ្ញុំមិនបានប្រជុំទេ។ កាលដែលគេប្រជុំនេះគឺខ្ញុំដឹងក្រោយ។ ដែលខ្ញុំមិនបានទៅប្រជុំ ប្រធានខ្ញុំគាត់និយាយប្រាប់ខ្ញុំ បាទ និយាយទៅសរុបថា ប្រធានខ្ញុំដែលគាត់ប្រាប់ខ្ញុំនោះ ព្រោះខ្ញុំនៅឆ្ងាយ នៅទន្លេសាបមិនងាយបានឡើងមកប្រជុំគេទេ ពេលដែលខ្ញុំឡើងទៅ គាត់និយាយប្រាប់តាមក្រោយ បាទ ហើយអ្នកមណ្ឌលឯកសារនេះកត់សរុបយ៉ាងណា គឺខ្ញុំអត់ដឹងទេ។

**ស៖** ឥឡូវនេះយើងទុករឿងនេះមួយឡែកសិន។ ថាតើលោកបានឆ្លើយជាមួយខាងមជ្ឈមណ្ឌលឯកសារកម្ពុជាអំពីការក្បត់ គឺការក្បត់ប្រទេសរបស់ សោ ភឹម, មូល សម្បត្តិ, ហើយនិង ហេង សំរិន នុ៎ង? តើលោកមានន័យយ៉ាងម៉េចដែរ នៅពេលដែលលោកនិយាយថា ពួកគេក្បត់ប្រទេសហ្នឹង?

**ឆ៖** ត្រង់មានន័យថាក្បត់អីហ្នឹង គឺខ្ញុំមិនដឹងថាគេក្បត់តាមវិធីណាទេ ប៉ុន្តែកាលណោះ គឺខ្ញុំបានរត់ចេញទៅនៅឯជំរំ ហៅថាព្រៃមាន់ ភ្នំឆ័ត្រ ហើយពេលនោះឮគេនិយាយពេលនោះឯង ថាពួកភូមិភាគបូព៌ាក្បត់ ថាៗ ហេង សំរិន, សោ ភឹម ម្ល៉ោះហើយគឺខ្ញុំបានយកពាក្យនេះមកនិយាយដែលមណ្ឌលឯកសារចុះទៅផ្ទះខ្ញុំ។ ចប់ការងារខ្ញុំហើយ។ អានេះគឺនិយាយដូចថាសំណេះសំណាលគ្នាជាសាមញ្ញទេ ដល់គាត់មកកត់បញ្ចូលអ៊ីចេះ ខ្ញុំមិនដឹងឆ្លើយថាយ៉ាងម៉េចទេ។ ថាការពិតគឺខ្ញុំដឹងនៅ -- កាលដែលនៅជំរំទេពាក្យទាំងអស់នេះ។

E1/361.1/Old-3

[០៩:២២:០៤]

**ស៖** តើលោកចាំទេថា សោ ភឹម ហើយនិង រស់ ញឹម ដែលគេហៅថា មូល សម្បត្តិ ហ្នឹង តើពួកគាត់មានទំនាក់ទំនងអ្វីជាមួយគ្នាដែរ?

**ឆ៖** ខ្ញុំមិនដឹងថាគាត់ទំនាក់ទំនងអីជាមួយគ្នា ខ្ញុំអត់ដឹង។

**ស៖** តើលោកដឹងថាតើកូនៗរបស់ពួកគាត់ហ្នឹងមានទំនាក់ទំនងផ្ទាល់ខ្លួនអីដែរឬទេ?

**ឆ៖** បើថារឿងកូនគាត់ ខ្ញុំមានឮគេនិយាយប្រាប់ដែរ អានេះគឺខ្ញុំមិនបានឃើញ គឺខ្ញុំមិនបានឃើញពិតជាក់ស្ដែងទេ ប៉ុន្តែគេនិយាយថា តាសោម ភឹម គាត់មានកូនក្រមុំមួយ។ តាមូល សម្បត្តិ គាត់មានកូនកំលោះមួយ។ ម៉្លោះហើយគាត់ចង់ផ្សំផ្គុំ ចងស្ពានមានមេត្រីជាមួយគ្នាគាត់ ការទំនាក់ទំនងរាប់អាននេះ។ ហើយខ្ញុំឮគេថាអ៊ីចឹង ខ្ញុំថាតាមគេទៅ ព្រោះខ្ញុំមិនបានឃើញទេ ខ្ញុំមិនដែលឃើញមុខគេទេ។

**ស៖** តើលោកដឹងទេថាតើនៅក្នុងឆ្នាំណា ឆ្នាំ៧៥, ៧៦ ឬក៏៧៧ ដែលខាងបូព៌ា ហើយនិងពាយ័ព្យហ្នឹងមានទំនាន់ទំនងពិសេសជាមួយគ្នា? តើនៅក្នុងឆ្នាំណាដែរ?

[០៩:២៣:៥៤]

**ឆ៖** ខ្ញុំចាំមិនបានទេ មិនដឹងឆ្នាំណា។ មិនដឹងថា ៧៧ ឬក៏៧៨ ឬក៏អី ខ្ញុំថាមិនត្រូវ ព្រោះការដែលឮចចាមអារ៉ាមថាតាមគេ អត់បានកំណត់ឆ្នាំដឹង ខ្ញុំភ្លេចដែរ។

**ស៖** តើលោកឮអាពាក្យចចាមអារ៉ាមគេនិយាយហ្នឹងថាម៉េចខ្លះ?

**ឆ៖** ថាអ្នកទាំងពីរនេះចង់ចងដន្លងគ្នានេះឯង។ តាមូល សម្បត្តិ ហើយនិង តាសោ ភឹម នេះគាត់ចងដន្លងគ្នា។ ដឹងតែប៉ុណ្ណោះឯង។

**ស៖** ខ្ញុំសូមបន្តទៅមុខទៀតទាក់ទងទៅនឹង ថាតើលោកដឹងថាភូមិភាគទាំងពីរហ្នឹងមានទំនាក់ទំនងពិសេសអីដែរទេ ខ្ញុំមិនសួរអំពីមនុស្សទេ ខ្ញុំសួរអំពីភូមិភាគ គឺភូមិភាគបូព៌ា ហើយនិងភូមិភាគពាយ័ព្យហ្នឹង តើភូមិភាគទាំងពីហ្នឹងមានទំនាក់ទំនងអ្វីពិសេសដែរឬទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ ត្រង់ការទំនាក់ទំនងពិសេស ព្រោះខ្ញុំមិនបានតាមដាន ហើយក៏ខ្ញុំមិនបានដឹងក្នុងឆាកនយោបាយ គឺខ្ញុំអត់ដឹងទេ ខ្ញុំដឹងតែដឹកនាំកម្លាំងរកត្រីដើម្បីដោះស្រាយអង្គភាព។

**ស៖** ខ្ញុំអាននូវសម្រង់មួយគឺជាចម្លើយរបស់មនុស្សម្នាក់។ គាត់មិនមានតួនាទីខ្ពស់ដូចលោកទេ តែគាត់មានតួនាទីមួយដែរនៅទំនប់ត្រពាំងថ្ម។ ខ្ញុំនិយាយទៅលើឯកសារ E3/9060 គឺជាចម្លើយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានមកផ្ដល់សក្ខីកម្មនៅទីនេះផងដែរ។ ខ្ញុំនិយាយយោងទៅលើទំព័រ

00733054, បារាំងមានលេខ 01123699 និងអង់គ្លេសមានលេខ 00728747។ ហើយបុគ្គលម្នាក់នេះបានមកផ្តល់សក្ខីកម្មនៅទីនេះផងដែរ ហើយគាត់ក៏បានផ្តល់ចម្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជាផងដែរ ខ្ញុំសូមដកស្រង់៖ “ មិត្តភាពរវាងភូមិភាគទាំងពីរ គឺខាងបូព៌ា ហើយនិងពាយ័ព្យ។ គឺមិត្តភាពហ្នឹងគឺចង់កម្ទេចខាងនិរតីឲ្យខ្ទេចដើម្បីកម្ទេចបដិវត្តន៍។” តើលោកយល់យ៉ាងម៉េចដែរចំពោះចម្លើយមួយនេះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ការជំទាស់របស់ខ្ញុំគឺថា មេធាវីកំណត់ដោយមិនត្រឹមត្រូវ អំពីចម្លើយហ្នឹង គឺគាត់និយាយអំពីកម្មាភិបាលជាន់ខ្ពស់ បុគ្គលម្នាក់នេះ គាត់ធ្វើជាឆ្មាំការដ្ឋានតែប៉ុណ្ណោះ ដូច្នេះ តាមសក្ខីកម្មរបស់គាត់ គឺមិនមានមូលដ្ឋានអ្វីទាក់ទងទៅនឹងការងាររបស់របប។ ខ្ញុំមិនជំទាស់ទៅនឹងការដាក់នោះទេ ប៉ុន្តែខ្ញុំជំទាស់ចំពោះការដែលនិយាយថាសាក្សីមានឋានៈខ្ពស់ ហើយមានព័ត៌មានលម្អិតអ្វីទាក់ទងទៅនឹងភូមិភាគនោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងបញ្ជាក់ឲ្យច្បាស់អំពីបុគ្គលនេះ ខ្ញុំមិនមានបញ្ហាទេ លោកប្រធាន។

[០៩:២៨:៣៧]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សម្រង់ដែលខ្ញុំបានដកស្រង់ប្រាប់លោក គឺជាចម្លើយមជ្ឈមណ្ឌលឯកសារកម្ពុជារបស់មនុស្សម្នាក់ដែលធ្លាប់ធ្វើការនៅត្រពាំងថ្មដែរ ហើយគាត់បាននិយាយថា មិត្តភាពរវាងបូព៌ានិងពាយ័ព្យគឺមានបំណងដើម្បីកម្ទេចខាងនិរតីឲ្យខ្ទេចតែម្តងដើម្បីបង្កើតនូវបដិវត្តន៍ថ្មី។ តើលោកយល់យ៉ាងម៉េចដែរចំពោះមតិឬក៏ការឆ្លើយបែបនេះ?

**លោក 2-TCW-918៖**

**ឆ៖** ខ្ញុំមិនបានជាគិតយល់យ៉ាងម៉េចដែរ ព្រោះហួសការស្មានអំពីការងារដែលខ្ញុំធ្វើ គឺខ្ញុំអត់បានជាគិតទេ មិនដឹងសម្រេចថាយ៉ាងម៉េច ដល់ហើយសំណួរនេះគឺខ្ញុំមិនអាចឆ្លើយបានព្រោះខ្ញុំអត់ដឹង។

**ស៖** ខ្ញុំព្យាយាមបញ្ជាក់បន្តិច ថាតើលោកដឹងបុគ្គល ឬក៏លោកស្គាល់បុគ្គលនេះឬក៏អត់?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានខ្ញុំសូមអនុញ្ញាតបង្ហាញនូវរូបថតបុគ្គលម្នាក់នេះ គឺសាក្សីម្នាក់នេះ ហើយរូបថតហ្នឹងមាននៅក្នុង អ៊ីធីហ្វេសផង គឺ E3/9443 អង់គ្លេសមានលេខ 00729899 ជារូបថតទៅ -- គឺជារូបថតលេខ42 របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

ខ្ញុំមិនជំទាស់ចំពោះរូបថតនោះទេ ហើយខ្ញុំក៏ពេញចិត្តផងដែរ ប៉ុន្តែជាការល្អណាស់ដែលគាត់មិនបង្ហាញឈ្មោះបុគ្គលនេះជាសាធារណៈ។ ដូច្នេះ ខ្ញុំមិនយល់ថា ហេតុអ្វីបានជាមិនកត់ត្រា?

[០៩:៣០:៥៤]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំពេញចិត្តប្រសិនបើអនុញ្ញាតឲ្យខ្ញុំនិយាយឈ្មោះបុគ្គលម្នាក់នេះ គាត់ឈ្មោះ ឡូត ស៊ុយ ហើយនេះជារូបថតរបស់គាត់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំអានឈ្មោះ មិនត្រឹមត្រូវទេ។ សូមទោស គឺ ឡូត ស៊ុយ។

**លោក 2-TCW-918៖**

**ឆ៖** ខ្ញុំមិនដែលស្គាល់។

**ស៖** មិនអីទេលោកសាក្សី។ ខ្ញុំគិតថា ខ្ញុំអាចទាយស្មានចម្លើយរបស់លោកចំពោះសំណួរបន្ទាប់របស់ខ្ញុំ ប៉ុន្តែខ្ញុំនឹងសួរលោកអំពី គឺឯកសារ E3/9579 គឺកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់កម្មាភិបាលខាងពាយ័ព្យមកពីផ្នែកដឹកជញ្ជូន។ ខ្មែរ -- ឯកសារខ្មែរមានលេខ 00947282, បារាំងមានលេខ 00974761 និងអង់គ្លេសមានលេខ 00970467។ គឺសាក្សីម្នាក់នេះ គឺនៅសំណួរ13 ហើយសំណួរចម្លើយដូចតទៅនេះ៖ "សំណួរ៖ តើលោកដឹងទេហេតុអ្វីបានជាខាងនិរតីមកជំនួសខាងពាយ័ព្យ? ឆ្លើយ៖ ពួកគេត្រូវបានចោទប្រកាន់ថា ជាប់ពាក់ព័ន្ធជាមួយនឹងវៀតមិញ ខ្មែរក្រហម ហើយខាងបូព៌ា គឺមេ សោ

ភឹម ពួកគេទាំងពីរភូមិភាគហ្នឹងបានប្រឆាំងនឹង ប៉ុល ពត។ តាមការសង្កេតរបស់ខ្ញុំ ខ្មែរក្រហមគឺរួមមាននៅបីបួនក្រុម។ ក្រុមទី១ គឺវៀតមិញ ក្រុមទី២ គឺខ្មែរក្រហមជាតិនិយម ក្រុមទី៣ គឺខ្មែរក្រហមសីហនុ និងក្រុមទី៤ គឺខ្មែរក្រហមមកពីចិនរួមទាំង ប៉ុល ពត ផងដែរ។" សូមបញ្ចប់ការដកស្រង់។ លោកសាក្សី តើលោកយល់យ៉ាងម៉េចដែរចំពោះចម្លើយរបស់កម្មាភិបាលភូមិភាគពាយ័ព្យនេះ?

[០៩:៣៤:១៨]

**ឆ៖** ខ្ញុំមិនដឹងថា យល់យ៉ាងម៉េច ព្រោះក្នុងឆាកនយោបាយខ្ញុំអត់ដែលបានប្រឡូក។ មិនដឹងអាចសន្និដ្ឋានថាម៉េច ខ្ញុំអត់ចេះឆ្លើយបាន។

**ស៖** ទោះជាយ៉ាងណាក៏ដោយខ្ញុំសូមអានសម្រង់មួយទៀតដើម្បីសួរអំពីប្រតិកម្មរបស់គាត់។ នេះគឺជាកំណត់ហេតុស្ដាប់ចម្លើយសាក្សីពីប្រធានភូមិភាគខាងផ្នែកទទួលផ្នែកព័ស្ដុភារនិងសេដ្ឋកិច្ចពីភូមិភាគពាយ័ព្យ គឺឯកសារ E3/9580, ERN ជាភាសាខ្មែរ 00951906, បារាំង 01004437, អង់គ្លេស 00978422។ លោកសាក្សី គឺថាសាក្សីរូប -- បុគ្គលរូបនេះបាននិយាយឈ្មោះ តាហាំ។ ឈ្មោះខាងក្រៅ ឈ្មោះ ទុន តុល –តាហាន– គឺជាកូនចិញ្ចឹមរបស់ រស់ ញឹម ហើយគឺជាអនុសេនាធិការភូមិភាគនេះបើតាមសម្ដីរបស់សាក្សីរូបនេះ។ ហើយក្រោយមក អ្នកស៊ើបអង្កេតបានសួរដូចតទៅ ខ្ញុំសូមដកស្រង់ចម្លើយរបស់គាត់ទាំងស្រុងតែម្ដង៖ "សួរ៖ តើលោកមានដឹងថាមានអ្វីកើតឡើងចំពោះ តាហាំ។ ចម្លើយ ២៩៖ តាហាំ ក៏បានចាប់ខ្លួនដែរ ពួកគាត់ត្រូវបានចាប់ខ្លួនទាំងអស់គ្នា។ ខ្ញុំបានទទួលព័ត៌មានថា កងពលទាំងពីររបស់ភូមិភាគពាយ័ព្យមានផែនការ គឺថាប្រយុទ្ធតដៃជាមួយ ប៉ុល ពត។ ផែនការនេះ ក៏បែកការណ៍ទៅដល់ភ្នាក់ងាររបស់មជ្ឈិម។ ហេតុអ៊ីចឹងបានជាបុគ្គលិកកងទ័ព គឺថាសមាជិកកងទ័ពមួយចំនួនត្រូវបានចាប់ខ្លួន ហើយខាងក្រោយមកទៀត គឺថាកងទ័ពនេះបានស្ដាប់ឮមេ -- កងទ័ពនោះគឺថាបាននិយាយគ្នា។ ហើយពួកខាងផ្នែកភូមិភាគនិរតីនោះក៏ចូលមក ហើយមានការបះបោរ។"

លោកសាក្សី បុគ្គលិករូបនេះ មានតួនាទីខ្ពស់នៅក្នុងភូមិភាគពាយ័ព្យ សព្វថ្ងៃនៅរស់រាននៅឡើយ ហើយគាត់បានផ្ដល់សក្ខីកម្មអំពីផែនការរបស់ភូមិភាគពាយ័ព្យ និងផែនការរបស់ភូមិភាគបូព៌ា ដើម្បីធ្វើការបះបោរប្រឆាំងជាមួយនឹងពួកប៉ុល ពត។ លោកយល់ថាយ៉ាងដូចម្ដេចដែរ?

[០៩:៣៧:១៥]

**ឆ៖** ខ្ញុំមិនដឹងថាយល់ថាម៉េច ព្រោះក្នុងឆាកនយោបាយ ខ្ញុំអត់ដែលបានរៀនសូត្រ។ ខ្ញុំអត់យល់ ហើយក៏មិនអាចឆ្លើយយ៉ាងម៉េចបាន។

**ស៖** បាទ មិនថ្វីទេ។ បើលោកមិនចូលពាក់ព័ន្ធរឿងនយោបាយទេ ខ្ញុំនឹងសួរលោកអំពីការអនុវត្តជាក់ស្តែងនៅក្នុងមូលដ្ឋានតែម្តង។ លោកសាក្សី ខ្ញុំសូមអានសម្រង់មួយទៀតពីសៀវភៅមួយក្បាល សៀវភៅដែលសរសេរដោយ ថេត សម្បត្តិ ជាពិសេស គឺឯកសារ E3/4202, ERN អង់គ្លេស 00757532, ខ្មែរ 00858342, បារាំង 00849437។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតអានសម្រង់ចេញពីសៀវភៅនេះ ប៉ុន្តែខ្ញុំមិនបញ្ចេញឈ្មោះបុគ្គលនេះទេ ដោយសារថាគាត់ គឺ TCW-959។

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន មុននឹងមេធាវីការពារក្តីអានសម្រង់ដើម្បីប្រតិចារឹក ខ្ញុំសូមកែតម្រូវការលើកឡើងសម្តីរបស់គាត់ដែលបានអានសម្រង់របស់សាក្សីមុននេះ។ នេះគឺជាចម្លើយរបស់បុគ្គលម្នាក់ ដែលជាប្រធានផ្នែកខាងភស្តុភារនិងសេដ្ឋកិច្ច ដែលបានដឹងផ្ទាល់អំពីផែនការនេះ។ ប្រធានភស្តុភារសេដ្ឋកិច្ចនេះ មុនឆ្នាំ១៩៧៥ គាត់ធ្វើការនៅកងនេសាទតំបន់៤ ហើយព័ត៌មាននេះហាក់បី -- គាត់ថាគាត់ស្តាប់ឮទៅ ហាក់បីដូចជាក្រោយ៧៥ គឺជាការឃោសនាទេ។ ដូច្នេះ ដើម្បីឲ្យច្បាស់សម្រាប់ប្រតិ-ចារឹក នេះមិនមែនជាសក្ខីកម្មពីបុគ្គលដែលមានឋានៈខ្ពស់ តួនាទីខ្ពស់នៅក្នុងព្រឹត្តិការណ៍ដែលបានកើតឡើងនោះទេ។

[០៩:៣៩:៥១]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំដឹងថាបុគ្គលនោះគឺជាសមាជិកនៃភូមិភាគពាយ័ព្យ។ នៅផ្នែកបន្ទាប់នៃសវនាការ ខ្ញុំដឹងថាតុលាការនឹងកោះហៅបុគ្គលរូបនេះ។ លោកសាក្សីនេះគឺមកពី -- គឺជាប្រធានមន្ទីរពេទ្យនៃតំបន់មួយនៅក្នុងខេត្តបាត់ដំបង។ បុគ្គលនេះបានឆ្លើយនៅក្នុងកិច្ចសម្ភាសន៍ សូមដកស្រង់ សម្រង់៖ “នៅក្នុងកិច្ចប្រជុំគាត់បានប្រជុំនៅស្តៅ ដើម្បីទម្លាក់ ប៉ុល ពត។ រស់ ញឹម បាននិយាយថាភាពសម្ងាត់គឺចាំបាច់បំផុត បើរកឃើញ គេរកឃើញអ្នកណាម្នាក់ថាជាអ្នកចូលរួមពាក់ព័ន្ធនៅក្នុងផែនការនេះនឹងត្រូវគេសម្លាប់ចោលហើយ។” សាក្សី 2-TCW-959 បានឆ្លើយថា បានទទួលការណែនាំពី រស់ ញឹម គាត់បញ្ជាឲ្យប្រុសៗ ៣០នាក់ដើម្បីបញ្ជូនថ្នាំពេទ្យ និង ឧបករណ៍ចូលទៅក្នុងទីបញ្ជាការរបស់គាត់។ នៅពេលដែលសួរថាហេតុផលថាហេតុអ្វីបានជាគេចល័តកម្លាំងបែបនេះ គាត់ថា គឺរៀបចំកម្លាំងដើម្បីបង្កសង្គ្រាមជាមួយ

ថៃ។ យើងបានលាក់អង្ករទុកនៅបាត់ដំបង-បន្ទាយមានជ័យ។ ពួកគេមានផែនការកម្ទេចស្ពានដែលត្រូវដឹកស្បៀងទៅកាន់បាត់ដំបង ដើម្បីគ្រប់គ្រងតំបន់ភាគខាងលិចតែម្តង ហើយធានាថាមានសម្ភារៈ និងស្បៀងអាហារ។ ផែនការនេះធំណាស់ ហើយសំខាន់ណាស់ ហើយបើយើងចង់ឱ្យវាដំណើរការទៅមុខបាន យើងត្រូវប្រុងប្រយ័ត្ន។" នេះវាសាក្សី 2-TCW-959 ឆ្លើយយ៉ាងដូច្នេះឯង។ ទោះបីជាសាក្សីនេះមិនមកពីតំបន់របស់លោកក្តី ក៏លោកនិយាយអំពីការស្តុកអង្ករ សម្ភារៈ ស្រូវ ដើម្បីឧបត្ថម្ភទៅដល់កងទ័ពភូមិភាគពាយ័ព្យសម្រាប់ធ្វើការវាយបកមកលើក្រុម ប៉ុល ពត វិញ។ តើលោកបានដឹងអំពីការស្តុកអង្ករ និងសម្ភារៈផ្សេងៗ ដើម្បីបម្រើ ដើម្បីការបះបោរនេះដែរទេ?

[០៩:៤២:៣៤]

**ឆ៖** ខ្ញុំមិនដែលបានដឹង។ រឿងរ៉ាវទាំងអស់នេះ គឺខ្ញុំមិនដែលបានឮ ហើយក៏មិនដែលបានដឹងផែនការ។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលនិយាយអំពីកន្លែងមួយដែលលោករស់នៅ និងធ្វើការនៅទីនោះ ខ្ញុំសូមអានសម្រង់មួយពីរបាយការណ៍ប្រចាំសប្តាហ៍របស់តំបន់៥ គណៈកម្មាធិការតំបន់៥។

លោកប្រធាន នេះឯកសារ E3/178។ ខ្ញុំដឹងថាមាន ERN ជាភាសាអង់គ្លេសទេ ហើយក៏ខ្ញុំសូមបង្ហាញឯកសារមួយទៀត មកពីភូមិភាគដែរ គឺឯកសារ E3/160 នេះគឺជារបាយការណ៍នៅខែមេសា ថ្ងៃទី០៤ ឆ្នាំ១៩៧៧ រហូតដល់ខែមេសា-២៩-៧៧ រហូតដល់មួយពាន់ប្រាំបួនរយ-- គឺរបាយការណ៍ចុះថ្ងៃទី២៧ ឧសភា ១៩៧៧។ របាយការណ៍នេះ និយាយអំពីស្ថានភាពខ្មាំង, ERN ជាភាសាអង់គ្លេស 00143452, ខ្មែរ00008497។ នៅថ្ងៃទី០៧ ឧសភា ១៩៧៧ ក្រុមទាហានខ្មែរសេរី១៥នាក់ បានចូលមកវាយប្រយុទ្ធ ហើយក៏បានជម្លៀសប្រជាជន២៥នាក់ចេញទៅ ពួកគេដុតឃ្លាំងស្រូវ ដុតស្រូវ ដុតឃ្លាំង ហើយនិងសម្លាប់កម្មាភិបាលយើងម្នាក់។

លោកសាក្សី តើលោកមានបានដឹងអំពីព្រឹត្តិការណ៍ដែលខ្ញុំទើបតែអានឱ្យលោកស្តាប់ ដែលចេញមកពីរបាយការណ៍របស់ភូមិភាគពាយ័ព្យនេះដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនដែលបានឮទេ។

**ស៖** របាយការណ៍ប្រចាំសប្តាហ៍ដែលខ្ញុំទើបតែយោងអម្បាញ់មិញនេះ គឺខ្ញុំដឹងថាមាន ERN តែជាភាសាអង់គ្លេសទេ ហើយរបាយការណ៍នេះនិយាយអំពីការលាក់អង្ករនៅភ្នំស្រុក ហើយនិងស្រុកព្រះនេត្រព្រះ។ នេះគឺជារបាយការណ៍សរសេរនៅថ្ងៃទី២១ ខែឧសភា ១៩៧៧ ចេញមកពីតំបន់នោះតែម្តង។

នៅពេលលោកធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម តើលោកដែលឮ តាវ៉ាល់ និយាយអំពី -- ឬក៏អ្នកណាម្នាក់ផ្សេងទៀត ក្រៅពី តាវ៉ាល់ និយាយអំពីការលាក់អង្ករ ដើម្បីចិញ្ចឹមទ័ពដែលត្រូវធ្វើការបះបោរនេះ។ ធ្លាប់បានឮទេ?

[០៩:៤៦:៣៥]

**ឆ៖** បាទ ខ្ញុំមិនដែលបានឮទេ មិនដែលមាននរណានិយាយឲ្យឮ។

**ស៖** ឥឡូវនេះ ខ្ញុំសូមត្រឡប់ទៅនិយាយអំពីកិច្ចប្រជុំមួយដែល តាវ៉ាល់ ដឹកនាំកិច្ចប្រជុំនេះ។ តាវ៉ាល់, តាហ៊ីង្ស ដឹកនាំកិច្ចប្រជុំនេះ។ កិច្ចប្រជុំនេះគឺមានសាក្សីម្នាក់បានឆ្លើយនៅក្នុងសវនាការអសាធារណៈថា ឆ្លើយពាក់ព័ន្ធទៅលោក ហើយលោកបដិសេធ។ បាទដើម្បី -- គឺគាត់និយាយតែអំពីផែនការសម្លាប់ដើម្បីបំពាក់អាវុធទៅដល់កម្លាំងកងចល័តនៅតំបន់៥។ កិច្ចប្រជុំនេះគឺធ្វើឡើងនៅភ្នំក្បូនខ្លែង អ្នកចូលរួមក្នុងកិច្ចប្រជុំនេះ គឺថានឹងត្រូវបំពាក់ស័ក្តិ៣ទាំងអស់។ ផែនការសម្លាត់នេះ គឺមិនត្រូវបានអនុវត្តទេ។ ពីម្សិលមិញ ខ្ញុំសួរថា ហេតុអ្វីបានជាបុគ្គលនេះនិយាយថា ពិតណាស់ថាលោកមានវត្តមាននៅក្នុងកិច្ចប្រជុំសម្ងាត់នោះ។ ខ្ញុំសួរសំណួរនេះដដែលឡើងវិញ ហើយលោកដឹងទេថា ហេតុ -- មូលហេតុដែលសាក្សីរូបនេះត្រូវបានតុលាការសួរនៅក្នុងសវនាការអសាធារណៈ គឺឆ្លើយថាលោកនេះពិតជាមានវត្តមាននៅក្នុងកិច្ចប្រជុំនោះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

[០៩:៤៨:៣៧]

**លោក ខេល លីសាក់៖**

ការជំទាស់របស់ខ្ញុំ គាត់សួរឲ្យសាក្សីឆ្លើយស្មានៗ ដើម្បីនិយាយអំពីថាតើ ស្មានៗ ថាតើសាក្សីមុននោះឆ្លើយហ្នឹងត្រូវ ឬមិនត្រូវ? ដូច្នេះ ខ្ញុំសូមជំទាស់ចំពោះបញ្ហានេះ។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ហ្នឹងគឺមានមូលដ្ឋានសមស្រប ហើយម៉្យាងទៀតសំណួរនេះសំណួរច្រំដែលទេ បានសួរ ហើយឆ្លើយរួចហើយកាលពីម្សិលមិញ។

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី បុគ្គលរូបនេះដែលបានមកឆ្លើយជូនតុលាការក្នុងសវនាការអសាធារណៈ ក៏បាននិយាយអំពីមនុស្សម្នាក់ទៀតដែលបានចូលរួមនៅក្នុងកិច្ចប្រជុំនេះដែរ។ គឺកម្មាភិបាលស្រីម្នាក់ឈ្មោះ មោង *(តាមការបកប្រែ)*។ លោកស្គាល់មេបញ្ជាការកងវរសេនាធំស្រីម្នាក់ឈ្មោះ ម៉ៅ ដែរទេ ដែលធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្មដែរនោះ?

**លោក 2-TCW-918៖**

**ឆ៖** ខ្ញុំមិនដែលបានស្គាល់ទេ មិនដឹងជានារីណាឈ្មោះ ម៉ៅ អត់។

**ស៖** លោកសាក្សី យើងបានរកឃើញនៅក្នុងបន្ទប់សវនាការនេះថា លោកធ្វើការជិតស្និទ្ធណាស់ជាមួយ តាវ៉ាល់ និង តាហឹង្ស។ អ៊ីចឹង ទើបបានជាលោកមានតួនាទីធំដុំនៅការដ្ឋានទំនប់ត្រពាំងថ្មនោះ។ សម្រាប់ខ្ញុំ គឺថាខ្ញុំពិបាកយល់ណាស់ ដែលថាលោកមិនដឹងអ្វីទាំងអស់ រួមទាំងផែនការដើម្បីទម្លាក់រដ្ឋាភិបាល។ លោកសាក្សី លោកឥឡូវហ្នឹងកំពុងតែភ័យ ឬម៉េច មិនហ៊ានឆ្លើយនឹងសំណួរខ្ញុំ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[០៩:៥១:៣៨]

**លោក ឌេល លីសាក់៖**

បាទ មេធាវីសួរថាតើ គាត់ខ្លាច មិនហ៊ានឆ្លើយឬយ៉ាងម៉េច គឺថាមិនៗទាស់អីទេសំណួរនេះ ប៉ុន្តែការកំណត់អំពីលក្ខណៈនៃផែនការសម្លាប់ទម្លាក់កម្ពុជាប្រជាធិបតេយ្យ គឺចម្លើយនៅស-២១ គឺថាជាពាក្យចចាមអារ៉ាម គឺជាការដែលសួរ គាត់ថា ខ្លាចមិនហ៊ានឆ្លើយ ឬក៏យ៉ាងម៉េចនោះ មិនត្រឹមត្រូវទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំមិនដែលលើកយកឯកសារណាមួយពីស-២១ ថាជាព័ត៌មាន គឺថាចចាមអារ៉ាមនោះទេ មិនដែលយកមកសួរផង។

**ប្រធានអង្គជំនុំ៖**

មេធាវីលោកបន្តសំណួរទៅ ហើយលោកមិនគប្បីប្រើសំណួរសួរទៅសាក្សី ខ្លាច ភ័យ ឬក៏មិនភ័យនោះទេ។ អាកប្បកិរិយារបស់សាក្សីរហូតដល់ម៉ោងនេះ មិនមានអាកប្បកិរិយាណាមួយព្រួយបារម្ភពីការផ្តល់សក្ខីកម្មរបស់គាត់ទេ។ គាត់គ្រាន់តែឆ្លើយបញ្ជាក់ឲ្យបានច្បាស់លាស់នូវអ្វីដែលគាត់បានផ្តល់

សក្ខីកម្មជាក់ស្តែងនៅពេលនេះ ហើយនិងសក្ខីកម្មដែលបានកត់ត្រាដោយ ស៊ី.ឌី.ខេម កន្លងមក ដែលវាមិនត្រឹមត្រូវ ដោយមិនយកបញ្ជាក់ ព្រោះអង្គហេតុច្បាស់លាស់នៅក្នុងការទទួលបាននូវចម្លើយតប គឺយកអាពាក្យលេង សើច និយាយ បន្ថែមបន្ថយក្រៅ យកមកធ្វើជាកំណត់ហេតុដែលនាំឲ្យមានបញ្ហាសួរប្រឈមនេះ។

[០៩:៥៣:០៤]

បញ្ហាទី២ គ្រប់មនុស្សទាំងអស់ មិនថាបច្ចុប្បន្ន ឬក៏មិនថាអតីតកាលទេ មិនសុទ្ធតែដឹងអំពីរឿងហេតុទាំងឡាយដែលកើតឡើងនៅក្នុងសង្គមគ្រប់ជ្រុងជ្រោយ គ្រប់កន្តុកកន្តៀតនោះទេ។ យើងមិនជឿថាដឹងទេ សូម្បីតែមេធាវីខ្លួនឯងក៏ទំនងមិនដឹង សូម្បីតែ អ.វ.ត.ក ផ្ទាល់នេះ ក៏មិនដឹងថាគ្រប់ជ្រុងជ្រោយគ្រប់បុគ្គលិកថាធ្វើអ្វីខ្លះរាល់ថ្ងៃនេះ ប្រហែលជាលោកមិនដឹងទេ។ កុំថាឡើយដល់ទៅរឿងបញ្ហាសង្គមលើពិភពលោក ឬក៏ស្ថានភាពសង្គមកម្ពុជាបច្ចុប្បន្នថាយ៉ាងម៉េចនោះ សូម្បីតែនៅ អ.វ.ត.ក ទាំងមូលនេះប្រហែលជាលោកមិនដឹងផងទេ។ ជាក់ស្តែងយើងខ្ញុំក៏មិនដឹងថា ការប្រព្រឹត្ត ការវិវឌ្ឍទៅនៅអង្គភាពផ្សេងទៀត ក្រៅពីអង្គជំនុំជម្រះសាលាដំបូងយើង តើវាមានការផ្លាស់ប្តូរ ឬក៏មានការវិវឌ្ឍយ៉ាងម៉េចការធ្វើអីខ្លះ ឬមិនធ្វើអីខ្លះ ក៏យើងមិនដឹងដែរ។ អ៊ីចឹង គឺមិនបើប្រើអត្តនោម័តិ បញ្ជាក់ថាមនុស្សទាំងអស់សុទ្ធតែដឹងនោះទេ។ កម្រិតត្រឹមតែគាត់ដឹងបានហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន បើខ្ញុំជាសាក្សីក៏ខ្ញុំខ្លាចដែរ។ ខ្ញុំដឹងថាសាក្សីរូបនេះពិតជាខ្លាចហើយ សំណួរដែលសួរថាលោកកំពុងតែភ័យខ្លាចអីនេះ គឺថាជាសំណួរមួយត្រឹមត្រូវ ប៉ុន្តែបើសិនណាមិនអនុញ្ញាតឲ្យខ្ញុំសំណួរត្រឹមតែ តើលោកកំពុងតែភ័យខ្លាច ឬក៏អត់ អ៊ីចឹងខ្ញុំសូមឲ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចឥឡូវនេះតែម្តង។

**ប្រធានអង្គជំនុំ៖**

យើងសម្រេចថាគឺមិនមានបញ្ហាអីទេ បន្តការតាំងសំណួរពាក់ព័ន្ធនឹងអង្គហេតុដែលលោកមានបំណងសួរសាក្សីនេះទៅចុះ!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកប្រធានមិនទាន់ឆ្លើយសំណួរខ្ញុំ ប៉ុន្តែខ្ញុំសួរម្តងទៀត។ ដូច្នេះអ៊ីចឹងលោកសាក្សីលោកកំពុងតែភ័យខ្លាចឬ?

**ឆ៖** ខ្ញុំមិនមានភ័យអីទេ ព្រោះខ្ញុំកាលដើមដែលមានក្រុមជំនុំទៅពិភាក្សាខ្ញុំឯផ្ទះ ទៅជួបខ្ញុំឯផ្ទះ គឺចង់សួរការពិតនៃអាងត្រពាំងថ្ម ហើយខ្ញុំក៏តែងតែផ្តល់នូវការពិតដែលខ្ញុំដឹង ក្នុងអង្គភាពអាងត្រពាំងថ្ម តែប៉ុណ្ណោះ តែរឿងរ៉ាវអ្វីផ្សេងៗគឺខ្ញុំមិនបានដឹង ព្រោះខ្ញុំមិនបានអនុវត្ត ព្រោះខ្ញុំអនុវត្តតែការងារខ្ញុំដែលខ្ញុំដឹងថាតួនាទីភារកិច្ចនៅអាងត្រពាំងថ្មបាទ។ ដល់ការពាក្យដែលនិយាយលេងសាមញ្ញជាធម្មតាមកបូកសរុបដាក់បញ្ចូល គឺខ្ញុំឆ្លើយអត់កើតបាទ។

**ប្រធានអង្គជំនុំ៖**

ចម្លើយច្បាស់លាស់ហើយ សូមអញ្ជើញទៅមុខទៀត។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណ។

[០៩:៥៦:២៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

ឥឡូវដល់ម៉ោងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់ ដប់ប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ០៩:៥៧នាទី ដល់ម៉ោង ១០:១៥ នាទី)*

[១០:១៦:០៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះអង់តា ហ្គីសសេ ខ្ញុំជាមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។ ខ្ញុំនឹងសួរសំណួរបន្ថែមមួយចំនួនទៅកាន់លោក ក្នុងឋានៈខ្ញុំជាមេធាវី។ ឥឡូវនេះ ខ្ញុំចង់ត្រឡប់មកនិយាយអំពីការងាររបស់លោកនៅការដ្ឋានទំនប់ ដូចដែលលោកបានឆ្លើយជូនការិយាល័យសហព្រះរាជអាជ្ញា។ បើតាមខ្ញុំយល់ គឺលោកធ្វើការនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនៅទំនប់បី គឺទំនប់កំបោរ គោករំចេក និងត្រពាំងថ្ម។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**លោក 2-TCW-918៖**

**ឆ៖** បាទ សូមគោរពលោកប្រធានជាទីគោរព! សំណួរនេះគឺពិតជាត្រឹមត្រូវហើយ។

**ស៖** ជាដំបូង ខ្ញុំនិយាយអំពីទំនប់កំបោរ លោកបាននិយាយថាគេកំណត់ពេលវេលាច្បាស់លាស់សម្រាប់ការសាងសង់ទំនប់នេះ លោកថាគេកំណត់ឲ្យត្រឹមបួនខែជាដំបូង ហើយក្រោយមកទៀត តាវ៉ាល់បានសម្រេចថាតែបីខែទេ។ អ៊ីចឹងខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ក្នុងការដែលសម្រេចផែនការនេះ គឺថា លើកផែនការបួនខែឲ្យបានរួច ហើយរយៈពេលបួនខែនោះ គឺកងកម្លាំងទាំងអស់ ប្រធានវរៈ ប្រធានវរសេនាតូច សេនាធំ ដែលគេមានកម្លាំង ហៅតាវ៉ាល់ ហៅប្រជុំ សួរតើប៉ានប្តេជ្ញាដែរឬទេ ឲ្យបានផែនការនេះឲ្យបានរួចមុនបួនខែ។ ដល់សួរប្រជុំពិភាក្សាសួរទៅ គឺប្រធានកងទាំងនោះប៉ានប្តេជ្ញាឲ្យរួចបួនខែ បានឲ្យរួចបានមុនផែនការ ឲ្យបានមុនចូលឆ្នាំបាទ។ ម្ល៉ោះហើយគេនាំគ្នាប្តេជ្ញាគ្នាគេទៅតាមកម្លាំងខ្លួនគេ គឺមិនមែនអង្គការបង្ខំឲ្យប្តេជ្ញាទេ។

[១០:១៩:៣៥]

**ស៖** ក៏ប៉ុន្តែកាលកំណត់ដំបូងហ្នឹងគឺថាបួនខែឲ្យធ្វើឲ្យហើយ។ អ៊ីចឹងខ្ញុំយល់ខុសយ៉ាងម៉េចដែលថាតាវ៉ាល់ គាត់សម្រេចថាធ្វើឲ្យត្រឹមតែបីខែនោះ?

**ឆ៖** យល់នេះគឺត្រូវហើយ ព្រោះអង្គការគាត់ដាក់ទិសមកថាបួនខែ តើយើងអាចធ្វើរួចឬទេបួនខែ។ ហើយដល់ តាវ៉ាល់ នេះនឹកឃើញថាបួនខែនៅក្នុងអំឡុងចូលឆ្នាំ ម្ល៉ោះហើយគាត់ថាធ្វើម៉េចឲ្យ

បានរួចមុនចូលឆ្នាំបាទ ឲ្យរួចមុនចូលឆ្នាំ។ ដូច្នេះហើយបានកងកម្លាំងទាំងអស់ គឺប្តេជ្ញាយករួចមុនចូលឆ្នាំបាទ អ៊ីចេះ។ មិនមែនអង្គការបង្ខំឲ្យប្តេជ្ញាទេ។

**ស៖** ដូច្នេះការសម្រេចរបស់ តាវ៉ាល់ ក្នុងការកាត់បន្ថយមកនៅត្រឹមបីខែហ្នឹង គឺក្រោយពីការសួរយោបល់ពីមេផ្សេងៗហើយទើបគាត់សម្រេចថា បន្ថយមកនៅត្រឹមបីខែមែនទេ?

**ឆ៖** បាទ គាត់សួរយោបល់ហើយ យោបល់តាមកងកម្លាំងនេះទេ គេផ្តល់យោបល់ឲ្យគាត់ គេថាគឺសម្រេចឲ្យបានមុនចូលឆ្នាំ តែក្នុងរយៈពេលមុនចូលឆ្នាំមិនដឹងថា ប៉ុន្មានខែៗ គឺមិនអាចកំណត់បានទេព្រោះបានបួនខែដូចគ្នាក៏មិនដឹង ខ្លាចតែ ឧទាហរណ៍ថាបួនខែហើយ វាមិនទាន់ដល់ថ្ងៃចូលឆ្នាំ ខ្លាចគេចូលឆ្នាំដល់ខែ៥ ក៏មិនដឹង ព្រោះការកំណត់របស់គេ គឺថាឲ្យបានមុនចូលឆ្នាំ។

**ស៖** នៅពេលដែលលោកឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាកាលពីម្សិលមិញ លោកបានពន្យល់ថា មូលហេតុមួយដែលជំរុញឲ្យមេកងនីមួយៗនិយាយថា អាចសម្រេចបានត្រឹមបីខែហ្នឹង គឺម្នាក់ៗហ្នឹងចង់បានឡើងតំណែង។ អ៊ីចឹងខ្ញុំចង់ដឹងថា លោកចាំឈ្មោះមេកងមួយៗដែលបានឡើងតំណែងទេ ក្រោយពីសាងសង់ទំនប់កំបោរចប់នោះ?

[១០:២២:៣៣]

**ឆ៖** ក្នុងការឡើងតំណែងនោះ គឺមិនមានអ្នកណារៀបចំឲ្យឡើងតំណែងអីទេ គឺគ្រាន់តែមានការប្តេជ្ញាក្រែងលោបានឡើងតំណែងដោយខ្លួនឯងទេ ការប្តេជ្ញាខ្លួនឯងនេះ តែថ្នាក់លើមិនបានឲ្យអ្នកណាម្នាក់ថា អ៊ូ! អ្នកនេះឡើងពីប្រធានកងតូច ឡើងទៅប្រធានកងធំ ពីប្រធានកងធំឡើងទៅវរសេនាតូច ពីវរសេនាតូចឡើងវរសេនាធំ គឺអត់មានទេ គឺនៅតែដដែល។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីទំនប់គោករំចេកវិញម្តង។ ប្រសិនបើខ្ញុំស្តាប់មិនច្រឡំទេ គឺលោកឆ្លើយថា ការសាងសង់ទំនប់នេះបានចាប់ផ្តើមក្រោយពីចប់សាងសង់ទំនប់កំបោរ គឺក្រោយចូលឆ្នាំខ្មែរ ឆ្នាំ១៩៧៦ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ក្នុងការសាងសង់ទំនប់គោករំចេកនេះ វាក្រោយទំនប់កំបោរ។ បាទ មិនមែនក្រោយដោយចុងឆ្នាំទេ ក្រោយគ្នាប្រហែលជាមួយខែប៉ុណ្ណោះទេ។ មុននិងក្រោយ ទំនប់កំបោរចាប់ផ្តើមមុនបានប្រហែលមួយខែជាងបានចាប់ផ្តើមទំនប់គោករំចេកមួយទៀត។

**ស៖** លោកបានបញ្ជាក់ថា ការចាប់ផ្តើមសាងសង់ទំនប់កំបោរហ្នឹង គឺនៅខែកុម្ភៈ តើលោកចាំទេថា ពិតជាខែកុម្ភៈហ្នឹង ឬក៏ខែផ្សេង?

**ឆ៖** ខែកុម្ភៈ ខ្ញុំមិនស្គាល់ខែដែរ មិនដឹងថា ខែ១ ឬខែ២ ខែកុម្ភៈហ្នឹង ខ្ញុំអត់ដឹង ប៉ុន្តែទំនប់កំបោរនោះ គឺទឹកស្រកអស់ហើយ ដីសើមៗ។

**ស៖** ដូច្នេះ ការចាប់ផ្ដើមសាងសង់ទំនប់គោករំចេកហ្នឹង គឺមួយខែក្រោយពីគេចាប់ផ្ដើមសាងសង់ទំនប់កំបោរ បើសិនខ្ញុំស្ដាប់មិនច្រឡំទេ លោកថាទំនប់គោករំចេកហ្នឹងគឺបញ្ចប់នៅខែ៧ ខែ៨។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ទំនប់គោករំចេកនេះ ចាប់ផ្ដើមក្រោយទំនប់កំបោរ ព្រោះស្រូវអង្ករដែលនៅតាមនោះច្រូតរួចហើយ នៅសល់តែជញ្ជាំង បានចាប់ផ្ដើម ដល់ខែ៨ ខែ៩ នោះបានរួច ព្រោះផែនការមិនបង្ខំដូចទំនប់កំបោរទេ។

[១០:២៦:៣២]

**ស៖** ដូច្នេះមានន័យថា រយៈពេលសាងសង់គោករំចេកនោះ គឺមានរយៈពេលវែងការសាងសង់ទំនប់កំបោរ មែនទេ?

**ឆ៖** បាទ។ ការសាងសង់ទំនប់គោករំចេកនេះ មានពេលវែងជាងទំនប់កំបោរ ព្រោះទំនប់គោករំចេក វែងជាងទំនប់កំបោរដែរ វា១៨ម៉ែត្រ វាខុសគ្នា ទំនប់កំបោរវាតែ១៣ម៉ែត្រ។

**ស៖** កាលពីថ្ងៃច័ន្ទ ទី៣០ ខែកញ្ញា លោកបានឆ្លើយថា នៅទំនប់គោករំចេកហ្នឹង មានត្រាក់ទ័រមានអាសានី។ តើលោកអាចជម្រាបបានទេ តើម៉ាស៊ីនកាយដីទាំងអស់ហ្នឹងបានមកពីណា? ហើយអ្នកណាជាអ្នកបញ្ជូនម៉ាស៊ីនទាំងអស់នេះមក?

**ឆ៖** បាទ មានអាសានីបីគ្រឿង។ ខ្ញុំមិនដឹងថាបានពីណាទេ ប៉ុនគ្រាន់តែថាអង្គការជួយ ថាអង្គការជួយអាសានីបីគ្រឿង ព្រោះកម្លាំងលើកទំនប់នោះវាកម្លាំងតិច តែ៤.០០០នាក់ជាង។ ម៉្លោះហើយកម្លាំងតិច ទំនប់វាវែង ម៉្លោះហើយជួយអាសានីបីគ្រឿងដែលឈូសដី ព្រោះអង្គការជួយ មិនដឹងមកពីខាង ខ្ញុំអត់ដឹងដែរ ដឹងតែអង្គការជួយ។

**ស៖** លោកបានឆ្លើយថា អង្គការបញ្ជូនសម្ភារៈមកឲ្យជួយកម្មករ។ ហេតុម្ដេចបានជាលោកដឹងថា ម៉ាស៊ីនហ្នឹងអង្គការជាអ្នកបញ្ជូនមក? លោកមានបានចូលរួមប្រជុំណាមួយ ហើយគេប្រាប់លោកថាអង្គការជាអ្នកបញ្ជូនម៉ាស៊ីន ឬក៏សម្ភារៈទាំងអស់ហ្នឹងមក ឬក៏យ៉ាងណា?

**ឆ៖** បាទ នោះប្រធានខ្ញុំគាត់បានហៅកូនក្រុម ហើយទាំងខ្ញុំទាំងអីបានចូលរួមប្រជុំនៅលើទំនប់គោករំចេកនោះឯង។ នៅប្រជុំថា ពីរបីថ្ងៃទៀត គឺអង្គការជួយអាសានីបីគ្រឿង។ ស្រាប់តែដល់ពីរបីថ្ងៃ

ឃើញអាសានីទៅមែន។

**ស៖** ដូច្នេះ តាមពិតទៅលោកគ្រាន់តែដឹងថា អង្គការៗអ៊ីចឹង តែលោកមិនដឹងថាអ្នកណាពិតប្រាកដទេ ជាអ្នកបញ្ជូនម៉ាស៊ីនទាំងអស់ហ្នឹងមក មែនទេ?

**ឆ៖** បាទ ព្រោះគាត់ថាអង្គការ ខ្ញុំថាអង្គការតាម។ ព្រោះមិនមែនថា ឈ្មោះនេះឈ្មោះនោះឲ្យមក អត់មាន។

**ស៖** ពាក់ព័ន្ធទៅនឹងទំនប់គោករំចេកនេះដដែល ខ្ញុំចង់និយាយអំពីទស្សនកិច្ចរបស់មនុស្សម្នាក់ដែលលោកបានឆ្លើយជូនអង្គជំនុំជម្រះថា តាវ៉ាល់ ប្រាប់លោកថាជាលោក ខៀវ សំផន។ ក៏ប៉ុន្តែលោកផ្ទាល់ហ្នឹង ក្រោយមកលោកថា គឺថាដូចជាមិនមែន ខៀវ សំផន ទេ។ អ៊ីចឹងខ្ញុំចង់និយាយមក ត្រឡប់មកនិយាយអំពីរឿងនេះវិញ។ លោកបានឆ្លើយថាលោកបានឃើញឡានមួយនៅលើផ្លូវ គឺផ្លូវទៅភ្នំស្រុក លោកចាំទេ ថាលោកឃើញឡានហ្នឹងនៅចម្ងាយប៉ុន្មានគីឡូម៉ែត្រដែរ -- ប៉ុន្មានម៉ែត្រដែរពីភ្នំស្រុក?

[១០:៣១:០១]

**ឆ៖** ឡាននោះនៅឆ្ងាយពីភ្នំស្រុក មិនដឹងជាប៉ុន្មានទេ ព្រោះខ្ញុំដឹងថាពីភ្នំស្រុកមកគោករំចេកនេះវាឆ្ងាយគ្នាដែរ ព្រោះមិនដឹងថាប៉ុន្មានគីឡូបាទ ព្រោះនៅចំណុចនោះ គឺចំណុចព្រំប្រទល់ស្រុកព្រះនេត្រព្រះនិងព្រំប្រទល់ស្រុកភ្នំស្រុកបាទ។ ប៉ុន្តែប៉ុន្មានគីឡូ គឺខ្ញុំមិនអាចសន្និដ្ឋានបាន ឃើញឡាននៅលើថ្នល់មួយឈប់ហ្នឹង ហើយខ្ញុំក៏នៅឆ្ងាយពីឡាននោះប្រហែលជា២០០ម៉ែត្រជាង។

**ស៖** តាមរយៈការបកប្រែ ខ្ញុំស្ដាប់ឮថាមានឡានច្រើន។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកថា មានឡានច្រើន ឬក៏មានឡានតែមួយទេនៅថ្ងៃនោះ?

**ឆ៖** ថ្ងៃនោះមានឡានតែមួយទេ មិនមែនច្រើនទេ ប៉ុន្តែមនុស្សជិះក្នុងឡាននោះមិនដឹងប៉ុន្មានទេ ព្រោះមានចុះមកពីលើឡានចុះម្នាក់ ឈរលើផ្លូវលំនោះឯង ឈរមើលទំនប់នោះឯងតាមខ្ញុំស្មានមើល ព្រោះគាត់ឈរមើលពីលិចម្ដង ពីកើតម្ដង លិចម្ដង កើតម្ដង តែម្នាក់គាត់ប៉ុណ្ណោះឯង។ រួចហើយបានឃើញឡើងឡានបើកទៅភ្នំស្រុកបណ្ដោយ បានតាវ៉ាល់ មកជួបខ្ញុំ ក្រោយមក តាវ៉ាល់ គាត់ថាអំមិញ ខៀវ សំផន អំមិញ អ៊ីចេះ ហើយខ្ញុំពេលនោះ ខ្ញុំមិនដែលឃើញ ខៀវ សំផន ទេ ខ្ញុំឮតែឈ្មោះគាត់គណៈប្រធានរដ្ឋៗ។ ដល់ពេលគេហៅខ្ញុំចូលកន្លែងសវនាការនេះលើកដំបូង ឲ្យមកស្ដាប់ បាទ។ ខ្ញុំមកខ្ញុំឃើញ ខៀវ សំផន នៅកន្លែងនេះ មិនមែនដូចដែលខ្ញុំឃើញឯណោះទេ។ បានខ្ញុំថា បែបតាវ៉ាល់ ក៏គាត់មិនស្គាល់ ខៀវ សំផន ដែរ បែបគាត់ចេះតែថាទៅក៏មិនដឹង ព្រោះខ្ញុំមកឃើញឯណោះ គាត់ទាប ដែលខ្ញុំ

ឃើញឯណោះខ្ពស់ បាទ។ បានខ្ញុំក៏មិនសន្និដ្ឋានថាអ្នកណាដែរ ប៉ុន្តែអង្កាល់ដែលមិនដឹង តាវ៉ាល់ ថា ខៀវ សំផន ចេះតែថាតាមគាត់ទៅ ខៀវ សំផន។ ព្រោះការពិត ដល់មកឃើញ ខៀវ សំផន នេះមិនមែនរូបដែលខ្ញុំឃើញឯណោះទេ។

[១០:៣៣:៥៥]

**ស៖** លោកបានប្រើពាក្យថា "ក្រោយមក តាវ៉ាល់ ប្រាប់ខ្ញុំ"។ អ៊ីចឹងមានន័យថា ក្រោយពីលោកបានឃើញបុគ្គលម្នាក់ហ្នឹងចាកចេញទៅហើយ ទើបតាវ៉ាល់ ប្រាប់លោកថា ម្នាក់ហ្នឹងជាលោក ខៀវ សំផន មែនទេ? គឺខ្ញុំចង់និយាយថា មិនមែនពេលដែលលោកឃើញបុគ្គលហ្នឹងតែម្តងទេ គឺក្រោយពេលដែលបុគ្គលហ្នឹងចាកចេញទៅបាត់ហើយទេ បានតាវ៉ាល់ ប្រាប់ថា លោកហ្នឹងជា ខៀវ សំផន អ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតប្រាកដអ៊ីចឹងមែន។ ឡានចេញទៅឃ្ងួរហើយ បានតាវ៉ាល់ គាត់មកដល់ គាត់ប្រាប់ថា មានឃើញឡានឈប់នេះទេ? ខ្ញុំថា មាន ឃើញមនុស្សចុះម្នាក់ ហើយបានគាត់ថា ខៀវ សំផន ហ្នឹងចុះ។ ដល់ខ្ញុំ ខ្ញុំមិនស្គាល់ទេ ខ្ញុំថាតាមតែគាត់។ ដល់មកខ្ញុំនៅឯណោះ វាមិនមែនរូបដែលខ្ញុំឃើញឯណោះទេ។

**ស៖** លោកដឹងទេ មុនពេលដែលតាវ៉ាល់គាត់មកជួបលោកប្រាប់ថា អ្នកហ្នឹងជា ខៀវ សំផន ហ្នឹង គាត់មកពីណាដែរពេលហ្នឹង?

**ឆ៖** គាត់នៅក្នុងការដ្ឋានទំនប់នោះឯង កំពុងតែដើរមើលដែលអាសានីឈ្ងួសដី ព្រោះគាត់នៅឆ្ងាយ ខ្ញុំនៅជិត។ គាត់នៅរហូតភូមិអូរ បន្ទាត់បោះទានកាំងឯណោះ។ ដល់គាត់ឃើញឡានឈប់នោះ គាត់ជិះម៉ូតូមកបាទ គាត់ជិះម៉ូតូមកក៏ឡានចេញផុតទៅហើយបាទ ឡើងឃ្ងួរ ឡានប្រហែលជិតដល់ៗភ្នំស្រុកបានគាត់ជិះម៉ូតូមកដល់ បានគាត់សួរខ្ញុំទៅ ខ្ញុំប្រាប់គាត់ប្រាប់តាមដំណើរអ៊ីចុះទៅ។

[១០:៣៦:១៦]

**ស៖** លោកក៏បានឆ្លើយផងដែរថា នៅថ្ងៃនោះគឺអត់មានការប្រកាសអ្វីពាក់ព័ន្ធនឹងទស្សនកិច្ចជាយថាហេតុរបស់អ្នកធំទេ។ អ៊ីចឹងលោកអាចឆ្លើយបញ្ជាក់ម្តងទៀតបានទេ ថានៅពេលហ្នឹងគឺអត់មានគេប្រកាសប្រាប់ថាមានអ្នកធំណាមកទេ?

**ឆ៖** បាទ អត់មានអ្នកណាប្រកាសប្រាប់ទេ មិនដឹងស្រាប់តែឃើញឡានតែម្តង។

**ស៖** លោកទើបតែឆ្លើយថា តាវ៉ាល់ជិះម៉ូតូពីកន្លែងដែលគេជីកដី ហើយមកជួបលោក។ អ៊ីចឹងខ្ញុំ

ចង់ដឹងថាពេល តាវ៉ាល់ គាត់ទៅណាមកណាហ្នឹង គាត់តែងតែជិះម៉ូតូមែនទេ?

**ឆ៖** តាវ៉ាល់ គាត់ៗមានម៉ូតូជិះ គាត់ជិះម៉ូតូ។

**ស៖** កាលពីម្សិលមិញ បាទសូមទោស គឺមិនមែនម្សិលមិញទេ គឺកាលពីថ្ងៃច័ន្ទ លោកបានបញ្ជាក់ថាកន្លែងជីកដីទៅកន្លែងដែលលោកឃើញឡានហ្នឹងមានចម្ងាយប្រហែលជា២គីឡូម៉ែត្រ។ អ៊ីចឹងថ្ងៃហ្នឹងគឺពេលគាត់ជិះម៉ូតូនោះ គាត់ជិះម៉ូតូចម្ងាយ២គីឡូម៉ែត្រហ្នឹងមែនទេ ពីកន្លែងជីកដីមកកន្លែងដែលលោកឃើញឡានហ្នឹង?

**ឆ៖** បាទ ដែលខ្ញុំៗនៅឆ្ងាយពីឡានប្រហែលជា២០០ម៉ែត្រ មិនមែន២គីឡូជាងនោះទេ។ តែ តាវ៉ាល់ នោះគាត់នៅឆ្ងាយជាងនោះទេ គាត់នៅកន្លែងអាសានីឈ្យូសដីនោះ វាប្រហែលជា៣គីឡូជាងឯណោះ ហើយស្តាប់ច្រឡំ ព្រោះខ្ញុំគឺខ្ញុំនៅឆ្ងាយពីឡាន ប្រហែលពី២០០ម៉ែត្រជាង។

**ស៖** លោកឆ្លើយថាលោកឃើញមនុស្សម្នាក់ចេញពីឡាន ហើយលោកមាននៅចាំទេថាអ្នកផ្សេងទៀតនោះនៅក្នុងឡាននោះ ទោះបីជាមិនចុះក៏ដោយ លោកមាននៅចាំរូបរាងអីខ្លះទេ?

**ឆ៖** នៅក្នុងឡាននោះ ខ្ញុំមិនបានឃើញរូបរាងទេ ឃើញតែក្បាលនោះ ឃើញតែក្បាលក្នុងកញ្ចក់ឡាននោះ។

[១០:៣៩:៣៨]

**ស៖** អ៊ីចឹងមានន័យថាលោកឃើញតែក្បាលទេ។ ចុះអ្នកចុះពីឡាននោះ លោកមានចាំថាគាត់ចុះពីខាងតៃកុងឡាន ចុះពីខាងមុខឡានមួយចំហៀងទៀត ឬក៏ចុះពីខាងក្រោយ?

**ឆ៖** ដែលចុះហ្នឹង ខ្ញុំចាំមិនបានដែរនោះ ខ្ញុំភ្លេចទៅ ព្រោះក្បាលឡានទៅឯជើង តែត្រង់អ្នកចុះនោះ ខ្ញុំមិនដឹងថាចុះខាងណាទេ ប៉ុនដល់ខ្ញុំមើលទៅឃើញមនុស្សឈរតែម្តង មិនដឹងថាចុះខាងណា ឡើងខាងណា មិនបានជាពិចារណាឲ្យដិតដល់អីចុះទេ អាងតែមិនមែនរឿងរបស់ខ្លួនឯងហើយក៏ហីទៅ គ្រាន់តែមកបានឃើញ។

**ស៖** ខ្ញុំសូមបញ្ចប់ចំណុចនេះត្រឹមនេះ ឥឡូវនេះខ្ញុំចូលនិយាយអំពីចំណុចមួយផ្សេងទៀត លោកបានលើកឡើងជាច្រើនដងអំពីឈ្មោះ ជាល ជាពិសេសជាមួយនឹងលោកមេធាវី កូប៉េ។ ឥឡូវនេះ ខ្ញុំចង់ឲ្យលោកបញ្ជាក់ឲ្យបានច្បាស់ថា លោកឃើញ ជាល ហ្នឹង ជាលើកដំបូងបំផុតនៅពេលណា ក្នុងពេលដែលលោកធ្វើការនោះ?

**ឆ៖** ខ្ញុំបានឃើញ ជាល នៅលើកដំបូងបំផុត គឺខ្ញុំឃើញកាលដែលគាត់នៅស្វាយ ហើយខ្ញុំទៅ

ទាក់ទងយកម៉ាស៊ូតដាក់កាណូត ប៉ុនមិនបានទាក់ទងនឹងគាត់ទេ ទាក់ទងនឹងអ្នកផ្សេងទេ តាមអង្គភាពរបស់ខ្ញុំ ប៉ុន្តែឃើញគាត់នៅកន្លែងនោះ គេប្រាប់ខ្ញុំថា ជាលៗ ខ្ញុំក៏បានឃើញត្រឹមនោះឯង។ ហើយលើកក្រោយទៀត ខ្ញុំបានឃើញច្បាស់ដែលគាត់មកចាប់ តាម៉ន ហើយខ្ញុំដួលសន្លប់ក្នុងឡាន ខ្ញុំឃើញច្បាស់ គឺរូបនោះឯង។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីការចាប់ខ្លួន តាម៉ន នេះនៅពេលក្រោយ ក៏ប៉ុន្តែឥឡូវនេះខ្ញុំចង់បានការបំភ្លឺមួយថាលោកទៅយកប្រេងម៉ាស៊ូត។ អ៊ីចឹងនៅពេលដែលលោកឃើញ ជាល ដំបូងហ្នឹងលោកនៅក្នុងកងណា? លោកធ្វើការនៅត្រពាំងថ្ម ឬក៏លោកនៅក្នុងកងនេសាទនៅពេលនោះ?

**ឆ៖** បាទ ពេលដែលខ្ញុំឃើញនោះ ខ្ញុំនៅក្នុងអង្គភាពចល័តដែរ ប៉ុន្តែខ្ញុំនៅខាងផ្នែកនេសាទ។

[១០:៤៣:០៨]

**ស៖** សូមអរគុណ។ លោកបានឆ្លើយថាលោកឃើញ ជាល ច្បាស់ នៅពេលដែលចាប់ ម៉ន។ លោកអាចលម្អិតបន្តិចបានទេថា លោកឃើញគាត់ពេលនុ៎ងយ៉ាងម៉េច ហើយគេចាប់ ម៉ន ហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** ការដែលចាប់ ម៉ន នេះ គឺខ្ញុំពីរនាក់ តាម៉ន បានបណ្តើរគ្នាមកពីផឹកទឹកត្នោត ព្រោះដឹងខ្លួនថាគេចាប់។ មុននឹងងាប់ឲ្យបានផឹកទឹកត្នោតឲ្យឆ្អែតសិន។ ដល់ដើរចេញពីកន្លែងផឹកទឹកត្នោតមក ឃើញឡានសរបស់ ជាល ហ្នឹងឯង គឺបើកទៅដល់មុខខ្ញុំ គឺចុចហ្វ្រាំងឈប់ ពួកក្រុមយោធាចុះពីឡានព្រួកភ្ជង់ពួកខ្ញុំជាប់។ ខ្ញុំក៏គេថាស្នើឡើងឡាន ខ្ញុំក៏ឈានជើងឡើងឡាន។ ដល់ទៅមានយោធាម្នាក់ ខ្ញុំមិនអាចស្គាល់បាន ហើយចំណាំមិនបាន យកដៃវាខ្ញុំ កុំឲ្យឡើងឡាន រុញ តាម៉ន បញ្ចូលទៅក្នុងឡាន ហើយខ្ញុំក៏គេគ្រាន់តែវាបន្តិច ខ្ញុំក៏ដួលសន្លប់នៅនឹងកន្លែង។ ឡាន ក៏ចេញទៅផុតទៅ បាទ ទាល់តែគេសែងទៅដាក់មន្ទីរពេទ្យ ម៉ោងមួយកន្លះបានខ្ញុំដឹងខ្លួន។

**ស៖** លោកបានឆ្លើយថាលោកបានឃើញ ជាល ច្បាស់នៅក្នុងឡាន។ តើប្រពន្ធរបស់ តាវ៉ាល់ ក៏បាននិយាយអំពីឡានដែរនៅពេលដែលគេចាប់ តាវ៉ាល់ នោះ ហើយគាត់ថា ប្រពន្ធហ្នឹងគាត់ថាឡានហ្នឹងគឺឡានពណ៌ស។ អ៊ីចឹងខ្ញុំដឹងពេលដែលគេចាប់ ម៉ន ហ្នឹងឡានដែលលោកឃើញហ្នឹង គឺឡានហ្នឹងពណ៌អី ពណ៌សហ្នឹងមែនទេ?

**ឆ៖** បាទ ដែលគេទៅចាប់ តាម៉ន នោះគឺឡានពណ៌ស។

[១០:៤៥:៤៧]

**ស៖** នៅក្នុងកិច្ចសម្ភាសន៍របស់លោកជូនមជ្ឈមណ្ឌលឯកសារកម្ពុជាគឺឯកសារ E3/9094, ERN ជាភាសាបារាំង 01123651, ERN ជាភាសាអង់គ្លេសគឺ 00728691, ERN ជាភាសាខ្មែរ 00734101 ជាភាសាបារាំងនៅចុងទំព័រ។ លោកនិយាយអំពីការចាប់ ជាល ក៏ប៉ុន្តែមុននេះបន្តិច លោកនិយាយដូចតទៅ ខ្ញុំសូមដកស្រង់៖ "ជាល បានធ្វើការមួយរយៈពេល ហើយក្រោយមកគេបានចាត់តាំងគាត់ គេសួរថាពេលណាគេចាប់ខ្លួន ជាល? លោកឆ្លើយថា៖ គេចាប់ខ្លួនគាត់នៅពេលពួកនិរតីមកដល់។ ជាល បានចាប់កម្មាភិបាលពាយ័ព្យ ហើយអ៊ីចឹងពួកនិរតី គេចាំមើលសកម្មភាពរបស់ ជាល។ ពេលដែល ជាល ចាប់មនុស្សគ្រប់ប្រភេទហើយ ពួកនិរតីក៏ចាប់ជាល តែម្តង។" សូមបញ្ចប់ការដកស្រង់។

ដូច្នេះខ្ញុំចង់ដឹងថា លោកបានឃើញការចាប់ខ្លួនមនុស្សផ្សេងទៀតទេ ក្រៅពី តាម៉ន នោះ? ពីព្រោះលោកថា ជាល បានចាប់មនុស្សគ្រប់ប្រភេទទាំងអស់។ ដូច្នេះ ខ្ញុំចង់ដឹងថាក្រៅពី តាម៉ន នោះ ជាល មានចាប់អ្នកណាផ្សេងទៀតទេ?

[១០:៤៧:៤២]

**ឆ៖** បាទ ក្រៅពីចាប់ តាម៉ន មក ខ្ញុំក៏ចេញទៅអង្គភាពខ្ញុំនៅទន្លេសាបនោះទៅ។ តែក្រោយមកដល់គេចាប់តាមសហករណ៍តាមអីទៀត គឺខ្ញុំមិនដឹងថាអ្នកណាទេ គឺខ្ញុំមិនបានឃើញច្បាស់។ ហើយដល់ពេលគេចាប់ ជាល ក៏ខ្ញុំមិនដឹង។

**ស៖** លោកអាចពន្យល់បានទេ ថាលោកបានទទួលព័ត៌មានអ្វីខ្លះបានជាលោកឆ្លើយនៅក្នុងបទសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹងថា ជាល បានចាប់មនុស្សគ្រប់ប្រភេទទាំងអស់។ លោកបានស្តាប់ឮ ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំដឹងថា ជាល ដែលចាប់នេះ គឺដឹងច្បាស់ថាចាប់ក្នុងអង្គភាពចល័ត គឺចាប់តាំងពីប្រធានវរសេនាតូចដល់វរសេនាធំ នេះគម្រោងផែនការ។ តែក្នុងនោះមិនទាន់បានឃើញចាប់អ្នកណាបានទេ ព្រោះកម្លាំងទាំងអស់នោះ គេដឹងខ្លួន ខ្លះក៏បានរត់គេច មិនដឹងជារត់គេចទៅខាងណា ខ្ញុំក៏មិនដឹងដែរ។

[១០:៤៩:៣៤]

**ស៖** តើជាល ហ្នឹងធ្លាប់ធ្វើជាអនុរបស់ តាហ៊ីង្ស ទេ នៅពេលដែលតាវ៉ាល់ នៅបំពេញមុខងារនោះ?

**ឆ៖** បាទ កាល តាវ៉ាល់ នៅបំពេញមុខងារ ខ្ញុំធ្លាប់ឮគេថា រងពីតាងហ៊ីង្ស តាជាល – រងពីតាហ៊ីង្ស តាជាល ប៉ុន្តែពេលនោះខ្ញុំមិនដែលឃើញទេ។ មិនដែលឃើញរូប តាជាល ទេ ទើបតែឮគេថា។

ដឹងថារងតាជាល -- រងតាហឹង្ស ដឹងជារងមែនឬមិនមែន គឺខ្ញុំអត់ដឹងដែរ ប៉ុនឮថា ច្រើនគ្នាគេថាតែចុះឯង។

**សៈ** អម្បាញ់មិញលោកនិយាយអំពីទំនាក់ទំនងរវាងគ្រួសារ តាជាល និង តាញឹម។ លោកដឹងទេថា តាជាល ទទួលបានតំណែងជាអនុតាហឹង្សហ្នឹង ដោយសារតែមានទំនាក់ទំនងសាច់ញាតិជាមួយ តាញឹម ហ្នឹងមែនទេ?

**ធៈ** អានេះការស្មានរបស់ខ្ញុំទេ ព្រោះថា ឲ្យដឹងការពិតដល់មានចេញសេចក្តីប្រកាស គឺអានោះអត់មានទេ ការស្មានរបស់ខ្ញុំៗថា ព្រោះតាជាល កូនតាញឹម ម្ល៉ោះហើយកូនអ្នកធំគេតែងតែឲ្យធ្វើធំអីចុះឯង។

**សៈ** នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់លោកមេធាវី កូប៉េ អម្បាញ់មិញនេះ លោកបានបញ្ជាក់ថា លោកផ្ទាល់ លោកមិនបានចូលរួមក្នុងកិច្ចប្រជុំដែលដឹកនាំដោយតារិនទេ ហើយក្នុងពេលប្រជុំហ្នឹង គេនិយាយអំពីការវាយចូលរបស់វៀតណាម ហើយបន្ទាប់មក ក្នុងពេលហ្នឹងគឺថាមានការបញ្ជាឲ្យជីករណ្តៅលាក់ស្បៀង។ ខ្ញុំដឹងថាមានអ្នកផ្សេងទៀតចូលរួមនៅក្នុងកិច្ចប្រជុំហ្នឹង ហើយមកនិយាយរឿងហ្នឹងប្រាប់លោក។ ខ្ញុំយល់អីចឹងត្រឹមត្រូវទេ?

**ធៈ** បាទ ព្រោះមានគេប្រជុំ ក្រោយមកគេនិយាយប្រាប់ខ្ញុំ ខ្ញុំក៏និយាយតមកអីណេះ។

[១០:៥២:៤៧]

**សៈ** ប្រហែលជាមានបញ្ហាបកប្រែក៏មិនដឹង ខ្ញុំនិយាយអំពីកិច្ចប្រជុំដែលដឹកនាំដោយ តារិន។

**ធៈ** ប្រជុំដឹកនាំដោយ តារិន ខ្ញុំមិនដែលបានទៅប្រជុំផង។ ព្រោះខ្ញុំនៅឆ្ងាយជាងគេ គឺមិនដែលបានមកប្រជុំជាមួយគេទេ គ្រាន់តែឡើងមកទៅមានការងារអីក៏គាត់ប្រាប់ផ្ទាល់។

**សៈ** ទោះបីជាលោកមិនបានចូលរួមប្រជុំក៏ដោយ ក៏លោកបានឮអំពីកិច្ចប្រជុំហ្នឹង ហើយលោកដឹងថាមានបញ្ជាឲ្យគេជីករណ្តៅដើម្បីលាក់ស្បៀង។ អីចឹង លោកឯកភាពទេថាព័ត៌មាននោះគឺលោកស្តាប់ឮពីគេ មិនមែនលោកចូលរួមដោយផ្ទាល់ទេ។

**ធៈ** បាទ ព័ត៌មាននេះ គឺខ្ញុំឮពីគេប្រាប់ខ្ញុំ ព្រោះកាលដែលគេទៅប្រជុំនោះ ប្រជុំតែតារិន ហើយជាមួយនឹងយាយថែម ប៉ុន្តែខ្ញុំមិនដែលស្គាល់មុខគាត់ទេ ឮតែឈ្មោះ ហើយប្រធានសហករណ៍ ប្រធានឃុំ ប្រជុំមានផែនការនោះ គឺខ្ញុំដឹងច្បាស់ តែក្នុងអង្គភាពចល័តមិនមានផែនការជីករណ្តៅកប់ស្បៀងកប់អីទេ ព្រោះចល័តអត់មានស្បៀង។ ក្នុងនោះក៏ តារិន ក៏គាត់មិនបានប្រាប់មកកងចល័តឲ្យជីកស្អីៗ

គាត់អត់បានប្រាប់ទេ គាត់គ្រាន់តែប្រាប់ថា គាត់បានទៅប្រជុំជាមួយ យាយថែម។ គាត់និយាយរឿងដូច ដែលខ្ញុំនិយាយអ៊ីចេះឯង បានខ្ញុំដឹងពីគាត់ ក៏ខ្ញុំនិយាយតមក ជូនខាងព័ត៌មានដែលទៅសម្ភាសខ្ញុំនៅផ្ទះ។

**ស៖** លោកចាំកាលបរិច្ឆេទនៃកិច្ចប្រជុំហ្នឹងទេ ថ្ងៃណា ខែណា?

**ឆ៖** កាលបរិច្ឆេទនៃអង្គប្រជុំនោះ ខ្ញុំមិនបានដឹងទេ មិនដឹងថ្ងៃណា មិនដឹងខែណា។

**ស៖** ពេលហ្នឹងលោកនៅអង្គភាពនេសាទ ឬក៏លោកទំនប់ត្រពាំងថ្ម?

**ឆ៖** បាទ ពេលនោះ ខ្ញុំនៅអង្គភាពនេសាទ ប៉ុន្តែពេលដែលខ្ញុំដឹកត្រី ដឹកប្រហុកអីឡើងមកចូល នៅអង្គភាព នៅកន្លែងអាងត្រពាំងថ្មនេះ ក៏គាត់មានការអីក៏គាត់ប្រាប់ខ្ញុំឱ្យបានដឹងប៉ុណ្ណោះឯង។ មិន ដែលបានប្រជុំ មិនដែលបានអីទេ ព្រោះឆ្ងាយពីគេ គេអនុគ្រោះ។

[១០:៥៦:៥៤]

**ស៖** ចំណុចចុងក្រោយដែលខ្ញុំចង់និយាយជាមួយលោក លោកបានឆ្លើយជាច្រើនលើកច្រើនសា ថា អ្នកស៊ើបអង្កេតដែលស្តាប់ចម្លើយលោកនុំងប្រហែលជាច្រឡំ ឬក៏កត់ត្រាខុសនូវចម្លើយរបស់លោក ដូច្នេះខ្ញុំចង់ត្រឡប់មកនិយាយអំពីលក្ខខណ្ឌនៃការសម្ភាសរបស់លោកជាមួយនឹងមជ្ឈមណ្ឌលឯកសារ កម្ពុជានៅឆ្នាំ២០១១។ លោកចាំទេ នៅពេលដែលខាងមជ្ឈមណ្ឌលឯកសារកម្ពុជាទៅសម្ភាសលោក ហ្នឹងគេមានថតសំឡេងទេ?

**ឆ៖** ខ្ញុំភ្លេចដែរ ព្រោះវាមានទៅច្រើនសា មិនដឹងជាគេថតសំឡេងខ្ញុំ ឬគេមិនថត ខ្ញុំអត់បានដឹង ដែរ។ ព្រោះគេទៅច្រើនសាមិនមែនតែមួយសាទេ។ មានខ្លះប្រុសទៅ ជួនកាលពួកគេទៅក្មេងៗ ថាពួក គេនិស្សិត គេទៅសួរ គេថាគេឃើញរូបថតខ្ញុំនៅកន្លែងសាលាក្តីអីនេះ ហើយជួនកាលឃើញពួកជនជាតិ បារាំងមិនដឹង មិនដឹងជាបារាំង ដឹងជាអីទេ សៗ ខ្ពស់ ទៅៗ។ ម្ល៉ោះហើយខ្ញុំមិនអាចសន្និដ្ឋានបានថា យ៉ាងម៉េចដែរ មិនដឹងជាគេអាត់សំឡេងគ្រប់ទាំងនោះ ក៏ខ្ញុំមិនដឹង។ ម្ល៉ោះហើយការធ្វើនេះ បានជាការ និយាយលេង និយាយអីសំណេះសំណាលក្រៅអីវាមានចូលនៅក្នុងនោះ បានខ្ញុំថា បែបជាគេចេះតែអាត់ ដាក់ទេដឹង បានជាវាចូលរល់វ៉ុក្នា វាខុសពីរចនាសម្ព័ន្ធនៅអង្គភាព ចូលជ្រៅទៅពាសណាពាសណី។ ខ្ញុំក៏ ពិបាកឆ្លើយបន្តិចដែរ ឆ្លើយបានតែរឿងដែលខ្ញុំដឹងប៉ុណ្ណោះ។

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន និងសូមជំនួយពីមន្ត្រីតុលាការ ខ្ញុំអត់ឃើញមិនដឹងជាគាត់ទៅ ណាបាត់ហើយ។ អ៊ីចឹងសូមលោកប្រធានមេត្តាឱ្យនរណាម្នាក់ផ្តល់សម្រង់នៃកំណត់ហេតុរបស់មជ្ឈ-

មណ្ឌលឯកសារកម្ពុជា ជូនសាក្សី គឺឯកសារ E3/9094 ដើម្បីឲ្យសាក្សីគាត់អាននូវកំណត់ត្រាមួយនៅក្នុងប្រតិចារឹកនេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

កញ្ញា ជា ស៊ីវហ័ង យកឯកសារពីមេធាវី យកជូនសាក្សីពិនិត្យ!

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ចំពោះភាគីទាំងអស់ គឺ នេះគឺឯកសារ E3/9094 គឺមានតែជាភាសាខ្មែរ គឺនៅ ERN 00734031 គឺនៅចុងទំព័រមានការសរសេរជាភាសាខ្មែរ ខ្ញុំមិនដឹងថាលោកឃើញឬក៏អត់ លោកសាក្សី? គឺខ្ញុំគូសជាពណ៌លឿង មានន័យថា ជាការចម្លងចេញពីខ្សែអាត់ គឺការប្រតិចារឹកចេញពីខ្សែអាត់ លោកឃើញទេ។ គឺគេដាក់ថាចម្លងចេញពីអូឌ្យូ។

[១១:០១:១២]

**លោក 2-TCW-918៖**

**ឆ៖** បាទ ឃើញ។

**ស៖** អ៊ីចឹង លោកនឹកឃើញឡើងវិញទេ ថានៅពេលដែលគេសម្ភាសលោកហ្នឹង គេថតសំឡេងលោក? គឺបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹងគាត់បានថតសំឡេងលោក ពេលដែលគេសួរលោកនោះ។ លោកនឹកឃើញឡើងវិញទេ ថាបុគ្គលិកហ្នឹងមានបានប្រាប់លោកទេ ថាគេនឹងថតសំឡេងលោក?

**ឆ៖** បាទ ខ្ញុំនឹកឃើញហើយ ហើយគេថតសំឡេងមែនកាលណោះ។ ប៉ុនដល់ពេលបិទវិញ អីវិញ ខ្ញុំអត់ដឹងថា គេបិទពេលណា អត់ដឹង។

**ស៖** នៅទំព័រទី១នៃបទសម្ភាសន៍នេះ មានការសរសេររយៈពេលនៃការសម្ភាស គឺពីរម៉ោង ម្ភៃប្រាំបីនាទី ហាសិបបីវិនាទី។ ដូច្នេះ ខ្ញុំចង់សួរលោកថា លោកចាំទេ ថានៅពេលដែលលោកផ្តល់បទសម្ភាសន៍ដល់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ពេលហ្នឹងគឺប្រហែលជាពីរម៉ោងកន្លះ លោកនៅចាំទេ?

**ឆ៖** បាទ ចាំដែរ ប៉ុនថាខ្ញុំមិនដឹងថាប៉ុន្មានម៉ោង ព្រោះយូរដែរ។ ហើយក៏រឿងរ៉ាវយូរឆ្នាំ ខ្ញុំទ្រង់ភ្លេចដែរ។

[១១:០៣:២៨]

**ស៖** មិនជាបញ្ហាអ្វីទេ ទោះជាលោកមិនចាំរយៈពេលនៃការសម្លាសរបស់លោកក៏ដោយ។ អ៊ីចឹងចាំទេ ថាការសម្លាសហ្នឹង គឺសម្លាសតែម្តងជាប់គ្នារហូត ឬក៏មានការឈប់សម្រាកដែរ?

**ឆ៖** មិនដឹងយ៉ាងម៉េចដែរ ពេលសម្លាសហ្នឹងយូរដែរថ្ងៃនោះ។ ប៉ុនដល់សម្លាសក្រោយៗទៅ វាមានលឿន។ សម្លាសក្រោយទៀត វាមានលឿន។ មានលឿន មានយូរ ពីរបីដងអ៊ីចុះ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំមិនចង់រំខានលោកយូរទៀតទេ អ៊ីចឹងលោកប្រធាន ខ្ញុំអស់សំណួរហើយ។ ហើយលោកមេធាវី គង់ សំអុន ក៏គាត់អត់មានសំណួរដែរ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវី!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន ខ្ញុំនៅសល់ចំណុចមួយ គឺយើងអត់ទាន់បានទទួលរូបថតដែលយើងបានស្នើសុំកាលពីម្សិលមិញទេ ហើយខាងព្រះរាជអាជ្ញាគាត់បាននិយាយកាលពីម្សិលមិញថា គាត់រក ប៉ុន្តែឥឡូវមិនដឹងថាតើគាត់អាចផ្ញើរូបថតនោះមកខ្ញុំបាន ឬក៏មិនបាននៅឡើយទេ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ឥឡូវនេះយើងនឹងផ្តល់ ប៉ុន្តែយើងនៅរង់ចាំការអនុញ្ញាតពីខាងសហចៅក្រមស៊ើបអង្កេត ថាតើអនុញ្ញាត ឬក៏អត់? បើសិនយើងបានទទួលការអនុញ្ញាត គឺយើងនឹងផ្តល់ឱ្យទៅដល់ភាគីនានា ហើយខ្ញុំគិតថារូបហ្នឹងមិនមានអ្វីគួរឱ្យចាំអារម្មណ៍នោះទេ ប៉ុន្តែខ្ញុំឥឡូវហ្នឹង ខ្ញុំកំពុងរង់ចាំការអនុញ្ញាតសិន ពីខាងសហចៅក្រមស៊ើបអង្កេត។

[១១:០៥:៤២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមានព័ត៌មានសមស្របអាចទទួលយកបានហើយ។

បាទ ឥឡូវនេះដល់ពេលការស្តាប់សក្ខីកម្មសាក្សី 2-TCW-918 បានចប់ហើយ ហើយអង្គជំនុំជម្រះអរគុណលោកសាក្សី ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សីក្នុងរយៈពេលពីរថ្ងៃកន្លះកន្លងមកនេះ។ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ វត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាព

ចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោក ឬក៏គោលដៅណាដែរលោកមានបំណងចង់ទៅបានហើយ។ សូមលោកជួបតែសំណាងល្អ បានសេចក្ដី សេចក្ដីចម្រើនគ្រប់ពេលវេលា ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោកគាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ អរគុណលោកមេធាវី ម៉ម រិទ្ធា មេធាវីប្រឹក្សាសាក្សី ពេលនេះលោកអាចសម្រាកបានហើយ។ ហើយសវនាការជាបន្តទៅនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-300 ពាក់ព័ន្ធនឹងអង្គហេតុដែលចោទប្រកាន់ការប្រព្រឹត្តលើក្រុមគោលដៅជាក់លាក់ចំពោះជនជាតិវៀតណាម។ ហើយដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនឹងមានលោក ប៊ុន លឹមហ្វី ជាបុគ្គលិកអង្គការ ធី.ភី.អូ អង្គុយអម សូមភាគី និងសាធារណជនជ្រាប។

ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី 300 និងបុគ្គលិកអង្គការ ធី.ភី.អូ ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

[១១:០៩:០០]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកដើមបណ្ដឹងរដ្ឋប្បវេណី តើលោកឈ្មោះអ្វី?

**លោក ប្រាក់ ឌឿន៖**

**ឆ៖** ខ្ញុំបាទឈ្មោះ ប្រាក់ ឌឿន។

**ស៖** អរគុណលោក ប្រាក់ ឌឿន តើលោកកើតនៅថ្ងៃខែឆ្នាំណា លោកចាំដែរទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** កុំអាលៗឆ្លើយ រង់ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការដោយឲ្យសញ្ញាភ្លើងក្រហមសិន ហើយក៏ដូចគ្នាដែរ កាលណាយើង -- លោកស្ដាប់សំណួរទៅ គឺលោកគិតថា ដកឃ្លាដើម្បីឆ្លើយតបនឹងសំណួរហ្នឹងយ៉ាងដូចម្ដេច។ ស្ដាប់សំណួរបានហើយ ជាឱកាសល្អដែលគិតពីការឆ្លើយតបនឹងសំណួរ នោះគឺជាលទ្ធភាពនៃការប្រើពេលវេលា រហូតដល់ពេលដែលក្បាលមីក្រូហ្វូនប្រតិបត្តិការ។ តើលោកកើតនៅថ្ងៃខែឆ្នាំណា លោកចាំទេ?

**ឆ៖** បាទ ខ្ញុំអត់បានចាំទេ។

សៈ ចុះបច្ចុប្បន្ននេះ លោកនៅដល់ឆ្នាំនេះ លោកអាយុប៉ុន្មានហើយ?

ឆៈ ឥឡូវខ្ញុំ៧៣ ហើយ។

សៈ បាទ អរគុណ។ ហើយលោកប្រាក់ ខឿន លោកមានទីកន្លែងកំណើតនៅទីកន្លែងណាដែរ?

ឆៈ ខ្ញុំបាទ នៅឃុំកំពង់ព្រះ ឃុំផ្អកទ្រ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។

សៈ បាទ អរគុណ។ ចុះទីលំនៅរបស់លោកសព្វថ្ងៃ លោករស់នៅទីកន្លែងណា?

ឆៈ បច្ចុប្បន្ននេះ ខ្ញុំនៅភូមិដដែល ស្រុកកំណើតដដែល។

សៈ អរគុណ។ ហើយលោកប្រកបមុខរបររកស៊ីធ្វើអ្វីទៅសព្វថ្ងៃនេះ?

ឆៈ ខ្ញុំបាទ ជាគណៈកម្មការវត្ត។

សៈ អរគុណ ហើយឪពុករបស់លោកឈ្មោះអី? ម្ដាយបង្កើតរបស់លោកគាត់ឈ្មោះអី?

ឆៈ ឪពុករបស់ខ្ញុំបាទ ឈ្មោះ ប្រាក់ ផាវ។ ម្ដាយរបស់ខ្ញុំបាទ គឺឈ្មោះ អ៊ូម មាន។ គាត់បាត់បង់ជីវិតអស់ហើយ។

[១១:១១:៤២]

សៈ បាទ អរគុណលោក ប្រាក់ ខឿន។ ហើយសព្វថ្ងៃនេះ តើប្រពន្ធរបស់លោកឈ្មោះអ្វី? ហើយលោកមានកូនប៉ុន្មាននាក់?

ឆៈ ប្រពន្ធមុននោះ បានស្លាប់បាត់បង់អស់ហើយ។ ខ្ញុំបាទ កាល៧៩ហ្នឹង ខ្ញុំយកប្រពន្ធក្រោយមួយទៀតបាទ។

សៈ ប្រពន្ធក្រោយរបស់លោកហ្នឹង គាត់ឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់សព្វថ្ងៃនេះ?

ឆៈ ហើយខ្ញុំបាទកូនមុននៅសល់ពីរ។ ហើយខ្ញុំយកប្រពន្ធកូនក្រោយមានសល់កូនប្រាំ ទាំងអស់កូនប្រពន្ធក្រោយមានប្រាំពីរ ស្លាប់បាត់បង់ជីវិតអស់ពីរ នៅសល់តែប្រាំទេ។ បូករួមទាំងកូនមុននៅសល់ពីរ បូករួមទាំងអស់មានកូនប្រាំពីរនាក់។

សៈ បាទ អរគុណ។ ហើយលោក ប្រាក់ ខឿន ជាចុងក្រោយបង្អស់នៃការផ្ដល់សក្ខីកម្មរបស់លោកក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះ លោកមានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យពីថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ៧៩ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។ ហើយតាមព័ត៌មានរបស់លោកមន្ត្រីច្បាប់ -- មន្ត្រីរដ្ឋបាលតុលាការផ្ដល់ឲ្យយើងអំមិញថាលោកមានបញ្ហាសុខ

ភាព បញ្ជាក់ថាបើលោកមានបញ្ហាសុខភាព លោកមិនអាចផ្តល់សក្ខីកម្មបានទេ លោកអាចលើកដៃ ហើយស្នើសុំមកអង្គជំនុំជម្រះដើម្បីអាចសម្រាក ដើម្បីឈប់សម្រាកដើម្បី -- ឬក៏ទទួលការពិនិត្យព្យាបាលដោយគ្រូពេទ្យប្រចាំការនៅ អ.វ.ត.ក នេះ។ សូមលោកកុំខ្លាចក្រែងរអែងចិត្តអីណាដើម្បីឱ្យការប្រព្រឹត្តទៅបានល្អនៅក្នុងការដំណើរការសវនាការរបស់យើង។ ហើយជាបន្តទៅនេះ ហើយសំណួរសួរថាតើលោកដែលធ្លាប់បានផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍អ្វីជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេកន្លង -- រយៈពេលកន្លងមក?

[១១:១៤:០៦]

**ឆ៖** គឺខ្ញុំបានផ្តល់សក្ខីកម្មហ្នឹង ផ្តល់ទៅអ្នកដែលបានស៊ើបអង្កេត ហើយសួរខ្ញុំៗក៏បានរាយការណ៍ជូនចំពោះគាត់ដែលបានទៅសាកសួរនូវសំណុំបែបបទអស់រយៈកាលកន្លងមកដោយជំនាន់ប្រល័យពូជសាសន៍។

**ស៖** យើងមើលនៅក្នុង -- លោកយល់ទេ បញ្ហាគឺអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក នេះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ តើលោកដែលផ្តល់សក្ខីកម្មទេ ឬក៏មិនមែនទេ? ហើយអ្នកដែលទៅសួរលោកហ្នឹង អ្នកក្រុមការងារផ្សេង ឬក៏យ៉ាងម៉េច ក្រុមខាងណាគេ លោកចាំទេ?

**ឆ៖** ដែលទៅសួរហ្នឹង គឺខ្ញុំបាទអត់បានចាំជាឈ្មោះណាទេ ខ្ញុំអត់បានបញ្ជាក់ថា លោកនៅខាងណាៗទេ ប៉ុន្តែគេបានទៅសួរខ្ញុំថា ទោសកំហុសដែលបនប្រល័យពូជសាសន៍បានធ្វើទារុណកម្មរបៀបម៉េច ឲ្យអ៊ំពូឯងមានចម្លើយឆ្លើយតបនឹងសំណួរដែលគេសួរខ្ញុំជាម្ចាស់ជនរងគ្រោះនុ៎ង ហើយខ្ញុំក៏បានរាយការណ៍ជូនថា ពេលនេះ ម៉ោងនេះ ដែលគេធ្វើទារុណកម្មខ្ញុំ។ ពេលនេះ ម៉ោងនេះ គេធ្វើ ឧទាហរណ៍ទៅសម្លាប់ប្រពន្ធខ្ញុំ។ ហើយពេលនេះ ទៅនោះ គេធ្វើទារុណកម្មដល់ពេលយប់អធ្រាត្រ ធ្លាក់ទៅដល់កូនប្រពន្ធដែលម្តាយក្មេក ឪពុកក្មេកក៏បាត់ បានស្លាប់បាត់បង់ជីវិតអស់ហើយ នៅបនប្រល័យពូជសាសន៍។

**ស៖** លោកចាំទេថា លោកផ្តល់កិច្ចសម្ភាសន៍នុង់នៅថ្ងៃខែឆ្នាំណា? នៅពេលណាដែរ លោកចាំទេ? ហើយធ្វើនៅកន្លែងណា នៅទីកន្លែងណា?

**ឆ៖** ខ្ញុំបាទក៏បានចាំខ្លះ អត់ខ្លះ។ ខ្ញុំរាយការណ៍ជូនសមត្ថកិច្ច និងប្រធានតុលាការឲ្យបានច្បាស់តែមុននឹងខ្ញុំធ្វើសំណួមពរ ជូនណាវាមានការខ្វះខាតនូវចំណុចខ្លះដែលខ្ញុំបានចាំមិនបានអីនេះ សូមមេត្តាអធ្យាស្រ័យចំពោះខ្លួនខ្ញុំបាទ។

[១១:១៦:១៦]

**ស៖** យើងគ្រាន់តែសួរថា លោកបានឆ្លើយថា មានលោកបានផ្តល់កិច្ចសម្ភាសន៍ដល់អ្នកស៊ើបសួររបស់លោក។ យើងសួរថា កាលធ្វើកិច្ចសម្ភាសន៍នុ៎ង ធ្វើនៅពេលណា? នៅឆ្នាំណា? ហើយធ្វើនុ៎ងនៅកន្លែងណា? សំណួរឆ្លើយតែប៉ុណ្ណឹងទេ យើងមិនទាន់សួរអីផ្សេងទៀតទេ។ តើលោកចាំដែរទេ អាចផ្តល់បានទេ នូវចម្លើយតបនឹងសំណួរពីរសំណួរនេះ គឺធ្វើនៅទីកន្លែងណា? ហើយធ្វើនៅពេលណា?

**ឆ៖** ខ្ញុំបាទក៏អត់បានចាំទេ ដែលកាលគាត់សួរនុ៎ង ខ្ញុំក៏មានស្មារតីមួយភ្លេចពីមុន ស្មានតែគេសួរជារឿងធម្មតា ដល់គេសួរដល់មកសាលាក្តីខ្មែរក្រហម ខ្ញុំបាទក៏អត់បានចាំទេ សូមអធ្យាស្រ័យ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអនុវត្តតាមបទបញ្ញត្តិនៃវិធាន៩១ស្ទួននៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្តល់វេទិកាជូនក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ លោកប្រធាន យើងខ្ញុំសូមអនុញ្ញាតប្រគល់វេទិកានេះ ជូនមេធាវីលីម៉ា ង្វៀន ដែលជាមេធាវីរបស់គាត់។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**កញ្ញា លីម៉ា ង្វៀន៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។

[១១:១៧:៤៨]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយកញ្ញា លីម៉ា ង្វៀន៖**

**ស៖** លោក ឌឿន ខ្ញុំចង់សួរលោកអំពីស្ថានភាពគ្រួសាររបស់លោក ជាពិសេស ចំពោះប្រពន្ធនិងកូនរបស់លោក តើមានអ្វីកើតឡើងចំពោះពួកគេនៅក្នុងរបបខ្មែរក្រហម? ប៉ុន្តែជាដំបូង ខ្ញុំចង់សួរថា តើ លោកមកពីទីណា? នៅមុនឆ្នាំ៧៥ តើលោកស្នាក់នៅ ឬក៏លោករស់នៅតំបន់ណាដែរ?

**លោក ប្រាក់ ឌឿន៖**

**ឆ៖** គឺទី១ ដែលខ្ញុំបានខ្មែរក្រហមដែលត្រូវជម្លៀសលើកទី១ហ្នឹង ចេញពីភូមិមក មកស្នាក់នៅឃុំពេជចង្វារ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង។ ហើយបានគេឲ្យខ្ញុំធ្វើដំណើរហ្នឹងរយៈប្រហែលជាបួនខែ ហើយខ្ញុំក៏បែកបាក់ពីប្រពន្ធកូនហ្នឹង ចុះមកក្រោម គេធ្វើឲ្យធ្វើនេសាទត្រី ធ្វើឡូត៍ដើម្បីដោះស្រាយបញ្ហាត្រីហ្នឹងជូនអង្គភាព ជូនកម្មាភិបាលគ្រប់កង គ្រប់ក្រុមទាំងអស់។ ហើយបន្តពីនុ៎ងមកទៀត ក៏បានគេចាត់ទម្លាក់ឲ្យខ្ញុំ ប្រពន្ធកូននុ៎ងក៏បែកបាក់គ្នាតាំងពីពេលហ្នឹងមក មកនៅក្នុងភូមិ គេហៅថា ភូមិកោះត្រម៉ូវ -- អូន៎ ភូមិកោះតាម៉ូវ ហើយនិងស្តីពាក់កន្ទេល។

**ស៖** តើគេផ្លាស់លោកមកពីណា? គឺបានន័យថាមុនដែលលោកមកពេជចង្វារហ្នឹង តើលោកស្នាក់នៅកន្លែងណាដែរ?

**ឆ៖** ដែលខ្ញុំបាទធ្វើដំណើរពីភូមិស្រុកដែលគេដេញមកហ្នឹង គឺខ្ញុំបាទឡើងតាមថ្នល់ជាតិលេខ៥ កាត់ទៅលើ គេហៅថា ភ្នំគុក។ ចុះមកក្រោមហ្នឹង ហៅថា ឃុំពេជចង្វារ គេឲ្យខ្ញុំស្នាក់នៅហ្នឹង រយៈពេលគេបើកត្រី បើកអង្ករអីឲ្យហូប។ ដល់រយៈប្រហែលជាមួយអាទិត្យជាង ក៏អស់សត្រូវ អស់អង្ករទៅ ក៏ខ្ញុំបាទដើររត់ជញ្ជាត់មើលខ្មៅខ្ចងហ្នឹងដើម្បីហូបចុក ដើម្បីយកអាយុជីវិត ដើម្បីរស់។ ហើយដល់រយៈប្រហែលជាបីអាទិត្យអីទៀត គេទម្លាក់ខ្ញុំចុះមកឲ្យធ្វើខ្ញុំបែកបាក់គ្រួសារតាំងហ្នឹងហើយ។ បាទ ខ្ញុំចុះមកដល់ភូមិកោះតាម៉ូវហ្នឹង គេឲ្យកាន់ឡូតិ៍នេសាទត្រី បាទ ដើម្បីគេចែកទៅតាមក្រុម តាមកង តាមចិត្តដូចថា ខ្មែរក្រហមគេចាត់ចែងតាមទិស។ បើនិយាយតាមច្បាប់ហ្នឹង គេនិយាយថា តាមទិសអង្គការដែលគេចាត់ឲ្យយើងទៅកន្លែងណា យើងអត់សិទ្ធិអីថា សុំគេបានអីបានទេ តែគេចាប់ត្រូវតែភារកិច្ចហ្នឹង យើងត្រូវតែធ្វើជូនអង្គការ។

[១១:២០:៤០]

**ស៖** សូមអរគុណ លោក ឌឿន ខ្ញុំនឹងសួរលម្អិតបន្ថែមទៀតនៅកន្លែងដែលលោកផ្លាស់ទី ប៉ុន្តែឥឡូវនេះ ខ្ញុំចង់ផ្តោតសំខាន់ទៅលើការរៀបការរបស់លោកជាមួយប្រពន្ធទី១។ នៅពេលដែលលោករៀបការជាមួយប្រពន្ធលោកទី១នោះ តើលោករៀបការនៅក្នុងឆ្នាំណាដែរ?

**ឆ៖** បាទ ខ្ញុំដែលរៀបប្រពន្ធទី១ ដែលនៅរបបសម្តេចសីហនុហ្នឹង នៅក្នុងឆ្នាំ១៩៦៦ ខ្ញុំកាលហ្នឹងអាយុ១៨ហើយ នៅភូមិដង្កែល ភូមិស្រុកកំណើតដង្កែល ឃុំដង្កែល ខេត្តដង្កែល។

**ស៖** តើប្រពន្ធទី១របស់លោកហ្នឹងឈ្មោះអ្វីដែរ?

**ឆ៖** ខ្ញុំបាទ គឺថាប្រពន្ធទី១ ឈ្មោះ ប៊ូ សំបាន។

**ស៖** តើគាត់ហ្នឹងជនជាតិអីដែរ?

**ឆ៖** បាទ ខ្ញុំបាទ ជម្រាបជូន គឺថាប្រពន្ធខ្ញុំជនជាតិវៀតណាម។

**ស៖** តើគាត់កើតនៅកន្លែងណាដែរ? តើគាត់ ទីកន្លែងកំណើតគាត់នៅទីណាដែរ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលៗទាន់ឆ្លើយតប!

**លោក ប្រាក់ ខឿន៖**

**ឆ៖** ប្រពន្ធខ្ញុំបាទកើតនៅស្រុកជាមួយគ្នា ភូមិជាមួយគ្នា ឃុំជាមួយគ្នា ខេត្តជាមួយគ្នា។

[១១:២២:២២]

**សួរដោយកញ្ញា លីម៉ា ង្វៀន៖**

**ស៖** អ៊ីចឹង មានន័យថានៅក្នុងភូមិផ្អុកទ្រូ ក្នុងខេត្តកំពង់ឆ្នាំង អ៊ីចឹងមែនទេ លោក?

**ឆ៖** បាទ ពិតប្រាកដមែន។

**ស៖** តើលោកអាចរៀបរាប់អំពីភិនភាគខាងក្រៅរបស់ប្រពន្ធលោកបានទេ គាត់មានរូបរាងយ៉ាងដូចម្ដេចដែរ?

**ឆ៖** ខ្ញុំបាទនឹងជម្រាបជូន។ ប្រពន្ធខ្ញុំធាត់ល្មម សាច់សហើយទាប ធាត់ក្រអាញ កម្ពស់ប្រហែលជា១,៥៥ម៉ែត្រទេ។ អាយុប្រពន្ធខ្ញុំបាទ គឺថាមានអាយុប្រហែលនឹងខ្ញុំបាទ។ បើនៅរស់ ប្រហែលជា៧៣ហ្នឹងបាទ។

**ស៖** តើគាត់និយាយភាសាអ្វីដែរ?

**ឆ៖** កាលហ្នឹងបានរៀនសាលាជាមួយខ្ញុំចេះភាសាខ្មែរច្បាស់ រៀនដល់ថ្នាក់ទី៨ បាទ។

**ស៖** តើគាត់មានសញ្ជាតិជាខ្មែរ ឬក៏មានកាតប្រជាជនជាខ្មែរដែរឬទេ?

**ឆ៖** ដែលកាលខ្ញុំរៀបហ្នឹង គឺថាមានចុះអេតាស៊ីវិល ក្របខ័ណ្ឌជាសញ្ជាតិខ្មែរ បាទ ពិតប្រាកដមែន។

**ស៖** តើគាត់ចេះនិយាយវៀតណាមដែរឬទេ?

[១១:២៤:០៩]

**ឆ៖** បាទ គឺចេះភាសាវៀតណាម តែអត់ប្រើទេក្នុងសង្គមនោះ ប្រើភាសាខ្មែរ និងភាសាបារាំង បាទ។

**ស៖** តើប្រពន្ធរបស់លោកហ្នឹងមានបងប្អូនដែរឬទេ?

**ឆ៖** ខ្ញុំបាទ ជម្រាបៗជូនថា មានបងប្អូនតែម្នាក់ខ្លួនឯងគត់។

**ស៖** តើគាត់មើលទៅ តើមុខមាត់គាត់ដូចជាវៀតណាម ឬក៏មុខមាត់គាត់ដូចខ្មែរ?

**ឆ៖** បាទ ខ្ញុំបានជម្រាបជូន មុខគាត់ដូចខ្មែរអ៊ីចឹង ប៉ុន្តែទាស់សាច់គាត់ស។

**ស៖** តើឪពុកម្ដាយរបស់គាត់ហ្នឹងជាជនជាតិវៀតណាមដែរមែនទេ?

**ឆ៖** តែខ្ញុំបាទជម្រាបជូន ម្ដាយនោះគឺកាត់បានទៅវៀតណាម តែឪពុកនោះចិនទាជីវ។

**ស៖** តើឪពុកម្ដាយប្រពន្ធរបស់លោកហ្នឹង គាត់កើតនៅទីណាដែរ?

**ឆ៖** គឺខ្ញុំបាទអត់ទាន់ទេ អត់ទាន់គាត់កើតនៅឯណាទេ ខ្ញុំក្ដាប់វាអត់ទាន់បាន ខ្ញុំនៅក្មេង ហើយខ្ញុំក៏មិនប៉ានសួរគាត់ដែរ -- គាត់ទៀត។

**ស៖** តើឪពុកម្ដាយក្មេងរបស់លោកហ្នឹងមើលទៅដូចជាជនជាតិវៀតណាម ឬក៏ស្លៀកពាក់ដូចជនជាតិវៀតណាមដែរទេ?

**ឆ៖** បាទ សុទ្ធតែម្ដង ស្លៀកខោអាវ ពាក់អាវ គាត់បួងសក់ពីក្រោយជនជាតិវៀតណាមតែម្ដង ហើយគាត់និយាយភាសាជាខ្មែរ អត់បានច្បាស់ទេ។ បើហៅ "ឈើ" គាត់ហៅ "សឺ" ហើយបើហៅ" អំបិល" គាត់ហៅ "អំបែល", បើហៅអំពិលវិញ គាត់ហៅ "អំពែល" បានជាថាន័យខ្មែរក្រហមនុំងវាស្ដាប់បាន ព្រោះគាត់នុំងបានរួមដំណើរនៅជាមួយគ្រួសារខ្ញុំ ហើយគេក្ដាប់បានចោទលើម្ដាយ។ ម្ដាយនិយាយអត់ច្បាស់។

[១១:២៦:៤៤]

**ស៖** តើគ្រួសាររបស់គាត់ហ្នឹង គោរពតាមប្រពៃណីវៀតណាមដែរឬទេ?

**ឆ៖** បាទ គោរពច្បាស់ ពេលដែលខែ ដូចយើងថាខែចូលអាដែងចូលឆ្នាំចិនអ៊ីចឹងទៅ គឺគាត់ធ្វើតាមនិយាយរបស់គាត់ ដែលគាត់បានចងក្រងជាកុងម៉ា ជីដូនជីតារបស់គាត់ គាត់ធ្វើតាមរបៀបរបប តែចំណែកខាងព្រះពុទ្ធសាសនាគាត់អត់ធ្វើទេ។ បើទៅវ៉ៃកាក់ -- លុយកាក់បន្តិចបន្តួចអាហ្នឹងគាត់ឲ្យ បើថាឲ្យទៅច្រើន ឬធ្វើបុណ្យតាមធម្មតា គឺអត់ឲ្យទេ។

**ស៖** តើនៅពេលដែលលោករៀបការជាមួយប្រពន្ធរបស់លោក ក្រុមគ្រួសាររបស់លោក ហើយ

និងសហគមន៍របស់លោក គេទទួលស្គាល់ដែរឬទេ?

**ឆ៖** បាទ អង្គាល់ជំនាន់នោះ គេទទួលក៏ឯកភាពគ្នាក៏រៀបចំជាពិធីហ្នឹង ហើយចាត់ចែងទៅមានការដូចថាសំណេះសំណាលជាមួយគ្នា ល្អសមរម្យអត់មានទាស់ទែងខ្វែងគំនិតអីទេ ទាំងខាងគេទាំងខាងខ្ញុំ។

**ស៖** តើនៅពេលដែលលោករៀបការហ្នឹង ប្រពន្ធលោកមានទទួលរងការរើសអើងរហូតទៅដល់ពេលដែលរបបខ្មែរក្រហមមកដល់ទេ?

**ឆ៖** បាទ អត់មានៗការប៉ះពាល់អីទេ គឺថាអបអរសាទគ្នា ស្វាគមន៍គ្នាជានិច្ចកាលតែម្តង។

**ស៖** តើឪពុកម្តាយក្មេករបស់លោកគាត់នៅមានជីវិតនៅឡើយទេឬនៅឆ្នាំ៧៥នោះ?

**ឆ៖** បាទ នៅក្នុងឆ្នាំ៧៥ គឺឪពុកក្មេងគាត់បានស្លាប់ពីជំនាន់សម្តេច សីហនុ ហើយ តែដល់ឆ្នាំ៧៥ ម្តាយហ្នឹងគាត់នៅរស់ ឡើងមកជាមួយនឹងខ្ញុំបាទ ដល់មកកន្លែងដែលខ្មែរក្រហមដែលឪខ្ញុំរស់នៅ។

**ស៖** ឥឡូវនេះ ខ្ញុំចង់និយាយពីកូនរបស់លោកវិញ។ តើនៅត្រឹមឆ្នាំ៧៥ លោកមានកូនប៉ុន្មាននាក់ដែរ?

**ឆ៖** ក្នុងឆ្នាំ៧៥ មានកូនប្រាំ បាទ មានប្រាំ។ ដល់មកក្នុងឆ្នាំ៧០ ចូល៧៧ គឺខ្ញុំបានកូននៅជំនាន់អាពតមួយទៀត។ កូនទាំងអស់មានកូនប្រាំមួយ។

[១១:២៩:៥៤]

**ស៖** តើលោកមានកូនប្រុសប៉ុន្មាននាក់ កូនស្រីប៉ុន្មាននាក់ដែរ?

**ឆ៖** ហើយខ្ញុំបាទជម្រាបជូន កូនស្រី -- កូនទាំងប្រាំមួយហ្នឹង គឺកូនស្រីមានប្រាំ កូនប្រុសមានមួយ។

**ស៖** តើកូនទាំងប្រាំមួយរបស់លោកហ្នឹងនៅជាមួយប្រពន្ធរបស់លោកជាជនជាតិវៀតណាមនោះមែនទេ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់ទៅនឹងពាក្យប្រពន្ធជនជាតិវៀតណាមនោះ។ ព្រោះវា

អាស្រ័យថាយើងកំណត់ជនជាតិ។ ព្រោះថាខ្ញុំយល់ស្របជាមួយដើមបណ្ដឹងរដ្ឋប្បវេណី ព្រោះថាដើមបណ្ដឹងរដ្ឋប្បវេណី គាត់ថាប្រពន្ធគាត់ត្រឹមឆ្នាំ៧៥ គឺមានសញ្ជាតិវៀតណាម។ គ្រាន់តែគាត់មានប្រភពដើមជាវៀតណាម។ គឺត្រឹមឆ្នាំ៧៥គាត់មានសញ្ជាតិខ្មែរ គ្រាន់តែគាត់មានប្រភពដើមវៀតណាមប៉ុណ្ណោះ។

**កញ្ញា លីម៉ា ង្វៀន៖**

លោកប្រធាន ដើមបណ្ដឹងរដ្ឋប្បវេណីគាត់បានផ្ដល់ព័ត៌មានថា ប្រពន្ធរបស់គាត់មានសញ្ជាតិវៀតណាមដែរ។ ដូច្នេះ នៅពេលដែលខ្ញុំនិយាយពីពាក្យថា "វៀតណាម" គឺខ្ញុំសំដៅទៅលើជាតិ ជាតិសាសន៍ ហើយនិងសិទ្ធិរបស់គាត់ គឺខ្ញុំមិនសំដៅទៅលើសញ្ជាតិរបស់គាត់ទេ។ តើខ្ញុំអាចអនុញ្ញាតបន្តទៅមុខបានទៀតទេ លោកប្រធាន?

[១១:៣១:៣៦]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ យើងបែងចែកពាក្យហ្នឹង ឲ្យច្បាស់ទៅ រវាងសញ្ជាតិ ហើយនិងជាតិនេះ។ ជាតិ – ជាតិកំណើតដើម ដើមកំណើត ហើយនិងសញ្ជាតិដែលប្រកាន់យកនៅតាមទីកន្លែងកំណើត ឬក៏ប្រកាន់យកដោយច្បាប់ផ្ដល់ឲ្យ។ អ៊ីចឹងវាឲ្យច្បាស់លាស់ ថាយើងច្របូកច្របល់ក្នុងការប្រើពាក្យនេះ នាំឲ្យការកើតនូវបញ្ហាចម្រូងចម្រាស់នៅក្នុងការសួរដេញដោលហើយ។ យើងប្រើពាក្យ "ជាតិ"ទៅ វាល្អត្រឹមត្រូវ ហើយងាយយល់ ហើយតែពិតមែនតែច្បាប់កម្ពុជា គឺ "ជាតិ" "សញ្ជាតិ"ហ្នឹង គឺប្រើមិនច្បាស់លាស់ទេនាពេលបច្ចុប្បន្ន ប៉ុន្តែជាទូទៅ គឺប្រើពាក្យ "ជាតិ"ហ្នឹង បានន័យថាជាតិដើមកំណើតដើម ហើយចំណែកឯសញ្ជាតិហ្នឹង គឺការដែលចុះបញ្ជីអត្រានុគោលដ្ឋាន ឬបានច្បាប់អនុញ្ញាតផ្ដល់សញ្ជាតិឲ្យជាដើម។ អ៊ីចឹង គឺសូមកំណត់ឲ្យបានច្បាស់លាស់។

**កញ្ញា លីម៉ា ង្វៀន៖**

សូមអរគុណលោកប្រធាន។ ដើម្បីបញ្ជាក់ឲ្យច្បាស់ នៅពេលដែលខ្ញុំប្រើពាក្យ "វៀតណាម" គឺខ្ញុំសំដៅទៅលើជនជាតិ គឺជនជាតិវៀតណាម។

**សួរដោយកញ្ញា លីម៉ា ង្វៀន៖**

**ស៖** លោក ឌឿន កូនស្រីប្រាំនាក់របស់លោក ហើយនិងកូនប្រុសម្នាក់ហ្នឹង ថាតើពួកគេនៅជាមួយប្រពន្ធទី១របស់លោកដែលជាជនជាតិវៀតណាមនោះ តើមែនទេ?

[១១:៣២:៥៧]

**លោក ប្រាក់ ឡើន៖**

**ឆ៖** បាទ អង្កាល់ដែលនៅរស់ជាមួយនោះ គឺកូនរួមរស់ជាមួយគ្នា។ ដល់ពេលខ្មែរក្រហមត្រូវកេណ្ឌដឹកនាំប្រជាពលរដ្ឋហ្នឹងឡើងមក គឺបានបែកបាក់គ្នា គេចែកទៅតាមកង តាមក្រុម តាមមូលដ្ឋាននីមួយៗ បាទ បែងចែកពីត្រឹមហ្នឹងមក ដែលគេជម្លៀសឡើងហើយ គេបែងចែកកូនទៅតាមផ្សេង ម្ដាយទៅតាមផ្សឹង ឪពុកមកផ្សឹង បាទ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ បាទ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកថ្ងៃត្រង់ ចាប់ពីពេលនេះតទៅនេះ រហូតដល់ម៉ោងមួយកន្លះរសៀលនេះសូមអញ្ជើញចូលវិញ ដើម្បីកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនៅអំឡុងក្នុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ ព្រមទាំងបុគ្គលិកអង្គការធី.ភី.អូ មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយកន្លះរសៀល។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣៤ នាទី ដល់ម៉ោង ១៣:៣២នាទី)*

[១៣:៣២:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយមុននឹងផ្ដល់វេទិកាជូនទៅក្រុមមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីនៃរឿងក្ដី០០២/០២ ទាំងអស់ថា នៅក្នុងកិច្ចដំណើរការសវនាការនៅរសៀលនេះ និងអាចនៅថ្ងៃបន្តបន្ទាប់ទៀត ដោយសារលោកស្រី ចៅក្រម ក្លូឌា ហ្វេនស៍ គាត់មានបញ្ហា

សុខភាពភ្លាមៗកាលពីថ្ងៃត្រង់ ថ្ងៃនេះ ហើយគាត់មិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការបានទេ ហើយបន្ទាប់ពីយើងខ្ញុំបានពិគ្រោះយោបល់ជាមួយនឹងបណ្ដាលចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងបានសម្រេចតែងតាំងចៅក្រម ម៉ាទីន ខារ៉ុបគីន ជាចៅក្រមបម្រុងខាងអន្តរជាតិ ជំនួសកន្លែងចៅក្រម ក្លូឌា ហ្វេនស៍ ដែលអវត្តមាន រហូតដល់ពេលណាដែលលោកស្រី ក្លូឌា ហ្វេនស៍មានវត្តមាន និងមានលទ្ធភាពអាចបំពេញការងារក្នុងការចូលរួមសវនាការនៅអង្គជំនុំជម្រះសាលាដំបូងវិញបាន។ ហើយការអនុវត្តនេះ ដោយយោងតាមខ្លឹមសារនៃបទប្បញ្ញត្តិនៃវិធាន៩៩(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ហើយជាបន្តទៅនេះ ផ្ដល់វេទិកាជូនទៅក្រុមមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលទទួលសិទ្ធិអាចតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបន្ត។ បាទ សូមអញ្ជើញ!

[១៣:៣៤:៤៣]

**សួរដោយកញ្ញា លីម៉ា ង្វៀន៖**

**ស៖** លោក ប្រាក់ ឌឿន មុនពេលឈប់សម្រាកថ្ងៃត្រង់នេះ លោកបានរៀបរាប់អំពីកូនៗរបស់គាត់។ ពីមុនមកលោកនិយាយថា លោកមានកូនស្រីប្រាំនាក់ និងកូនប្រុសម្នាក់។ ឥឡូវនេះខ្ញុំសូមឲ្យលោករៀបរាប់ពីឈ្មោះកូនស្រី និងអាយុរបស់កូនស្រីរបស់លោកម្ដងម្នាក់ៗ ចាប់ផ្ដើមពីកូនច្បងគេបង្អស់ជូនតុលាការស្ដាប់។ សូមអរគុណ។

**លោក ប្រាក់ ឌឿន៖**

**ឆ៖** បាទ ខ្ញុំបាទក៏សូមមានយោបល់ ដើម្បីផ្ដល់ជូននៅតុលាការពីកូនខ្ញុំបានមានចំនួនប្រាំមួយនាក់ គឺមានប្រាំនាក់ស្រី ម្នាក់ប្រុស។ តែកូនទី១ គឺឈ្មោះ ផាវ ជៀម អាយុ១៤ ភេទស្រី។ ទី២ អាយុ -- កូនខ្ញុំបាទឈ្មោះ ផាវ លៀម -- អ៎! ផាវ ម៉ៅ សូមទោស – ផាវ ម៉ៅ អាយុ១២ឆ្នាំ ភេទស្រី។ ទី៣ គឺឈ្មោះ ផាវ លាម អាយុ១០ឆ្នាំ ភេទស្រី។ ទី៤ ឈ្មោះ គៀម ភេទស្រី អាយុ៨ឆ្នាំ។ ទី៥ ឈ្មោះ ផាវ ឡួន អាយុបួនឆ្នាំ។ ដល់កូនទី៦ អាយុមួយឆ្នាំកន្លះ បាទ កូនប្រុស។

**ស៖** តើលោកធ្លាប់ហៅកូនៗរបស់លោកហ្នឹង ដោយប្រើឈ្មោះផ្សេងដែរទេ?

**ឆ៖** បាទ ខ្ញុំប្រើឈ្មោះផ្សេង គឺខ្ញុំមកដល់របបប្រល័យពូជសាសន៍ ខ្ញុំបាទបើហៅឈ្មោះពីដើមកំណើតបានន័យថា វាចាប់អារម្មណ៍ថាខ្ញុំ កូនខ្ញុំជាកូនវៀតណាម។ អ៊ីចឹងបំភាន់មតិដាក់ឈ្មោះកូនហ្នឹងបំបែកមួយតែឈ្មោះមីកំបាក់ មីកំពុក បាទ។

**សៈ** កូនស្រីពីរនាក់ហ្នឹង កូនស្រីពីរនាក់ណាដែរ ដែលលោកប្រើឈ្មោះ មីកំបាក់ មីកំពុក ហ្នឹង?

**ផៈ** ឈ្មោះកូនទី៤ ហៅ គៀម ហ្នឹង ពីដើមឈ្មោះហៅ ដូចថាហៅលេងអ៊ីចឹង ដ៏ពេលមកដល់ជំនាន់អាពត គេចេះសួររកឈ្មោះហ្នឹងខ្លាំងពេក ខ្ញុំឲ្យសំណូមពរទៅឲ្យក្មេងដែលប្រចាំការនៅកន្លែងកងកន្លែងក្រុមហ្នឹងថា មិនមែនឈ្មោះហ្នឹងទេ។ ឈ្មោះវាពីដើមមកឈ្មោះវា មីកំបាក់ មីកំពុក។ ខ្លាចគេរកកូនហ្នឹងខ្ញុំឃើញ គេយកទៅសម្លាប់ទាំងអស់។

[១៣:៣៧:៥៦]

**សៈ** លោកបានឆ្លើយថាកូនទី២របស់លោកឈ្មោះ ផាវ គៀម ហើយនិងកូនទី៤ គឺក៏ហៅ ផាវ គៀម ដែរ។ អ៊ីចឹងចុះកូនស្រីទី២ លោកហៅ មានហៅឈ្មោះផ្សេងពីនេះដែរ?

**ផៈ** បាទ ផុតពីហ្នឹង គឺខ្ញុំអត់មានហៅប្ដូរផ្លាស់ទេ ពីព្រោះនៅកងខុសគ្នា។ តែកងមួយហ្នឹង គេចំណាំមុខ ថាកូនខ្ញុំហ្នឹងឈ្មោះ ផាវ គៀម អ៊ីចឹង --អ៎នែ! ផាវ គៀម អ៊ីចឹងខ្ញុំប្រែឈ្មោះមកវា ឈ្មោះកំបាក់ កំពុក កាលជំនាន់សម័យរបបប្រល័យពូជសាសន៍នោះ ហើយខ្ញុំដល់រួចពីហ្នឹងខ្ញុំហៅឈ្មោះវាដដែលវិញ ប្រែឈ្មោះទៅ ផាវ គៀម វិញដដែល អាកូនទី៤។

**សៈ** ចុះហេតុអ្វីបានជាលោកប្ដូរឈ្មោះកូនស្រីរបស់លោកនៅក្នុងរបប ប៉ុល ពត?

**ផៈ** បានជាខ្ញុំប្ដូរឈ្មោះ ព្រោះនៅកងហ្នឹងវាស្គាល់ថាមីហ្នឹងឈ្មោះ តែឈ្មោះអ៊ីចឹង កូនវៀត-ណាមហើយ កូនតាឌឿន ហ្នឹងហើយ។ ហើយខ្ញុំបាទក៏ភ័យញ័រខ្លាំងពេក ក៏ផ្សាយៗប្រាប់តាមអូនកុមារដែលនៅក្រុមកងជាមួយថាមិនមែនទេ អូនឯងកុំហៅឈ្មោះវាអ៊ីចឹង។ ខ្ញុំបានទៅជួប ដើរតាមក្បែរៗហ្នឹងក៏លួចទៅជួប ខ្ញុំប្រាប់ថា ឈ្មោះវា មីកំបាក់ មីកំពុក ទេ។

**សៈ** ចុះមាន -- តើអាចមានអ្វីកើតឡើងចំពោះពួកគេ បើសិនណាជាលោកនៅតែហៅឈ្មោះថា ផាវ គៀម?

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំសូមជំទាស់លោកប្រធាន ដោយសារសំណួរនេះជាសំណួរឲ្យសាក្សីឆ្លើយស្មាន។

**កញ្ញា លីម៉ា ង្វៀនៈ**

លោកប្រធាន ដើមបណ្ដឹងរដ្ឋប្បវេណីបានបង្ហាញភស្តុតាងថា គាត់បានហៅឈ្មោះកូនស្រីគាត់ពីរនាក់ហ្នឹង ហៅឈ្មោះផ្សេងដើម្បីសុវត្ថិភាព។ អ៊ីចឹងឯងបានជាខ្ញុំសួរទៅគាត់ថាតើហេតុអ្វីបានជាគាត់បានគិតថាការហៅឈ្មោះផ្សេងពីឈ្មោះដើមនេះវាជួយការពារទៅដល់សុវត្ថិភាពរបស់ពួកគេ។ តើ

អនុញ្ញាតឲ្យខ្ញុំសួរបន្តទៅទៀត ឬក៏យ៉ាងណាដែរ?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដី នួន ជា។ ហើយអង្គជំនុំជម្រះត្រូវការស្ដាប់នូវចម្លើយតបរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ចំពោះសួរសំណួរដែលសួរចុងក្រោយដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទទួលសិទ្ធិ។ សូមអញ្ជើញឆ្លើយតបសាក្សី អ៎! ដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ប្រាក់ ឌឿន៖**

**ឆ៖** ហើយខ្ញុំបាទក៏បញ្ជាក់ជូនតាមដំណើរហេតុផលដែលកើតឡើងភ័យញ័ររន្ធត់ ស្លុតខ្លាំងពេកខ្លាចបាត់បង់ដល់កូនទៀត ម្ល៉ោះហើយខ្ញុំមានសេចក្ដីចាប់អារម្មណ៍ បានខ្ញុំជម្រាបជូនដល់តុលាការ នៃបញ្ហាហ្នឹងបើទុកឈ្មោះនោះដែលបានន័យថាកូនខ្ញុំត្រូវបាត់បង់ជីវិតហើយ។ អ៊ីចឹងឲ្យកាឡៃឈ្មោះហ្នឹងឲ្យកូនអូនកុមារដែលនៅជំនាន់ប្រល័យពូជសាសន៍ហ្នឹងជួយហៅថាវា មីកំបាក់ មីកំពុកទៅ។

**សួរដោយកញ្ញា លីម៉ា ង្វៀន៖**

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេ លោកបានចាប់ផ្ដើមហៅឈ្មោះកូនស្រីលោកហៅឈ្មោះផ្សេងនេះ គឺនៅក្នុងឆ្នាំណាដែរ?

**ឆ៖** នៅៗក្នុងឆ្នាំ៧៦កន្លះ។

[១៣:៤២:១៣]

**ស៖** ខ្ញុំក៏ចង់សួរបញ្ជាក់ផងដែរ លោកឆ្លើយថាលោកមានកូនប្រុសម្នាក់ ដែលមានអាយុមួយឆ្នាំកន្លះ។ កូនប្រុសនេះ នៅឆ្នាំ១៩៧៥ មិនទាន់កើតនៅឡើយទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ក្នុងឆ្នាំ១៩៧៥ កន្លះហ្នឹងវាអត់ទាន់បានជម្លៀសផង ទើបជម្លៀសឡើងមកលើបានបន្តិចទេ តែខ្ញុំជម្រាបជូនថាកូនដែលកើតនៅមួយឆ្នាំកន្លះហ្នឹងមកចូលនៅបនប្រល័យពូជសាសន៍ហើយចូល៧៦ ចូលជិត៧៧ហើយ ៧៦កន្លះ។

**ស៖** លោក ប្រាក់ ឌឿន ខ្ញុំចង់សួរលោកអំពីការផ្លាស់ប្ដូរទីលំនៅថាលោកបានផ្លាស់ប្ដូរទីលំនៅនៅក្នុងឆ្នាំមួយពាន់ប្រាំបួន -- នៅក្នុងឆ្នាំ -- ផ្លាស់ប្ដូរទីលំនៅ។ ចុះក្នុងឆ្នាំ១៩៧៥ គេផ្លាស់ទីលំនៅលោកឲ្យទៅលោកនៅក្នុងភូមិឈ្មោះអីដែរ?

**ឆ៖** ខ្ញុំបាទដែលឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសឡើងនៅឃុំអញ្ចាញរូង ស្រុកបរិបូរ បាទ។

**ស៖** ពីមុននោះ លោកបានផ្តល់ភស្តុតាងថា លោកត្រូវបានផ្លាស់ទៅនៅភូមិពេជចង្វារ។ តើភូមិមួយនេះនៅក្បែរភ្នំ ឬក៏យ៉ាងណា?

**ឆ៖** ភូមិនេះ ចម្ងាយពីភ្នំប្រហែលជា បួន-ប្រាំ -- ១៥គីឡូ បានដល់មកឃុំពេជចង្វារ បាទ អត់ទាន់ដល់ភ្នំទេ ប៉ុន្តែផ្លូវហ្នឹងទៅភ្នំ ឧបមាគេជម្លៀសយកទៅដាក់ចោលហ្នឹង ដល់រួចហ្នឹងបានគេបែងចែកជាកម្លាំងធ្លាក់ចុះមកវិញ គេឲ្យយើងប្រពន្ធទៅធ្វើស្រែ ឬមួយក៏ឲ្យប្តីហ្នឹងមកៗធ្វើនេសាទត្រី។ អស់រយៈកាលប្រហែលកន្លះខែ គេនឹងបែងចែកកម្លាំងហើយ គេអត់ឲ្យនៅជួបជុំគ្រួសារប្រពន្ធកូនទេ។

[១៣:៤៤:៤៣]

**ស៖** ត្រឡប់ទៅនិយាយអំពីភ្នំនេះ ភ្នំនេះឈ្មោះភ្នំអ្វីដែរ?

**ឆ៖** បាទ ខ្ញុំជម្រាបជូនថាភ្នំនេះគេហៅថា "ភ្នំគុក"។

**ស៖** តើសមាជិកគ្រួសាររបស់លោកត្រូវផ្លាស់ប្តូទៅរស់នៅភូមិពេជ្រចង្វារ ក្បែរភ្នំគុកនេះ ឬក៏យ៉ាងណា?

**ឆ៖** បាទ កាលដែលខ្ញុំនៅជួបជុំជាមួយគ្នា គឺនៅពេជចង្វារ ដល់ពេលកម្មាភិបាលគេទៅទម្លាក់ខ្ញុំចុះមកក្រោម មិនដឹងជាប្រពន្ធនោះទៅខាងណាអីខាងណា ខ្ញុំក៏អត់បានដឹង អត់ហ៊ានសួរ។ កាលណាបើសួរទៅ គេយក*វ៉ង់សែងញ៉ីម៉ង់* បានថា ខ្ញុំហ្នឹងដើម្បីស៊ើបការណ៍ គេយកទៅវាយចោល។ អ៊ីចឹងខ្ញុំបាទក៏នៅស្ងៀម អត់ហ៊ានតមាត់ តកទេ ស្រេកតែអង្គការកាលជំនាន់ហ្នឹង វាមានអំណាចប្រើទៅណា គឺនៅហ្នឹង។ ខ្ញុំបាទក៏ស្តាប់នូវទិសរបស់អង្គការរបស់គេ ខ្ញុំបាទក៏នៅនឹងកោះ ភូមិកោះតាម៉ូវ ភូមិស្តីពាក់-កន្ទេលទាំងពីរភូមិហ្នឹង។

**ស៖** តើលោករស់នៅភូមិពេជចង្វារអស់រយៈពេលប៉ុន្មាន មុនពេលគេផ្លាស់ប្តូរលោកទៅនៅកន្លែងបន្ទាប់មកទៀត?

**ឆ៖** អង្កាល់ហ្នឹងដែលខ្ញុំបានឡើងទៅទាំងប្តីទាំងប្រពន្ធជួបជុំគ្នាហ្នឹង រយៈប្រហែលជាកន្លះខែទេ។ កន្លះខែគេអាចចាត់ចែងឲ្យខ្ញុំហ្នឹងបែងចែក ប្រពន្ធនៅដោយឡែក ខ្ញុំចុះមកក្រោមដាច់ដោយឡែកចុះមកនៅក្នុងភូមិស្តីពាក់កន្ទេល ភូមិកោះតាម៉ូវ បាទ មកធ្វើនេសាទត្រី។

[១៣:៤៦:៣៣]

**ស៖** លោកបានឆ្លើយពីខាងដើមថា បន្ទាប់មកលោកបាន គេត្រូវបានបញ្ជូនទៅកោះមួយ។ តើគេបញ្ជូនទៅហ្នឹង កោះហ្នឹងនៅពេលណា?

**ឆ៖** កន្លះខែហ្នឹង ខ្ញុំក៏មិនបានស្តាប់នូវថា មិនដឹងជាពេលណាថ្ងៃណា ខែណាដែរ គេបញ្ជូនភ័យផង ភិតផង គេឲ្យមក ក៏ចេះតែមកតាមគេ អត់មានស្មារតីថាកត់ត្រាថា ឲ្យចាំពេលនេះ ខែនេះ ឆ្នាំនេះអី អត់បានចាំទេ សូមមេត្តាអត់ទោស បាទ។

**ស៖** នៅពេលគេបញ្ជូនលោកទៅកោះតាមូស*(តាមការបកប្រែ)* តើសមាជិកគ្រួសារទាំងអស់របស់លោក ត្រូវបានគេបញ្ជូនទៅជាមួយលោកដែរ ឬក៏អត់ទេ?

**ឆ៖** បាទ ខ្ញុំជម្រាបជូន អត់ទេ មានគេឲ្យទៅតែខ្ញុំម្នាក់ទេ ហើយនិងក្រុមគ្រួសារអ្នកដទៃទៀតប្រហែលជាបីបួននាក់ ដែលគេចាត់តាំងទៅឲ្យធ្វើព្រែក ធ្វើឡូត៍ដើម្បីដោះស្រាយនេសាទត្រីទៅតាមក្រុមតាមកង តាមមូលដ្ឋាន។

**ស៖** អ៊ីចឹង តើកូនចៅ និងប្រពន្ធរបស់លោកនៅស្នាក់នៅភូមិពេជចង្វារដដែលឬ នៅពេលដែលគេបញ្ជូនលោកទៅកោះតាមូស*(តាមការបកប្រែ)*?

[១៣:៤៨:០៦]

**ឆ៖** បាទ ខ្ញុំបាទជម្រាបជូនកាលដែលខ្ញុំទៅ គឺនៅជួបជុំរង្វង់គ្រួសារទាំងអស់ ដែលពេលខ្ញុំចុះផុតទៅ គេបែងចែកទៅតាមសហករណ៍។ កូនទី១ ដែលត្រូវកំពុងតែជាយុវវ័យ អាហ្នឹងគេឲ្យទៅតាមយុវវ័យ ដែលពេញក្រមុំ ពេញកំលោះហ្នឹង គេឲ្យទៅមួយទៅ។ ដល់កូនទី២ គេឲ្យខាងចូលខាងកសិដ្ឋានក្មេងកុមារ។ បាទ ដល់កូនទី៣ ដែលនៅបីឆ្នាំ បួនឆ្នាំហ្នឹង គេមកឲ្យមករៀនមកសូត្រ ហើយនិងបំពេញកាតព្វកិច្ចការងារដែលគេអាចប្រើធ្វើបាន។

**ស៖** ហើយឆ្នាំបន្ទាប់ដែលកូនស្រីរបស់លោកត្រូវបានគេបញ្ជូនចេញពីភូមិនោះ តើគេបញ្ជូនទៅកោះតាមូសដែរ ឬក៏គេបញ្ជូនទៅកន្លែងផ្សេង?

**ឆ៖** ខ្ញុំបាទជម្រាបជូនទៅ មិនកំណត់ទីតាំងនៅកន្លែងណាមួយទេ អាហ្នឹងគេហៅថា កងចល័ត ឧទាហរណ៍កម្មាភិបាល ឬក៏ក្រុមណាទៅសម្រុកក្នុងការងារខ្វះកម្លាំង គេបញ្ជូនទៅកសិដ្ឋានហ្នឹងហើយ គេអត់មានថា ប្រចាំទៅខាងណេះខាងណោះទេ។ ខ្ញុំបាទរៀបរាប់ វាមិនទាន់បានសព្វគ្រប់ ហើយខ្ញុំក៏មិនបានដឹងច្បាស់ដែរ ត្រង់ដំណើរការដែលអង្គការចាត់តាំងទៅឲ្យបំពេញការងារនោះ ខ្ញុំបាទដែលតាមឮសូរដែលរយៈប្រហែលជាកន្លះខែ គឺកូនហ្នឹងផ្តល់ឲ្យដំណឹងថា ខ្ញុំនៅឯណេះប៉ា ហើយនៅឯណោះ។ បាទ ខ្ញុំដែលប្រាកដប្រជា គឺគ្មានទេ។

[១៣:៤៩:៥៦]

**ស៖** តើលោកស្នាក់នៅកោះតាមូស*(តាមការបកប្រែ)* អស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំបាទនៅស្នាក់នៅកោះតាម៉ូវ ហើយនិងភូមិស្ដីពាក់កន្ទេល ដែលរយៈពេលប្រហែលជាមួយឆ្នាំកន្លះ។

**ស៖** អ្នកណាជាប្រធានភូមិរបស់លោកនៅកោះតាម៉ូវ?

**ឆ៖** ខ្ញុំបាទនឹងជម្រាបជូន កម្មាភិបាលដែលក្ដាប់ខ្ញុំនោះមានចំនួនបីនាក់ -- អ៎! បួននាក់ គឺស្រីបីប្រុសមួយ។ ខ្ញុំបាទនឹងរាយការណ៍ជូនឈ្មោះ តាទី១ ឈ្មោះតារស់ គាត់ជាប្រធានកងក្ដាប់នៅមូលដ្ឋានហ្នឹង ទី២ អ្នកទទួលខុសត្រូវខាងនេសាទ គឺឈ្មោះមិត្តហ៊ឹម ទី៣ គឺថាឈ្មោះមិត្តណា ទី៤ គឺឈ្មោះមិត្តកួន ដែលទទួលខុសត្រូវចំពោះខាងផ្នែកសេដ្ឋកិច្ច។

**ស៖** នៅពេលដែលលោកស្នាក់នៅកោះតាម៉ូវ តើលោកបានជួបប្រពន្ធរបស់លោកឡើងវិញទេ?

**ឆ៖** រយៈប្រហែលជាជាងមួយឆ្នាំ គឺប្រពន្ធខ្ញុំបាន ខ្ញុំបាទក៏បានស្នើថា អង្គការជួយបំពេញតួនាទីដូចខ្ញុំបានជម្រាបប្រាប់ឲ្យត្រង់ ដោយនឹកនិស្ស័យទៅប្រពន្ធកូន ខ្ញុំក៏សុំស្នើទៅកម្មាភិបាលទាំងមិត្តប្រុសមិត្តស្រីទាំងអស់ សូមមេត្តាជួយដើម្បីទម្លាក់គ្រួសារមក។ កាលហ្នឹង ជំនាន់គេស្ងិតណាស់រកបញ្ហាហូបចុកអត់បានទេ ហើយខ្ញុំមកនៅកន្លែងហ្នឹង ខ្ញុំជម្រាបជូនឲ្យច្បាស់ ថាមានត្រីសាច់ ឬក៏កន្លាំងហែអីអាចបកស្ងោរលួចលាក់ លួចបំពួន ចែកកូន ប្រពន្ធហ្នឹងហូបចុកខ្លះៗទៅបានៗរស់ទាំងអស់គ្នា។

[១៣:៥២:០១]

**ស៖** អ៊ីចឹងនៅកោះតាម៉ូវ ប្រពន្ធរបស់លោកបានមករួមរស់ជាមួយលោកវិញ ឬក៏យ៉ាងណា?

**ឆ៖** បាទ ដែលខ្ញុំៗ បាននៅកោះតាម៉ូវ បានប្រពន្ធនោះ ស្នើទៅកម្មាភិបាល -- កម្មាភិបាលហ្នឹងគេមានធម៌មេត្តាខ្លះ។ គេថា “អ៊ីចឹងចាំខ្ញុំចាត់ចែង ដើម្បីទម្លាក់គ្រួសារតាមក ឲ្យមកជួបគ្នា ក្នុងរយៈមួយឆ្នាំជាងហ្នឹង”។

**ស៖** ឥឡូវនេះ យើងចូលនិយាយហ្នឹង គឺតើវានៅចុង ជិតចុងឆ្នាំ១៩៧៦ មែនទេ?

**ឆ៖** បាទៗវាឆ្លងជិតចូល៧៧ ហើយ។

**ស៖** នៅពេលប្រពន្ធរបស់លោកបានមកជួបលោកនៅកោះតាម៉ូវ តើខ្មែរក្រហមបានដឹងថាលោកបានរៀបការជាមួយនឹងជនជាតិវៀតណាមដែរទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ចំពោះពាក្យខ្មែរក្រហម ការប្រើប្រាស់ពាក្យខ្មែរក្រហម ទោះបីជាឈ្មោះនេះសំដៅ

ទៅលើតែកម្មាភិបាលមូលដ្ឋានឬក៏សំដៅទៅលើបក្សកុម្មុយនីស្តកម្ពុជាក្តី ពីព្រោះយើងពេលនេះមកដល់ឆ្នាំ១៩៧៦, ៧៧ ហើយ គឺថា "*ខ្មែរវៀតណាម*" នេះ ជាពាក្យដែលជាក់លាក់ណាស់ ដូចនេះមិនត្រូវមកប្រើជំនួសនឹងពាក្យរបបនេះទេ។

**កញ្ញា លីម៉ា ង្វៀន៖**

លោកប្រធាន ខ្ញុំសូមរៀបសំណួរឡើងវិញ។

**សួរដោយកញ្ញា លីម៉ា ង្វៀន៖**

**ស៖** នៅពេលប្រពន្ធរបស់លោក បានមករស់នៅជាមួយលោកនៅកោះតាម៉ូវ តើមានកងទ័ពឬក៏កម្មាភិបាលណាម្នាក់ដែលធ្វើការនៅក្នុងបក្សកុម្មុយនីស្តកម្ពុជានៃរបបកម្ពុជាប្រជាធិបតេយ្យ បានដឹងថាលោកនេះ បានរៀបការជាមួយនឹងជនជាតិវៀតណាមដែរ ឬក៏អត់ទេ?

[១៣:៥៤:២២]

**លោក ប្រាក់ ឌឿន៖**

**ឆ៖** បាទខ្ញុំបាទជម្រាបជូនដល់ប្រធានតុលាការមេត្តាអធ្យាស្រ័យឲ្យខ្ញុំបាទ ក៏បានដឹងដោយសារដំណឹងថា ម្តាយនេះជាជនជាតិវៀតណាម និយាយមិនច្បាស់ទេ វាឲ្យនិយាយ វាបញ្ជាថា "ឈើ" ម្តាយខ្ញុំបាទគាត់ថា ម្តាយក្មេកខ្ញុំបាទក៏បាននិយាយ "សឺ" ហើយវាក៏ចាប់អារម្មណ៍ទៅ។ ហើយបញ្ហាទី២ គឺវាឲ្យនិយាយ "អំបិល", អំបិលហ្នឹង ភាសាម្តាយខ្ញុំនិយាយអត់ច្បាស់ ម្តាយក្មេកខ្ញុំហ្នឹង ក៏ភាសា "អំបែល" អ៊ីចឹងវាចាប់អារម្មណ៍ ហើយខ្ញុំអត់មានឲ្យគំនិតថាជនជាតិវៀតណាមអីទេ ព្រោះប្រពន្ធខ្ញុំបាទគឺខ្មែរសុទ្ធតែម្តង រៀនអក្សរជាមួយគ្នា ថ្នាក់ជាមួយគ្នា ប៉ុន្តែទាក់ម្តាយក្មេកគាត់និយាយអត់ច្បាស់ ដែលនៅរួមដំណើរគ្រួសារ ដែលនៅយុវវ័យនៅឡើយនោះ ដែលទម្រាំតែបានខ្ញុំ គាត់និយាយរបូតទាល់តែចប់ខ្មែរក្រហមហ្នឹងយកទៅវៃចោល។

**ស៖** តើកម្មាភិបាលនៅក្នុងភូមិរបស់លោកមាននិយាយអ្វីអំពីប្រពន្ធរបស់លោក និងម្តាយក្មេករបស់លោកដែលជាជនជាតិវៀតណាមនេះដែរទេ?

**ឆ៖** បាទ និយាយៗម្តងដែរ ខ្ញុំបានទៅនេសាទ ត្រឡប់មកវិញថា ប្រពន្ធមិត្តឯងខ្មែរ ឬក៏វៀត-ណាម? ខ្ញុំឆ្លើយទៅវាបំភាន់មតិខ្លះ បើឆ្លើយថាខ្មែរ ម្តាយក្មេកដែលនៅជាមួយបានន័យថា ខ្ញុំហ្នឹងបំភាន់មតិ ខ្លាចគេយកខ្ញុំហ្នឹងទៅវៃចោល។ ខ្ញុំពិចារណាសិនមុននឹងឲ្យគំនិតទៅគេ ដល់ពេលដែលខ្ញុំគិតឃើញថា ឆ្លើយខាងណាក៏ជាប់ៗ ខ្ញុំក៏ឆ្លើយតាមត្រង់ថា ប្រពន្ធហ្នឹងកូនរបស់គាត់ គឺកូនវៀតណាម។

[១៣:៥៦:១៦]

**ស៖** ចុះនៅពេលលោកឆ្លើយអ៊ីចឹង តើគេមានប្រតិកម្មយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំបាននឹងជម្រាបជូន អត់មាននិយាយអ្វីតទៅទៀតទេ ប៉ុន្តែខ្លាចលោគំនិតគុំកួន ម្ល៉ោះហើយគេគ្រាន់តែសួរអ៊ីចឹង ដើម្បីគេទុកសំងំដល់ពេលគេរើសើ អាហ្នឹងគេចាត់ចែងទៅតាមច្បាប់ទម្លាប់របស់គេ ខ្ញុំបាទក៏មិនបានយល់ដឹងដែរ។

**ស៖** ខ្ញុំនិយាយអំពីសមាសភាពប្រជាជននៅកោះតាម៉ូវ តើលោកអាចជម្រាបជូនតុលាការបានទេ នៅកោះតាម៉ូវ មានប្រជាជនវៀតណាមប៉ុន្មាននាក់ដែរ និងមានមានខ្មែរប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ ខ្ញុំបាទជម្រាបជូន ដែលជនជាតិវៀតណាមដែលរស់នៅ ដែលមានប្រពន្ធប្ដីដូចជារូបខ្ញុំហ្នឹងមានចំនួនប្រាំពីរគ្រួសារ។ បាទ មានអ្នកខ្លះជាប្ដីទៅប្រពន្ធ គឺថាប្រពន្ធយួនទៅ ពេលណាដល់នេះទៅប្ដីនោះខ្មែរទៅ មកយកប្រពន្ធយួនដូចរូបខ្ញុំបាទអ៊ីចឹង ប៉ុន្តែចំនួនប្រាំពីរគ្រួសារតែ ដែលគេហៅឡើងទៅលើនោះ សន្មតថាទៅទាំងអស់គ្នាបណ្ដោយ។

**ស៖** តើលោកចាំទេ មានប្ដីប្រពន្ធហ្នឹងប៉ុន្មានគូ ដែលរៀបការជាមួយគ្នា គឺប្ដីខ្មែររៀបការជាមួយប្រពន្ធវៀតណាម ប្ដីវៀតណាមរៀបការជាមួយប្រពន្ធខ្មែរ មានប៉ុន្មានគូដែរ?

**ឆ៖** បាទ អង្កាល់ដែលជំនាន់អាពតគឺគ្មានរៀបទេ។ មានតាំងពីបនជំនាន់សម្ដេច សីហនុ ម្ល៉េះហើយគ្នាក៏បានបន្ទឹមបន្ទំទៅចូលមករួមកង រួមគំនិតហ្នឹង អត់ទៅស្រុកទេស គេដេញយ៉ាងណាក៏អត់ទៅដែរ តស៊ូដូចចំពោះរូបខ្ញុំ ថាបើទៅចោលប្ដី ហើយបើខ្ញុំទៅខាងនេះ ចោលម៉ែចោលឪ ម្ល៉ោះហើយនៅសុខចិត្តស្លាប់រស់ទាំងអស់គ្នា ដែលនៅក្នុងកងខ្ញុំបាទហ្នឹងមានប្រាំពីរគ្រួសារ ដូចជម្រាបជូនអ៊ីចឹង។

[១៣:៥៨:៤៧]

**ស៖** ក្រៅពីការរៀបការចម្រុះគ្នា ចម្រុះជនជាតិគ្នាបែបនេះ តើ -- ខ្ញុំចង់ដឹងថាក្នុងចំណោមទាំងអស់ហ្នឹងមានប៉ុន្មានដែលជាប្រភេទ ប្រពន្ធវៀតណាមការជាមួយប្ដីខ្មែរ?

**ឆ៖** បាទ ខ្ញុំបាទបានដឹងតែច្បាស់ទេ ប៉ិនចំនួនគ្រួសារខ្ញុំបានដឹង ដល់ថ្ងៃហ្នឹងដែលគេហៅយកទៅហ្នឹង ខ្ញុំក៏បានឡប់សតិអស់ អត់មានគិតគូរពីតួនាទីហ្នឹងទេ ប៉ុន្តែខ្ញុំចាំច្បាស់ ដែលខ្ញុំឃើញច្បាស់នឹងភ្នែកដែលគេយកខ្ញុំផ្ទាល់ទៅ ឃើញវាប្រាំពីរគ្រួសារ តែប្ដី -- គេហៅប្រាំពីរ ប្រពន្ធនឹងវាប្រាំពីរដែរ។ ប៉ុន្តែមួយ ឧទាហរណ៍ថា វាចល័តថា ឥឡូវប្ដីខាងនេះ យកប្រពន្ធវៀតណាម ប្រពន្ធខាងនោះមកយកប្ដីខ្មែរ ខ្ញុំបានដឹងឮតែបីនាក់ទេ។

**ស៖** តើជនជាតិវៀតណាមដែលនៅលើកោះតាម៉ូវហ្នឹង ត្រូវបានកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាហ្នឹងគេកំណត់ថាជាវៀតណាមមែនទេ?

**ឆ៖** ខ្ញុំបាទគេយក*វ៉ង់សែងញ៉ីម៉ង់* ពីថ្ងៃមុន ខែមុនហើយ ឆ្នាំមុនហើយ គេដឹងថាយើងធ្វើការអីក៏ចេះតែធ្វើទៅ ប៉ុន្តែគេដឹងគោលគំនិតរបស់គេ ស្រង់ស្ថិតិហ្នឹងអស់ហើយ ថាឥឡូវមានចំនួនប៉ុននេះគ្រួសារ វាមានកូនប៉ុននេះនាក់ វាមានប្តីប៉ុននេះ មានប្រពន្ធប៉ុននេះនាក់ជាខ្មែរ មានប្តីប៉ុននេះនាក់ជាវៀតណាម។

**ស៖** តើលោកដឹងទេថា ពួកគេធ្វើយ៉ាងណាដឹងថា អ្នកណាជាជនជាតិវៀតណាម?

**ឆ៖** ហើយខ្ញុំជម្រាបជូនប្រហាក់ប្រហែលជានៅក្នុងក្រុម ក្នុងកងដែលមកពីស្រុកហ្នឹង ផ្តល់ព័ត៌មានដែលខ្ញុំបានដឹងច្បាស់ឈ្មោះតែម្នាក់ទេ គឺឈ្មោះ ដែលខ្ញុំបានដឹងច្បាស់ គឺឈ្មោះ មិត្តជុំ ដែលចេញពីស្រុក ថាអានេះវាយកប្រពន្ធវៀតណាម។ ម្ល៉ោះហើយ អ្នកដែលត្រូវបក្ខពួកហ្នឹងចង់បានដំឡូងចង់បានអង្ករហូបហ្នឹង ក៏ឲ្យព័ត៌មាននេះទៅឲ្យគេទៅ។ អាហ្នឹងស្តាប់នៅឮត្រចៀកខ្ញុំច្បាស់ហ្មង មានតែម្នាក់គត់ហ្នឹងទេ ដែលគេឲ្យព័ត៌មានទៅខាងកម្មាភិបាល ទាំងមិត្តប្រុសមិត្តស្រីទាំងអស់ហ្នឹង។ គេថា គឺរូបខ្ញុំបាទតែម្តងថា មិត្តឌឿន ហើយនិងមិត្ត ប៊ូ សំបាន ប្រាកដជា មិត្តឌឿន ខ្មែរ។ មិត្ត ប៊ូ សំបាន ជាប្រពន្ធនោះប្រាកដជាវៀតណាមហើយ។

[១៤:០១:៣៣]

**ស៖** មុននេះ លោកនិយាយថាម្តាយក្មេករបស់លោកនិយាយខ្មែរមិនច្បាស់ ហើយគាត់អានពាក្យមួយចំនួនដែលធ្វើឲ្យគេដឹងថា គាត់មិនមែនខ្មែរទេ តែជាវៀតណាម។

**ឆ៖** ពេលនោះ ដែលគេរៀបការ -- ដែលគេរាយការណ៍បន្ថែម គឺខ្ញុំបាទបានរាយការណ៍ គេពីមុនដែលគេសួរ ដល់ក្រោយទៀត មិត្តហ្នឹងបានទៅឯកភាពជាមួយអាដែងសមមិត្តហ្នឹង គេផ្តល់យកអាដែងរបស់ស៊ីហូបចុកហ្នឹង ក៏គេឲ្យគំនិតមេថា ប្រាកដហើយ គេសួរមិត្តហ្នឹងទៀត គេថាប្រាកដទេ? មិត្តហ្នឹងបានប្រាប់ថា ប្រាកដហើយ ថាប្រពន្ធជាជនជាតិវៀតណាម តែប្តីខ្មែរទេ។ ហើយខ្ញុំបាទក៏វាជាន់ពីរគ្រួត។

**ស៖** តើលោកដឹងអំពីការផ្លាស់ទីជនជាតិវៀតណាមទៅប្រទេសវៀតណាមទេ នៅពេលដែលលោកនៅកោះតាម៉ូវហ្នឹង?

**ឆ៖** ខ្ញុំបាទក៏បានឮសួរសម្តីប្រធានកងថា កម្លាំងដែលគេត្រូវប្រមូលបងប្អូនប្រជាជនវៀតណាម

ហ្នឹង ដើម្បីឲ្យធ្វើដំណើរទៅប្រទេសខ្លួនវិញហើយ។ គេក៏ប្រកាសដែរ គេប្រកាសប្រាប់ថា បើអ្នកណាចង់ទៅ ឆាប់ទៅឲ្យហើយ បាទ អ៊ីចេះ។ តែដោយសារប្រពន្ធខ្ញុំថា មិនព្រមទៅទេ នៅងាប់ជាមួយប្ដីហ្នឹង ក៏សុខចិត្តនៅងាប់មែន ដូចពាក្យដែលប្រពន្ធខ្ញុំបាទថា។

**ស៖** តើលោកមានធ្លាប់ឃើញទូក កាណូត ធ្វើដំណើរទៅទិសទៅប្រទេសវៀតណាមទេ នៅពេលដែលលោកនៅកោះតាម៉ូវហ្នឹង?

**ឆ៖** បាទ ខ្ញុំបាទជម្រាបជូន ឃើញគេប្រមូលក្នុងទូកដំបូលមួយ ដែលខ្ញុំបានឃើញភ្នែកផ្ទាល់ ដែលបរ ដែលបើកទៅតាមទន្លេ ព្រែក ដែលខ្ញុំបាទឃើញនៅសហករណ៍ខ្ញុំបាទហ្នឹង ខ្ញុំបានឃើញមួយជាក់ស្ដែងមួយមែន តែចំនួនប្រហែល២០- ៣០នាក់ តែព្រែកហ្នឹងវាមានច្រើន ចំនួនដល់បីបួនដប់ព្រែកឯណោះ មិនដឹងគេទៅប្រឡោះណាទេ ដែលគេមកពីទន្លេសាបក្ដី គេមកពីខាងកំពង់លួងក្ដី មកខាងឆ្នុកទ្រូក្ដី គេបញ្ជូនទៅតាមផ្លូវ។ តែចំពោះមុខសហករណ៍ខ្ញុំបាទហ្នឹង គឺថាមានតែមួយទេ។

**ស៖** តើលោកនិយាយថា មានមនុស្សប្រហែល២០-៣០នាក់ នៅលើកាណូតហ្នឹង តើលោកស្គាល់មុខ ឬក៏លោកចាំមុខអ្នកណាខ្លះនៅលើទូកហ្នឹងទេ?

[១៤:០៤:២០]

**ឆ៖** បាទ ដែលខ្ញុំមើលទាន់នោះ ជម្រាបជូនឲ្យច្បាស់ថា ស្គាល់តែមួយទេ គឺមិត្តអែម ដែលធ្លាប់រស់នៅពីសង្គមសីហនុ ដែលខ្ញុំបានចតផ្ទះជិត ហើយស្គាល់តែមួយនេះទេ ហើយបានចង្អុលប្រាប់ខ្ញុំថា បាយៗ គឺខ្ញុំបាទថា ប្រាកដជា បាយៗហ្នឹង ប្រាកដជាលាយើងទៅស្រុកហើយ។ ខ្ញុំក៏យប់ស្ងាត់ ខ្ញុំក៏លួចនិយាយជាមួយប្រពន្ធថា "គាត់នេះ នែ៎ឯងគេលាយើងទៅស្រុកហ្នឹង ប្រាកដជាគេមានសំណាងហើយ បើយើងនៅនេះមុខជាមានការទុក្ខសោកហើយ"។ ព្រោះខ្ញុំយល់ពីគំនិតអង្គាល់ហ្នឹង ដែលបានធ្វើអ៊ីចឹង ព្រោះខ្មែរក្រហមឃើញវៃអាដែងព្រះ ឃើញវៃស៊ីម៉ងត៍ យើងអស់ពីអ្នកហ្នឹងហើយ ព្រោះខ្ញុំកាន់ច្បាប់ព្រះពុទ្ធ តែឃើញអស់ពីហ្នឹង ខ្មែរយើងអស់ជំនឿហើយ គេអត់ជឿយើងទេ ទោះបីលើកម្រាមដៃដប់ឡើងទៅលើក៏គេអត់ជឿដែរ។

**ស៖** ឥឡូវនេះ យើងត្រឡប់ក្រោយបន្តិច ទៅនិយាយពីមនុស្សដែលលោកឃើញនៅលើទូកហ្នឹង តើពួកគាត់ហ្នឹងជាជនជាតិវៀតណាមមែនទេ?

**ឆ៖** បាទ ខ្ញុំបាទគឺស្គាល់ច្បាស់ ប្រាកដជាជនជាតិវៀតណាមទាំងអស់តែម្ដង ប៉ុន្តែខ្ញុំមើលពីចម្ងាយទៅ វាព្រិលបន្តិច បើមីមួយហ្នឹងវាពាក់អាវក្រហមបង្កង់ ខ្ញុំស្គាល់វាច្បាស់តែម្ដង។

**ស៖** តើនៅពេលដែលលោកឃើញកាណូតបើកាត់ពីមុខលោកហ្នឹង ប្រពន្ធលោកនៅក្បែរលោកទេ?

**ឆ៖** បាទ ខ្ញុំបាទជម្រាបជូន ប្រពន្ធខ្ញុំអត់បានឃើញទេ តែកំពុងគេឲ្យធ្វើត្រីប្រហុក ហើយនិងផ្អើរ អាល័យតែទៅដុតភ្លើងត្រីកែសផ្អើរហ្នឹងទៅ ខ្ញុំគ្រាន់តែប្រាប់ គេជិះផុតប្រហែលចម្ងាយប្រហែល ១គីឡូ ឬក៏៥០០ម៉ែត្រទៅហើយ។

[១៤:០៦:២៤]

**ស៖** តើលោកដឹងថា បក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយអ្វីទាក់ទងទៅនឹងការប្រព្រឹត្តចំពោះជនវៀតណាមទេ?

**ឆ៖** ដែលខ្ញុំបាទបាននៅហ្នឹង ឃើញកាកសំណល់សល់មួយដែលបញ្ជូនទៅមិនទាន់អស់ នៅពេលក្រោយបានគេបញ្ជូនទៅទៀត ឃើញគេហាមឃាត់នារីហ្នឹង ឈ្មោះ នារីអាំ បាទហើយគេប្រាប់ថា ម៉ែឪគេបញ្ជូនទៅអស់មុន នៅសល់តែមួយគេយកមកទុកនៅសហករណ៍ខ្ញុំ តែនៅដាច់ដោយឡែកពីគ្នា ហើយមិត្តកងទ័ពហ្នឹង គេប្រាប់ថា "មិត្តឯងកុំនិយាយវៀតណាមតទៅទៀត និយាយជាភាសាមួយគត់ទៅ គឺភាសាខ្មែរ។" ហើយខ្ញុំក៏បានស្ដាប់ ខ្ញុំនៅមុខរោងហ្នឹង កំពុងពុះព្រួល ពុះត្រៀមលប ដើម្បីធ្វើការដូចថារកនេសាទត្រីជូនខាងខ្មែរក្រហមហ្នឹង ហើយពួកវា ដល់ពេលស្ទាត់បន្តិច វាជជែកៗថា ជាភាសាវៀតណាមហ្នឹង ញ៉េញ៉ូរៗ គេស្ដាប់បាន គេហៅចុះមកដី ខ្ញុំស្មានតែគេហៅសួរចម្លើយ គេដោះស្រាយទៅ ស្រាប់ទៅដល់ ចាប់សក់ក្បាលបានវ៉ៃបណ្ដោយ – វ៉ៃបណ្ដោយ រំលងពីរថ្ងៃ គេចាប់បញ្ជូនទៅសេះស្លាប់ – សេះស្លាប់ចាប់បញ្ជូនទៅខាងវៀតណាមបណ្ដោយ។ កាលហ្នឹងបាត់មុខ ខ្ញុំអត់ដឹងទេ។

[១៤:០៧:៥៣]

**ស៖** តើលោកធ្លាប់ស្ដាប់ពួកម្នាភិបាលនៅកោះតាម៉ូវ ឬមួយក៏ឮតាមវិទ្យុថា ខ្មែរក្រហម គឺមានគោលនយោបាយទាក់ទងទៅនឹងការប្រព្រឹត្តចំពោះវៀតណាមដែរឬទេ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការជំទាស់ទៅនឹងសំណួរនេះ ក៏ដូចជាចំពោះសំណួរមុនៗ

មក ខ្ញុំគិតថាជាការចាំបាច់ដែរមេធាវីគាត់ត្រូវតែបញ្ជាក់ឲ្យបានច្បាស់នៅពេលដែលគាត់និយាយអំពីពេលវេលា ជាពិសេសនៅពេលដែលគាត់សួរសំណួរបែបនេះ។ ខ្ញុំឮសួរគាត់និយាយអំពីខ្មែរក្រហម ដូច្នេះ ខ្ញុំសូមកត់សម្គាល់ថា ទាល់តែដល់ខែវិច្ឆិកា ឆ្នាំ៧៧ ទើបខ្មែរ -- ទើបប៉ុល ពត បានប្រកាសជាផ្លូវការអំពីបក្សកុម្មុយនីស្តកម្ពុជា ដែលទទួលខុសត្រូវទៅលើកម្ពុជាប្រជាធិបតេយ្យ ហើយខ្ញុំក៏សូមកត់សម្គាល់ផងដែរថាមានភាពខុសគ្នាខ្លាំងនៅក្នុងពេលវេលា គឺរយៈពេលមុនពេលដែលកងទ័ពវៀតណាមជាទ្រង់ទ្រាយធំ បានវាយលុកចូលកម្ពុជានៅឆ្នាំ៧៧។ ដូច្នេះខ្ញុំគិតថា ដោយសារតែសាក្សីគាត់គ្រាន់តែជាជនស៊ីវិលសាមញ្ញ គាត់មិនអាចនិយាយអ្វីឲ្យបានច្បាស់ទាក់ទងទៅនឹងគោលយោបាយឡើយ គាត់មិនមែនជាកម្មាភិបាល ឬក៏ជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាឡើយ។ ដូច្នេះ ខ្ញុំសូមស្នើថា មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីគួរតែនិយាយឲ្យបានច្បាស់លាស់ ហើយឥឡូវនេះយើងនៅក្នុងផ្នែកមួយនិយាយអំពីអំពើប្រល័យពូជសាសន៍។ ដូច្នេះ វាគួរតែមានការបញ្ជាក់ឲ្យបានលម្អិតអំពីពេលវេលាផងដែរ សូមអរគុណ។

[១៤:១០:២០]

**កញ្ញា លីម៉ា ង្វៀន៖**

លោកប្រធាន ខ្ញុំអាចអនុញ្ញាតបន្តទៅទៀតបានទេ?

**ប្រធានអង្គជំនុំ៖**

លោក វ៉ិចទ័រ កូប៉េ គ្រាន់តែកត់សម្គាល់ទេ។ គាត់មិនជំទាស់ទេ។ អញ្ជើញ!

**សួរដោយកញ្ញា លីម៉ា ង្វៀន៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា លីម៉ា ង្វៀន៖**

**ស៖** លោក ឌឿន នៅក្នុងភស្តុតាងកន្លងមក លោកនិយាយថា ប្រពន្ធលោកនៅជាមួយលោកនៅលើកោះតាម៉ូវ ប្រហែលជាមួយឆ្នាំ។ ដូច្នេះពេលវេលាដែលយើងនិយាយក្នុងខែធ្នូ ៧៦ ដល់ ខែធ្នូ ៧៧។ តើអ៊ីចឹងមែនទេ?

**លោក ប្រាក់ ឌឿន៖**

**ឆ៖** ខ្ញុំបាទក៏ច្រឡំនូវខែដែលពិតប្រាកដ គឺខ្ញុំបានភ័ន្តច្រឡំហើយ ហ្នឹងសូមអធ្យាស្រ័យ ប៉ុន្តែរឿងហ្នឹងគឺរឿងពិតដែលខ្ញុំបានជម្រាបជូនដល់ប្រធានតុលាការ។ សូមមេត្តាអនុគ្រោះ ព្រោះខ្ញុំវាច្រឡំខែបាទ។ អារម្មណ៍ចេះតែមានការគិតគូរដល់ប្រពន្ធកូនដែលស្លាប់ទៅ។

[១៤:១១:៣១]

**ស៖** សូមអរគុណលោក ខឿន។ ក្នុងពេលដែលលោកស្នាក់នៅកោះតាម៉ូវ ហើយនៅពេលដែលប្រពន្ធលោកនៅជាមួយលោក តើលោកធ្លាប់ឮអ្វីដែលកម្មាភិបាលនិយាយ ហើយដែលពាក្យសម្ដីទាំងអស់នោះធ្វើឲ្យលោកភ័យខ្លាចអំពីជោគវាសនារបស់លោក និងជោគវាសនារបស់ប្រពន្ធលោកដែរឬទេ?

**ឆ៖** បាទ កាលថ្ងៃមួយនោះ ខ្ញុំបានកំពុងធ្វើការ ប្រពន្ធកូនខ្ញុំអត់ទាន់បានដឹងទេ តែកងទ័ពវៀត-ណាមហ្នឹង សហករណ៍ខ្ញុំបាទវាមានទឹកផង វាមានគោកផង ហើយកងទ័ពដើរធ្វើការហ្នឹងវាមានវ៉ាដ្យូស្ពាយនឹងស្មា។ ដល់ឮស្គរវ៉ាដ្យូហ្នឹង ផ្សាយអ៊ីចឹងប្រាប់ថា វារកជនជាតិវៀតណាមស៊ីរូងផ្ទៃក្នុង។ ហើយខ្ញុំវាជជែក ប៉ុន្តែក្នុងវ៉ាដ្យូខ្ញុំអត់បានច្បាស់ទេ ប៉ុន្តែឮវាជជែកក្រៅអ៊ីចឹង ហើយខ្ញុំក៏មានការចាប់អារម្មណ៍វាអត់និយាយហ្នឹងប៉ះពាល់ដល់ខ្ញុំទេ ប៉ុន្តែមានការចាប់អារម្មណ៍ព្រួយអ៊ីចឹងហ្នង។ ហើយខ្ញុំបាទក៏នឹកឃើញថា អូ៎! ប្រហែលជាគេប្រមូលអស់ហើយវៀតណាមទាំងអស់ ហើយប្រពន្ធខ្ញុំបាទក៏បានដឹងៗដោយខ្ញុំប្រាប់ផង ហើយគេអ្នកក្រៅក៏និយាយប្រាប់ផង – ថា "ប្រាកដគេយកវៀតណាមស៊ីរូងផ្ទៃក្នុងប្រមូលអស់ហើយ ត្រង់មិនដឹងថាមានពីរច្រក ថាមួយច្រកក៏សម្លាប់ ឬក៏មួយច្រកទៀតគេបញ្ជូនទៅស្រុកកំណើតវិញ"។

**ស៖** តើលោកស្ដាប់ឮវ៉ាដ្យូ ស្ដាប់ឮវិទ្យុដែលគេផ្សព្វផ្សាយហ្នឹង គេប្រើពាក្យអ្វីឲ្យជាក់លាក់លោកចាំទេ?

**ឆ៖** ខ្ញុំបាទជម្រាបជូនអត់ជាក់លាក់ទេ ប៉ុន្តែវាស្ពាយហ្នឹងឮស្គរតែកោកៗ ស្ដាប់មិនបាន ដល់វាមិត្តហ្នឹងជជែកខ្លួនឯងថា តាឯងប្រុងប្រៀបទៅក្នុងសហករណ៍ ហើយក្នុងមូលដ្ឋានទាំងអស់គេប្រមូលជនជាតិវៀតណាមហើយ ត្រង់តែថាវៃសម្លាប់ មិនវៃសម្លាប់អត់និយាយទេ ប៉ុន្តែគេប្រមូលហើយ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរចុងក្រោយអម្បាញ់មិញនេះ ដោយសារលោកស្រីមេធាវីបញ្ជាក់ថា សាក្សីបានឮពីវិទ្យុ ហើយបាន -- តាមសក្ខីកម្មដែលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបាននិយាយនោះ គឺគាត់មិនបានស្ដាប់ឮពីវិទ្យុដោយផ្ទាល់ទេ គឺគាត់ស្ដាប់ឮការជជែកគ្នារបស់កម្មាភិបាលដែលមានវិទ្យុ ដែលគាត់ថា តាមដែលការជជែកគ្នាហ្នឹង គឺដូចជាឮតាមវិទ្យុនិយាយ

ថា ស្វែងរកវៀតណាមដែលស៊ីរូងផ្ទៃក្នុង។ បាទ ដូច្នេះដែលសំណួរថា គាត់ហ្នឹងស្ដាប់ឮតាមវិទ្យុដោយផ្ទាល់ និយាយបែបណានោះ គឺមិនត្រឹមត្រូវទេ បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញតទៀត បាទ។

**សួរដោយកញ្ញា លីម៉ា ង្វៀន៖**

លោកចៅក្រម គឺថាភស្ដុតាងបានបញ្ជាក់ថា គាត់ឮការប្រកាសនៅតាមវិទ្យុអំពីការស៊ីរូងផ្ទៃក្នុងរបស់វៀតណាម។ ហើយបន្ទាប់មកទៀត មានសមមិត្តដែលនៅជុំវិញបាននិយាយប្រាប់ថា គេត្រូវប្រមូលជនជាតិវៀតណាម។ នេះគឺជាភស្ដុតាងដែលខ្ញុំស្ដាប់ឮពីសាក្សីរូបនេះ។ ប៉ុន្ដែប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីអាចបញ្ជាក់ សូមឲ្យលោកជួយបញ្ជាក់បំភ្លឺបន្ដិច។

**ស៖** លោក ឌឿន តើលោកអាចបញ្ជាក់បានទេ ថាមុននេះលោកនិយាយថាម៉េចទាក់ទងទៅនឹងអ្វីដែលលោកស្ដាប់ឮនៅក្នុងវិទ្យុ ហើយនិងអ្វីដែលកើតឡើងនៅពេលក្រោយមកទៀត?

**លោក ប្រាក់ ឌឿន៖**

**ឆ៖** ហើយខ្ញុំបាទក៏ជម្រាបជូនដែរថា ធ្វើដំណើរទៅ ខ្ញុំបាទក៏ឈប់មាត់ ឈប់ក ហើយកងទ័ពហ្នឹងក៏ត្រូវដើរហួសទៅ – ដើរហួសទៅប្រពន្ធកូនខ្ញុំត្រូវមានការចាប់អារម្មណ៍គាត់ដែរ។ ដល់ពេលយប់ស្ងាត់ដែលរួមដំណេកជាមួយគ្នា គាត់ក៏ឲ្យយោបល់ខ្ញុំថា គាត់ឯងសង្ស័យតែមុខជាព្រាត់ប្រាសគ្នាហើយខ្ញុំមើលទៅបើមិនទៅវៀតណាម មុខតែគេសម្លាប់ខ្ញុំហើយ។ ហើយខ្ញុំក៏មានសេចក្ដី ដូចថារន្ធត់ស្លុតស្មារតីហ្នឹងគិតគូរពីបញ្ហាហ្នឹង ប៉ុន្ដែមិនឲ្យប្រពន្ធដឹងទេ ក្នុងគំនិតអីដែលគិតគូរប្រហែលជាអ៊ីចឹងមែនហើយប្រាកដដែលក្នុងគំនិតខ្ញុំបែងចែកទៅ ប្រាកដជាប្រពន្ធទៅចោលខ្ញុំ ឬក៏មួយក៏គេយកទៅសម្លាប់ហើយ។ ដល់ពេលនោះមែន ដែលខ្ញុំគិតឃើញខ្ញុំអត់បានទៅជម្រាបជូនប្រពន្ធតទៅទៀតទេ គ្រាន់តែប៉ុណ្ណឹងខ្ញុំមានគំនិតទុក កុំប្រពន្ធភ័យញាប់ញ័រ។ ហើយមិននឹកស្មាន ដល់ពេលគេយកទៅគឺមែនយកទៅទាំងប្ដីទាំងប្រពន្ធមែន។

[១៤:១៦:៣៤]

**ស៖** ឥឡូវនេះ ខ្ញុំចង់និយាយអំពីថ្ងៃចុងក្រោយដែលលោកបានជួបប្រពន្ធរបស់លោក។ តើលោកពន្យល់បានទេ ថាមុនពេលដែលលោកបែកពីប្រពន្ធលោកនៅថ្ងៃហ្នឹង មានអ្វីកើតឡើងខ្លះ?

**ឆ៖** ហើយខ្ញុំបាទ ក៏ចង់សួរសំណួរថាសួរខ្ញុំបាទនេះគឺថា សួរពីដែលខ្ញុំបែកពីពេជចង្វារមក ឬក៏

សួរថាខ្ញុំនៅក្នុងបន្ទុកគ្រួសារនៅក្នុងសហករណ៍តែមួយ? សូមមេត្តាអត់ទោស។

**ស៖** ខ្ញុំចង់សួរលោកអំពីពេលដែលលោកនៅលើកោះតាម៉ូវទាំងពីរនាក់ ហើយនិងថ្ងៃចុងក្រោយ គឺថ្ងៃចុងក្រោយដែលលោកនៅជាមួយប្រពន្ធរបស់លោកនៅកោះតាម៉ូវហ្នឹង។ តើលោកអាចរៀបរាប់បានទេ?

**ឆ៖** ដែលខ្ញុំបាទគឺថាបានមករួមរស់ជាមួយប្រពន្ធកូននៅកោះតាម៉ូវហ្នឹង គឺគេបែងចែកជាកម្លាំងរួមហើយ គេឲ្យប្រពន្ធខ្ញុំបាទដាំចម្ការ ខ្ញុំបាទចាត់ចែងនៅធ្វើព្រែកឡូត៍ភូមិហ្នឹងទៅផ្នែកនេសាទត្រី។ ហើយខ្ញុំបាទក៏មានការចាប់អារម្មណ៍ដែរ ចេះតែគិតចេះតែគួរ ចេះតែបែងចែកថាប្រាកដជាប្រពន្ធហ្នឹងបែកពីខ្ញុំហើយក្នុងពេលហ្នឹង ប៉ុន្តែខ្ញុំអត់ឲ្យយោបល់ទៅលើគេទេ តែៗចោទប្រកាន់ថាអី ខ្មែរក្រហមថាអី គឺអត់មានទេ តែនិយាយតែពេលដែលខ្ញុំជម្រាបជូនខាងដើម គេមានតែថាតែប៉ុណ្ណឹង គេឈប់ទៅ គេដើរចោលទៅ ហើយខ្ញុំបាទពីរនាក់ប្ដីប្រពន្ធហ្នឹងចេះតែលួចគិត លួចគួរ មិនហ៊ាននិយាយទេ បើនិយាយពាក្យធំខ្លាចគេចាប់យកទៅវ៉ៃចោលទៀត ព្រោះអង្កាល់នៅជំនាន់ហ្នឹង គេអត់ឲ្យមានយើងនិយាយពិគ្រោះគ្នាតមួយទៅមួយទេ តែគេស្ដាប់បានគេហៅយើងទៅហើយ តែហៅយើងទៅ យើងប្រាកដជាស្លាប់ហើយ។

[១៤:១៨:៣៣]

**ស៖** តើលោកឃើញប្រពន្ធលោកនៅចុងក្រោយហ្នឹងនៅពេលណាដែរ?

**ឆ៖** បាទ ខ្ញុំបាទគឺបានឃើញជួបជុំជាមួយប្រពន្ធកូនដូចថាធ្វើការថ្ងៃ យប់ឡើងបែងចែកមករួមដំណេកជាមួយគ្នាហ្នឹង មានការគិតគួរ បាទ ខ្ញុំបានការគិតគួរ។ បញ្ហាទី១ គឺគិតអត់ពីស្បៀងដែលយើងហូបចុកគ្រប់គ្រាន់។ បញ្ហាទី២ ដែលកូននៅតាមសហករណ៍ ម្ដាយហ្នឹងលួចព្រួយចិត្ត ថាសុខចិត្តឲ្យស្លាប់វាមុនចុះ កុំឲ្យកូនស្លាប់មុន។ ប្រពន្ធខ្ញុំបាទហ្នឹងបាននិយាយស្មោះត្រង់ថា គិតគួរពីរឿងបញ្ហាកូនហើយឮដំណឹងកូនបងហ្នឹង គឺបានស្លាប់មួយទៅហើយ នៅសល់កូនប្រាំទៀត។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមលោកប្រធានជួយអន្តរាគមន៍ដោយណែនាំដើមបណ្ដឹងរដ្ឋប្បវេណីឲ្យឆ្លើយត្រូវទៅនឹងសំណួរ។ តាមខ្ញុំស្ដាប់មើលក្នុងរយៈពេលប៉ុន្មានសំណួរចុងក្រោយនេះគឺចម្លើយរបស់គាត់មិនស៊ីគ្នាទៅនឹងសំណួរទេ។ ដូច្នេះធ្វើឲ្យមិនមានប្រយោជន៍អ្វីសម្រាប់ការស្វែងរកការ

ពិតនេះបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយដើមបណ្តឹងរដ្ឋប្បវេណីស្តាប់សំណួរឲ្យបាន យើងបានប្រាប់តាំងពីដើមទីមក គឺលោកត្រូវប្រើប្រាស់ពេលវេលាដែលគម្លាតគ្នារវាងប៊ូតុងដែលនឹងប្រតិបត្តិការនេះ ដើម្បីស្តាប់សំណួរឲ្យបាន ហើយនិងលោកផ្តល់នូវចម្លើយរបស់លោកដើម្បីឲ្យតបទៅនឹងសំណួរដែលភាគីសួរ។ យើងបានជម្រាបលោកតាំងពីព្រឹកមិញម្ល៉េះ។ បាទ សូមអញ្ជើញបន្តទៀត!

**កញ្ញា លីម៉ា ង្វៀន៖**

លោកប្រធាន នៅព្រឹកនេះ កូនក្តីរបស់ខ្ញុំមានសម្ពាធឈាមគាត់ឡើងខ្ពស់ ដូច្នេះ ខ្ញុំសូមអនុញ្ញាតលោកប្រធាន តើលោកប្រធាន អាចសួរគាត់ថាគាត់អាចបន្តទៅមុខទៀតបាន ឬមួយក៏យ៉ាងម៉េចដែរ សូមលោកប្រធានមេត្តាអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅលោក ប្រាក់ ឌឿន តើលោកអាចបន្តការផ្តល់សក្ខីកម្មបានដែរឬទេ -- បានបន្តទៅទៀតដែរឬទេ? ពីព្រោះព្រឹកមិញយើងបានប្រាប់ហើយថា ដឹងថា អង្គជំនុំជម្រះដឹងថាលោកមានបញ្ហាសុខភាពដែរ ប៉ុន្តែខាងគ្រូពេទ្យបានផ្តល់ព័ត៌មានតាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញមកថាលោកដំបូងមានស្ថានភាពអ៊ីចឹងមែន ប៉ុន្តែក្រោយមកគឺស្ថានភាពល្អប្រសើរអាចផ្តល់សក្ខីកម្មបាន។ ប៉ុន្តែអង្គជំនុំជម្រះបានជម្រាបលោកហើយ គឺផ្តល់លទ្ធភាពឲ្យលោក ថាបើសិនជាមានបញ្ហា លើកដៃសុំការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីឈប់សម្រាក ក្នុងការផ្តល់សក្ខីកម្មមួយរយៈខ្លី ឬក៏មួយរយៈវែង តាមស្ថានភាពនៃសុខភាពរបស់លោក។ ឥឡូវនេះ តើលោកអាចបន្តផ្តល់សក្ខីកម្មតទៅទៀតបានដែរឬទេ?

**លោក ប្រាក់ ឌឿន៖**

បាទ ខ្ញុំបាទ ជម្រាបជូនហើយ គ្រូពេទ្យក៏បានឲ្យខ្ញុំធ្វើកាយវិការ ហើយនិងឲ្យថ្នាំខ្ញុំបាទលេបហើយនិងវាស់ឈាម។ បានន័យថា ពីព្រឹកវាស់ទៅឃើញ១៩ ដល់ថ្ងៃបន្តិចទៅចូលឲ្យវាស់ម្តងទៀតមាន ១៩ --អ៎! ១៤ ដល់វាស់អំមិញនេះ ឡើង១៥វិញ ក៏ឲ្យផឹកថ្នាំមួយគ្រាប់។ តែដំណើរការនេះ ខ្ញុំបាទគឺជម្រាបជូន បន្តវេនបន្តិចទៅទៀតបាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ ហើយសូមអញ្ជើញបន្តទៀតលោកស្រីមេធាវី។

[១៤:២២:២៨]

**សួរដោយកញ្ញា លីម៉ា ង្វៀន៖**

**ស៖** លោក ឌឿន លោកបាននិយាយថា ប្រពន្ធលោកនៅជាមួយលោកនៅលើកោះតាម៉ូវ ប្រហែលជានៅក្នុងខែធ្នូ ៧៦ ដល់ខែធ្នូ ៧៧។ តើមានអ្វីកើតឡើងចំពោះប្រពន្ធលោកនៅពេលនោះ?

**លោក ប្រាក់ ឌឿន៖**

**ឆ៖** ខ្ញុំបាទជម្រាបជូន នៅក្នុងឆ្នាំដែលលោកប្រធានតុលាការហ្នឹងបានជូនដំណឹងមកឲ្យខ្ញុំ ខ្ញុំបាទក៏ជម្រាបជូនទៅវិញថា ខ្ញុំអត់បានចាំពិតប្រាកដទេ។ សូមលោកអធ្យាស្រ័យដល់ខ្ញុំបាទផងបាទ។

**ស៖** តើលោកអាចប្រាប់បានទេថា មានអ្វីកើតឡើងចំពោះប្រពន្ធលោកនៅថ្ងៃចុងក្រោយ គឺនៅថ្ងៃចុងក្រោយដែលលោកបានជួបគាត់ហ្នឹង មានអ្វីកើតឡើង?

**ឆ៖** ដែលខ្ញុំបានជម្រាបជូនដូចគ្មានអ្វីកើតឡើងទេ។

**ស៖** តើកម្មាភិបាលនៅលើកោះតាម៉ូវហ្នឹង គេមានវិធានការអ្វីដែរ ចំពោះការរៀបការចម្រុះជាតិសាសន៍បែបនេះ?

**ឆ៖** គេអត់បន្ទោសខ្ញុំបាទទេ គេបន្ទោសជំនាន់ដែលកម្មាភិបាលដែលនៅជាមួយជាប់ខ្ញុំផ្ទាល់ គឺគេបន្ទោសទៅសម្តេចសីហនុថា កាលហ្នឹងដែលម៉េចតែយើងធ្វើអាដែង ដូចថា ពេលយើងការរួច យើងរៀបមង្គលការរួចយើងធ្វើ ដូចថា អីមួយដែលយើងចុះនេះ ចុះអេតាស៊ីវិលអីជាមួយប្តីប្រពន្ធនោះ គាត់ក៏មិនមាននិយាយពោលអ៊ីចឹង ពួកគាត់មិនគិតពីរឿងតួនាទីខ្មែរកុំឲ្យយកខ្មែរ ម៉េចទៅឲ្យទៅយកជនជាតិវៀតណាមវិញបាទ។

[១៤:២៤:៤៥]

**ស៖** តើកម្មាភិបាលនៅលើកោះតាម៉ូវហ្នឹងគេមានបំបែកប្តីប្រពន្ធដែលរៀបការចម្រុះជាតិសាសន៍ហ្នឹងចេញពីអ្នកដទៃទៀតទេ ឬមួយក៏គេឲ្យនៅជាមួយគ្នា?

**ឆ៖** ខ្ញុំបាទ គ្រួសារខ្ញុំបាទគឺនៅជួបជុំជាមួយគ្នា ដល់គ្រួសារដែលប្រាំមួយគូទៀតហ្នឹង គេចល័ត គេចល័តថា បើប្តីនៅធ្វើព្រៃក ប្រពន្ធនៅធ្វើចម្ការ តែបែកគ្នា ប៉ុន្តែបែកគ្នាក្នុងរវាងជិតទេ អត់ឆ្ងាយទេ។ ឧបមាថា នៅស្រុកលើអ៊ីចឹង ឬមួយក៏នៅពាក់កណ្តាលចម្ការ ព្រោះផែនការដែលវាឲ្យធ្វើនុំង វាមានបីផ្នែក។ ទី១ នេសាទត្រី ទី២ ចម្ការ ទី៣ ដាំស្រូវស្រែពីរដងបាទ។ ជួនកាលអ្នកខ្លះទៅក៏ចល័តទៅ ប្តីនៅធ្វើការនេះទៅ ហើយអ្នកខ្លះទៀតនោះក៏ទៅដាំចម្ការទៅ។ ខ្ញុំបាទជម្រាបជូនវាមានបីផ្នែក។

**ស៖** តើលោកធ្លាប់បែកពីប្រពន្ធពីប្រពន្ធរបស់លោកទេ នៅក្នុងឆ្នាំ៧៧?

**ឆ៖** បាទ ខ្ញុំធ្លាប់បែកអស់រយៈកាលជាង១ឆ្នាំ ដូចខ្ញុំបានជម្រាបជូនខាងដើមហើយ។

**ស៖** តើលោកនៅក្នុងចុងឆ្នាំ៧៧ ហ្នឹង តើលោកបែកគ្នាជាចិរន្ត្រៃយ៍ ឬមួយក៏គ្រាន់តែបែកគ្នាមួយភ្លែតៗទេ?

[១៤:២៦:២៨]

**ឆ៖** បាទ បែកហ្នឹងធ្វើការងារ ដូចថា បែកពីថ្ងៃទៅ ដល់ពេលព្រលប់ទៅយើងជួបគ្នាវិញ។ ដល់ពេលព្រលប់ហ្នឹង គេចាប់ខ្ញុំទៅទស់ព្រួលទោះអីទៅ ប្រពន្ធក៏ដេកទៅ។ បែកក្នុងរយៈពេលខ្លី។

**ស៖** លោក ឌឿន តើលោកអាចប្រើបានទេថា តើនៅថ្ងៃដែលលោកឃើញប្រពន្ធលោកជាលើកដំបូងនោះ តើវាមានលក្ខណៈបែបណាដែរ?

**ឆ៖** ខ្ញុំសួរអីចឹងដូចជាឆ្ងល់ដែរ។ សូមសំណូមពរសួរ ជួយបញ្ជាក់ម្ដងទៀតបាទ។

**ស៖** លោកនិយាយថា ប្រពន្ធរបស់លោកត្រូវបានគេសម្លាប់នៅក្នុងរបបខ្មែរក្រហម តើលោកអាចពន្យល់បានទេ ថាមានអ្វីកើតឡើងនៅថ្ងៃចុងក្រោយដែលលោកបានជួបប្រពន្ធរបស់លោកនៅលើកោះតាម៉ូវហ្នឹង?

**ឆ៖** ជម្រាបជូនថា បញ្ហាដែលប្រពន្ធកូនដែលត្រូវចុងក្រោយគេ កិច្ចបង្ហើយហ្នឹង គឺថាបានរៀបរាប់ដំណើរ នៃកម្មាភិបាលហ្នឹង ឲ្យខ្ញុំបាទហ្នឹង គឺថាថ្ងៃហ្នឹងវាអត់ប្រាប់មុនទេ ដល់ថ្ងៃហ្នឹងវាត្រូវតែប្រាប់តែម្ដង ថ្ងៃដែលបញ្ជូនឈ្មោះទៅលើហ្នឹង។ ខ្ញុំបាទក៏តាំងចិត្តស្មានថា គេតែប្រពន្ធខ្ញុំទៅម្នាក់ ហើយបាទក៏ធ្វើហីទៅ ដល់បន្តិចទៀត អាប្រធានកម្មាភិបាលគេមកប្រាប់ថា "ទេ ទៅទាំងប្ដីប្រពន្ធ" ហើយខ្ញុំបាទក៏ថា គិតថា អីចឹងទៅតែមួយគ្រួសារខ្ញុំ? អត់ទេ។ ដល់គេហៅគ្រួសារដែលមានសាច់ញាតិដែលថា មានប្ដីខ្មែរ ប្រពន្ធវៀតណាម មានប្រពន្ធវៀតណាមប្ដីខ្មែរអីចឹងគេឲ្យទៅទាំងអស់។ ដល់ខ្ញុំរាប់ទៅវាមានប្រាំពីរគ្រួសារ។ អីចឹងខ្ញុំចាប់អារម្មណ៍ជាមួយប្រពន្ធកូនខ្ញុំ ក៏ឈប់និយាយស្ដីតាំងយំរហូតតែម្ដង អត់និយាយជាមួយខ្ញុំទេ ពេលណាដែលវាហៅធ្វើដំណើរ។ តែមុននឹងធ្វើដំណើរទៅ ក៏វាអត់វ៉ៃ អត់ជេរ អត់ច្រំ អត់ធ្វើបាបអីទេ ធ្វើតាមសម្រួលយើងដើរទៅ បើល្ងើយវាឲ្យឈប់តាមថ្នក តាមត្រពាំង ប៉ុន្តែទៅពេលយប់។ បាទ ជម្រាបជូនថាទៅពេលយប់។ ហើយឲ្យខ្ញុំបាទបន្តវេនទៅបានឬអត់?

**ស៖** បាទ សូមអញ្ជើញ!

[១៤:២៨:៥៦]

**ឆ៖** ហើយខ្ញុំបាទជម្រាបជូនបន្តទៀត។ ដល់ទៅពេលយប់ហ្នឹង ទៅដល់កន្លែងដែលកើតហេតុហ្នឹងវាឲ្យខ្ញុំបាទហ្នឹង គឺថានៅមួយកន្លែងសិនៗ ខ្ញុំក៏ -- ខ្ញុំបាទក៏បានសួរមិត្តយើងថា "ឲ្យខ្ញុំនៅហ្នឹងយ៉ាងម៉េចដែរ?" ថា "ខ្ញុំមិត្តឯងនៅមួយចំនួន ប្រមូលគ្នាជុំនៅត្រង់ដែលគេហៅថា កន្លែងហ្នឹងគេហៅថា ទួលរកា មេលំ ទួលរកាបាទ ដែលកន្លែងគេយកទៅធ្វើទារុណកម្មនោះ យកទៅសម្លាប់នោះ។ ហើយខ្ញុំក៏បានសួរតែមួយមាត់ ខ្ញុំបាទក៏អត់ហ៊ានសួរទៀត ព្រោះកាំភ្លើងហ្នឹងឃើញជាប់ដៃទាំងអស់គ្នាហើយ។ ហើយៗខ្ញុំត្រង់វាថាប្រមាថកាតទានក៏អត់មានថាដែរ ហើយវាជម្រាបមកជូនខ្ញុំបាទហ្នឹងគឺថា "ខ្ញុំហៅអ៊ំឲ្យមកនេះ អ៊ំឯងកម្លាំងនេះ ត្រូវរែស្រូវ ទៅបោកស្រូវ។ កម្លាំងដែលខាងគ្រួសារអ៊ំឯងនេះ ទៅខាងផ្នែកដាំដំណាំ ហើយចុះខាងនោះ? ចុះអាប្រុសខាងនោះក៏គេហៅ។ ខ្ញុំចាប់អារម្មណ៍ មានការគិតអ៊ីចឹងគឺថាចុះវាហៅអីហៅតែខ្ញុំម្នាក់ដែលជាប្រពន្ធវៀតណាម ហើយចុះអាគេនោះ គេអត់ឲ្យទៅ គេឲ្យប្រពន្ធវៀតណាមនោះ -- អ៎! ប្រពន្ធខ្មែរមកខាងខ្ញុំវិញ ហើយខ្ញុំចេះតែគិតអ៊ីចឹង។ ស្រាប់តែអត់អីទេ អ៊ំឯង។ ដល់កន្លែងមួយមួយទៀត ខ្ញុំក៏បានសួរវាថា៖ "ចុះកូនរបស់ខ្ញុំអាពៅហ្នឹង ខ្ញុំសូមឲ្យទៅនៅជាមួយខ្ញុំទៅ ឲ្យម៉ែវាធ្វើការទៅ? អ៊ូ! គេមិនបាច់ទេ នាំអ៊ំឯងយកទៅ -- អ៎! មិត្ត -- អ៊ំឯងយកទៅវេទនាហើយ កូនវាយំវាស្រែក ឲ្យវាទៅជាមួយម៉ែវាទៅ ហើយនិងឲ្យកូនទៅខាងអាដែងម្ដាយខ្មែរទៅវិញ"។ បានខ្ញុំថា អ៊ូ! ខ្ញុំនឹកស្មានខ្លួនខ្ញុំថា អានេះម្ដាយខ្មែរ គេទុកឲ្យកូនរស់ ដល់ប្រពន្ធខ្ញុំបាទវៀតណាមហ្នឹង កូនទៅជាប់ជាមួយម្ដាយបាទ។ ហើយក្រោយពីពេលហ្នឹង ខ្ញុំជម្រាបជូនបញ្ជាក់ច្បាស់ថា ពេលហ្នឹងគាត់ទៅផុត បែងចែកគេអស់ទៅ មួយសន្ទុះទៀត ស្រាប់តែប្រធានកងហ្នឹងដើរទៅ ខ្ញុំកំពុងតែបោកស្រូវ ឮពោលថា "អ្នើស! គ្រួសារគេកម្ទេចអស់ហើយ"។ បាទ ដល់ព្រឹកឡើង បានខ្ញុំដឹងថា ពាក្យ "កម្ទេចអស់ហើយ" អាកូនហ្នឹងវាបានប្រាប់ថា គេលើកឡើងទៅលើ គេរងនឹងចំពុះទុង ចាក់យកបណ្ដោយ បាទ។ យំគ្មានដឹងទេ មិនដឹងជាឈាមយ៉ាងណា។ សូមមេត្តាជួយក្នុងការផ្នែកចាប់អារម្មណ៍អាហ្នឹង ខ្ញុំនៅមានស្មារតីតក់ស្លុតណាស់ សូមមេត្តាអត់ទោស បាទ។

[១៤:៣១:២៣]

**ស៖** លោក ឌឿន លោកបាននិយាយថា គេប្រមូលផ្ដុំគ្រួសារដែលរៀបការចម្រុះជាតិសាសន៍ហ្នឹង គឺមានប្រាំពីរគ្រួសារ។ ដូច្នេះខ្ញុំចង់សួរថា ពួកគេប្រមូលគ្រួសារដែលរៀបការចម្រុះពូជសាសន៍ហ្នឹង នៅពេលណាដែរ?

**ឆ៖** ហើយខ្ញុំបាទជម្រាបជូនថា គឺខ្ញុំពេលហ្នឹង ខ្ញុំដូចវាភ្លេចស្មារតីមិនដឹងជាខែណាទេ ប៉ុន្តែខ្ញុំ

បាទចាំទឹក។ ចាំទឹកដែលទឹកស្រកហ្នឹង មិនដឹងជាខែណា ខ្ញុំបាទអត់ច្បាស់ហ្នុង។ សូមបញ្ជាក់មេត្តាអត់ទោសបាទ។

**សៈ** ខ្ញុំនិយាយអំពីពេលវេលា នៅពេលដែលគេប្រមូលផ្តុំគ្រួសារ តើលោកដឹងទេ ថានៅពេលណា? នៅពេលព្រឹក ឬក៏ពេលថ្ងៃ?

**ឆៈ** ទៅហ្នឹង គឺពេលល្ងាច ប្រហែលជាម៉ោងប្រាំមួយ។ ម៉ោងប្រាំកន្លះគេចាប់ប្រមូល ម៉ោងប្រាំមួយធ្វើដំណើរទៅ។ ដើរទៅតាមដងផ្លូវ មានថ្លុកត្រពាំង បឹងបួហ្នឹង កាលណាហត់ទៅ វាឲ្យដេកនៅហ្នឹងទៅ ប្រហែលជាមួយម៉ោង ពីរម៉ោង វាហៅក្រោកទៅវិញ ទៅតទៅទៀត។ ព្រោះថ្លុកតាមផ្លូវហ្នឹងមានពីរបី។ ថ្លុកក្របី ថ្លុកតូចធំហ្នឹង មាន។ ដល់វាល្ងើយទៅ វាអត់បាយស៊ីអីផងហ្នឹង ទៅហ្នឹងអត់បាយទេ អត់មានបាយហូបទេ។ ទៅដល់ពាក់កណ្តាលផ្លូវហ្នឹង ក៏វាហត់ហេវ ក៏ដេកនឹងមួយសន្ទុះទៅ វាថា ហ៎! ងើប ក៏ងើបទៅតាមវាទៅ។ ទៅដល់កន្លែងសន្មតដែលវាវ៉ៃ បញ្ចប់អត់មាននិយាយថាអីទៀតទេ។

[១៤:៣៣:១៣]

**សៈ** តើលោកដើរអស់រយៈពេលប៉ុន្មានដែរ មុនពេលដែលលោកឈប់សម្រាក?

**ឆៈ** បាទ ខ្ញុំធ្វើដំណើរទៅ ផ្លូវនៅតាមដែលខ្ញុំបានប៉ាន់ស្មាន វាមិនកំណត់ទេ ខ្ញុំស្មានទៅប្រហែលបួន ប្រាំ ១០គីឡូទៅ។ បាទ ខ្ញុំដើរប្រហែលជាប្រាំមួយ ប្រាំពីរគីឡូ ខ្ញុំបានទៅសុំមិត្តសម្រាកសិន មិត្តអើយល្វើយណាស់។ វាក៏អត់ថាបង្ខំអីដែរ។ វាសម្រាកអី ក៏សម្រាកទៅ ធ្វើអី-- ប៉ុន្តែមិត្តហ្នឹងមានតែពីរនាក់ទេ នារីម្នាក់ ហើយនិងក្មេងកុមារប្រហែលជាអាយុ១៤ម្នាក់។ នារីនោះប្រហែលជាអាយុ១៨ ហើយមានរំពាត់ ប៉ុនអត់មានវ៉ៃមានដំច្រំផាក់ ក៏អត់មានស្តីបន្ទោសដែរ។ ចង់ដើរ ដើរទៅ ប៉ុន្តែវាកៀងដូចកៀងគោអ៊ីចឹង។ ត្រង់ណាវាឲ្យឈប់ ឈប់ទៅ។ វាថាតែមួយម៉ាត់អ៊ីចឹង។ វាអត់មានប្រើពាក្យយោធា គំរាម វ៉ៃ ជេរអីទេ អត់សោះ។ បាទ ហ្នឹងនិយាយតាមការពិត។

**សៈ** លោកបានឆ្លើយថា មានគ្រួសាររៀបការចម្រុះជាតិសាសន៍ហ្នឹង ប្រាំពីរគ្រួសារនៅក្នុងពេលធ្វើដំណើរហ្នឹង តើលោកអាចបញ្ជាក់បានទេ បើគិតចំនួនមនុស្សវិញ ទាំងប្រាំពីរគ្រួសារហ្នឹង មានទាំងអស់ចំនួនប៉ុន្មាននាក់?

[១៤:៣៤:៣៦]

**ឆៈ** មានចំនួនប្រាំពីរនាក់ដែរ។ បើថាអ៊ីចឹង បានខ្ញុំថាប្រាំពីរគ្រួសារ វានៅទាំងប្តីប្រពន្ធទាំងអស់ មិនទាន់អ្នកណាបាត់បង់នៅឡើយ។ អ៊ីចឹងប្រាំពីរនាក់ខ្មែរ ប្រាំពីរនាក់វៀតណាម។ បើប្តី -- ប្រពន្ធ

វៀតណាមមួយគូៗអ៊ីចឹង ប៉ុន្តែកូនខ្ញុំបាទអត់ចាំពិតប្រាកដទេ រឿងកូន មិនដឹងជាក្នុងម្នាក់មានកូនប៉ុន្មាន ស្លាប់ប៉ុន្មាន រស់ប៉ុន្មាន ខ្ញុំបាទក៏អត់ដឹងទេ។ ប៉ុន្តែកូនហ្នឹងត្រូវជាប់មួយពីរនាក់ កូនខ្ញុំបាទមួយ និងកូនអ្នកដទៃមួយទៀត ប៉ុន្តែម្តាយវាខ្មែរ ឪវាវៀតណាម គេទុកឲ្យកូនខ្មែរហ្នឹងដែរ។ ចំណែកខ្ញុំបាទ គេយកកូនខ្ញុំបាទទៅខាងម្តាយវា។ ខ្ញុំបាទគេឲ្យដើរខ្លួនទទេ។

**ស៖** ដូច្នេះកូនប្រុសរបស់លោកនៅជាមួយលោក។ ចុះម្តាយក្មេករបស់លោកនៅឯណាដែរ នៅជាមួយលោកឬ?

**ឆ៖** ចំណែកម្តាយក្មេកខ្ញុំទៅរួមដំណើរជាមួយគ្នាទាំងប្រពន្ធកូន ដែលកូនថាមួយឆ្នាំកន្លះហ្នឹងទៅរួមដំណើរបើរាប់ជាឈ្មោះដែលត្រូវទៅហ្នឹង វាមានបួននាក់ ខ្ញុំបានម្នាក់ កូនខ្ញុំម្នាក់ ប្រពន្ធខ្ញុំម្នាក់ និងម្តាយក្មេកម្នាក់។

**ស៖** នៅត្រង់ចំណុចមួយតាមផ្លូវដែលលោកបានឈប់ ក្រោយពីលោកបានដើរប្រមាណពី៥ទៅ៦គីឡូម៉ែត្រ តើមានអ្វីកើតឡើងចំពោះលោក?

**ឆ៖** បាទ ពេលនោះដែលខ្ញុំធ្វើដំណើរគ្មានអ្វីកើតឡើងទេ អត់មានដូចថាចោទប្រកាន់លើមិត្តណាមួយ ហើយមិត្តក៏ចោទប្រកាន់មកលើខ្ញុំបាទក៏អត់មានដែរ។ ធ្វើដំណើរហ្នឹងដោយដូចថា វាហត់ វាហេវ ចេះតែទៅៗ។ ហើយតាមផ្លូវហ្នឹង ក៏វាមិនមែនត្រង់ដូចសម័យឥឡូវដែរ ផ្លូវហ្នឹងក៏ទូលំទូលាយ ផ្លូវហ្នឹងវាតឿតក្រឡុកក្រឡាច់ ដើរមុតបន្លាខ្លះ រំពាក់ខ្លះ ចេះតែគេចទៅតាមហ្នឹង វាចេះតែឃ្លាលយើងជាប់។ ប៉ុន្តែវាអត់និយាយការណ៍អី។ អ្នកដែលដឹកនាំដែលយកទៅធ្វើសម្លាប់ហ្នឹង។ ទៅដល់កន្លែងហ្នឹងបានវានិយាយការសម្ងាត់ចែកទៅ ខ្ញុំបាទក៏អស់ត្រឹមហ្នឹងហើយ។

[១៤:៣៦:៤៨]

**ស៖** តើលោកអាចរៀបរាប់បន្តិចបានទេ គេបែងចែកទៅជាគ្រុបយ៉ាងដូចម្តេចដែរ? អ្នកណាទៅក្នុងក្រុមណាៗ?

**ឆ៖** បាទ ខ្ញុំបាទជម្រាបជូន ដែលបញ្ហាដែលខ្ញុំបានដឹងច្បាស់ហ្នឹង គេចែកជាកម្លាំងអ៊ីចេះ ចែកកម្លាំងថាអ្នកដែល ដូចគ្រួសារខ្ញុំ ម្តាយក្មេកខ្ញុំហ្នឹងដែលជាស្រីៗដែលវៀតណាម ឬក៏ប្តីវៀតណាម គេចែកទៅក្រុមហ្នឹងចល័ត ដើម្បីទៅស្ទូងស្រូវស្រែពីរដង។ ហើយចំណែកខាងខ្ញុំនេះ គេបែងចែកទៅវៃបោកស្រូវដែលស្រូវច្រូតហើយដាក់គំនរជាកណ្តាប់នោះ បាទ។ ហ្នឹងគេបែបចែកជាពីរប្រភេទ។ ប៉ុន្តែខ្ញុំឆ្ងល់ហ្នឹងអារម្មណ៍ខ្ញុំថា បើគេហៅក៏មិនភាពស្មើគ្នា ចុះអាប្តីប្រុសដែរ ក៏មិនមកខាងខ្ញុំ ហើយខ្ញុំមានគំនិត

ដែរ ប្រពន្ធខ្ញុំយំជាប់ជាដរាប ដឹងថាជីវិតអស់ហើយ ប្រពន្ធខ្ញុំប្រាប់ខ្ញុំថាជីវិតអស់ហើយ។ តែម្ដាយខ្ញុំតក់ស្លុត គាត់គ្រាន់តែទឹកភ្នែករហាម គាត់អត់យំគគ្រឹសគគ្រូសអីទេ បើប្រពន្ធខ្ញុំឡប់ស្មារតីហើយ។ ហើយកូនខ្ញុំចេះតែយំអេកៗ ដែលវាឃ្លានវានោះ។

**ស៖** ដូច្នេះតើត្រឹមត្រូវដែរទេ ដែលថាជនជាតិវៀតណាមប្រុសស្រីគេយកទៅដាក់មួយក្រុម ឯជនជាតិខ្មែរទាំងប្រុសទាំងស្រីនេះ គេយកទៅដាក់ម្ដុំ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ជម្រាបជូនពិតប្រាកដហើយ។

**ស៖** ហើយក្រុមមួយណាដែលគេឲ្យកូនៗទៅនៅជាមួយ?

**ឆ៖** ក្រុមដូចថា ក្រុមដែលប្រពន្ធខ្ញុំហ្នឹងជាក្រុមវៀតណាមហ្នឹង គេឲ្យកូនទៅនៅជាមួយ។ ដែលក្រុមខ្មែរហ្នឹង គេកូន -- គេឲ្យទុកមកនៅជាមួយម្ដាយ បាទតែប៉ុណ្ណឹងទេ។ បើនិយាយឲ្យចំគេឲ្យម្ដាយ ថាម្ដាយខ្មែរកូនគេឲ្យទៅ។ បើម្ដាយវៀតណាម ត្រូវវៀតណាមនេះយកទៅហ្នង គេអត់ឲ្យនៅទេ។ បានន័យថាទៅសម្លាប់ទាំងអស់គ្នា។

**ស៖** ចុះវាមានបញ្ហាអ្វីកើតឡើងដែរ បើសិនជាកូនៗហ្នឹងវាជាជនជាតិវៀតណាម?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ។ លោកស្រីមេធាវីមិនអនុញ្ញាតឲ្យសួរបែបឧបមានវិធីទេណា៎ះ សួរអង្គហេតុជាក់លាក់ចំពោះដើមបណ្ដឹងរដ្ឋប្បវេណី!

សូមអញ្ជើញមេធាវីការពារលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជឿថាតាមរយៈសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី គឺមានកូនពីរ -- មានកុមារពីរនាក់ ដូច្នេះខ្ញុំគិតថាសំណួរហ្នឹងមិនមែនជាសំណួរឧបមានវិធីទេ ហើយមេធាវីអាចសួរបានថាតើកូនគាត់ហ្នឹងនៅក្នុងក្រុមណាដែរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

កែសម្រួលឡើងវិញ មិនអាចប្រើឧបមានៅក្នុងការតាំងសំណួរនៅចំពោះមុខអង្គជំនុំជម្រះដូច្នេះបានទេ។

**កញ្ញា លីម៉ា ង្វៀន៖**

លោកប្រធានសំណួរដែលខ្ញុំសួរ ហើយនិងចម្លើយដែលបានឆ្លើយមកហ្នឹង គឺថាប្រសិនបើម្ដាយ

ជាខ្មែរ –ហ្នឹងអ្វីដែលខ្ញុំបានស្ដាប់ឮ– នោះកូនៗគេឲ្យទៅនៅជាមួយនឹងម្ដាយខ្មែរ។ សំណួរហ្នឹងមិនមែនជាសំណួរបែបសម្មតិកម្មនោះទេ គ្រាន់តែចង់ដឹង ការសួរនេះគឺចង់ឲ្យដឹងបានច្បាស់ថាតើគេមានគោលនយោបាយបែបយ៉ាងម៉េចដែរក្នុងការបំបែកមនុស្សជាក្រុមៗនេះ ប៉ុន្តែមិនជាថ្វីទេ ខ្ញុំអាចនឹងរៀបសំណួរឡើងវិញ។

[១៤:៤១:៣២]

**សួរដោយកញ្ញា លីម៉ា ង្វៀន៖**

**ស៖** លោក ប្រាក់ ឌឿន តើមានអ្វីកើតឡើងទៅដល់កូនៗ?

**លោក ប្រាក់ ឌឿន៖**

**ឆ៖** បាទ កូនដែលយកទៅជាប់ជាមួយម្ដាយនោះ ដូចខ្ញុំបានជម្រាបជូនអ៊ីចឹងថា វាលើកបោះឡើងទៅលើ ហើយព្រឹកឡើងគេប្រាប់ខ្ញុំថាកូនហ្នឹងគេចាក់ស្លាប់ហើយ លើកបោះឡើងទៅលើ កូនហ្នឹងក៏ស្រែកយំ ដល់ស្រែកយំទៅ វារងអាដែងដូចថាចុងកាណុងកាំភ្លើងហ្នឹង ដាក់ទ្រមកអាចំពុះទុងហ្នឹងទ្រក្មេងហ្នឹងបណ្ដោយបាទ តែភ្នែកខ្ញុំអត់បានឃើញ គេប្រាប់ខ្ញុំច្បាស់អ៊ីចឹងតែម្ដង ថាវាយំសម្លើមណាស់។ យំដល់បោះឡើងទៅលើមកវិញ រងញ៉ាច់បណ្ដោយបាទ។ ហ្នឹងបញ្ហាដែលកូនដែលត្រូវយកទៅ ប៉ុន្តែម្ដាយគឺបានស្លាប់ហើយ ស្លាប់មុនចោលកូនបាត់ទៅហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងអង្គការ ធី.ភី.អូ ដែលអមដើមបណ្ដឹងរដ្ឋប្បវេណីមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៣ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:២៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការកិច្ចនីតិវិធីសវនាការ។

សូមអញ្ជើញលោក -- ហើយមានបញ្ហាអ្វីដែរសូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណើសុំឲ្យមានការបញ្ជាក់បំភ្លឺមួយទាក់ទងនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ ខ្ញុំបានស្តាប់ដោយយកចិត្តទុកដាក់ទៅលើអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់នៅពេលរសៀលនេះ។ យើងទាំងអស់គ្នាបានសង្កេតឃើញថា ហេតុការណ៍ដែលគាត់បានរៀបរាប់នេះ គឺមិនមែនជាផ្នែកមួយ ឬក៏មិនមែនជាផ្នែកណាមួយនៃដីកាដំណោះស្រាយនោះឡើយ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់មិនមានយោង មិនមាននិយាយយោងនៅក្នុងដីកាដំណោះស្រាយនោះទេ។

ខ្ញុំដឹងថាអង្គជំនុំជម្រះអនុញ្ញាតឲ្យមានការផ្តល់សក្ខីកម្មទាក់ទងទៅនឹងគោលនយោបាយមួយចំនួន ប៉ុន្តែនៅពេលរសៀលនេះ យើងស្តាប់ឮតែទៅលើភស្តុតាងអង្គហេតុ ឬក៏ការចោទប្រកាន់ពីហេតុការណ៍មួយចំនួនដែលកើតឡើងនៅលើកោះ ដែល ដូចដែលខ្ញុំបញ្ជាក់រួចហើយថាកោះនេះ មិនមាននៅក្នុងដីកាដំណោះស្រាយនោះឡើយ។ ដូច្នេះ ឥឡូវយើងហាក់ដូចជាទទួលបានព័ត៌មានលម្អិតជ្រុលហួសហេតុពេកអំពីហេតុការណ៍ដែលកើតឡើង។ យ៉ាងណាក៏ដោយខ្ញុំគិតថាយើងមានស្ថានភាពមួយដែលកំពុងតែមានបញ្ហា ព្រោះថាឥឡូវហ្នឹងយើងមានដីកាដំណោះស្រាយ ហើយជាដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលកូនក្តីរបស់ខ្ញុំ និងលោក ខៀវ សំផន ត្រូវការពារខ្លួន ប៉ុន្តែមិនមាន -- ប៉ុន្តែក្នុងដីកាដំណោះស្រាយហ្នឹងមិនមាននិយាយអ្វីទាល់តែសោះ អំពីហេតុការណ៍ដែលកើតឡើងនៅលើកោះហ្នឹង និងហេតុការណ៍បន្តបន្ទាប់។ ដូច្នេះ ខ្ញុំគិតថានេះជាបញ្ហាមួយ ជាស្ថានភាពមួយដែលកំពុងតែមានបញ្ហា ហើយដែលជនជាប់ចោទគាត់មិនដឹងថាតើត្រូវការពារខ្លួនដោយរបៀបណា។ ដូច្នេះ ខ្ញុំស្នើសុំដាក់ជាសំណើមួយ ថាតើយើងគួរតែពិចារណា ឬក៏គួរតែសួរឲ្យលម្អិតខ្លាំងទៅលើហេតុការណ៍ហ្នឹង ឬមួយក៏យើងគ្រាន់តែស្តាប់ទៅលើព្យសនកម្មដែលកើតឡើងចំពោះដើមបណ្តឹងរដ្ឋប្បវេណីមួយនេះ។ ដូច្នេះខ្ញុំសួរដោយបញ្ជាក់ឲ្យបានច្បាស់ គឺថាហេតុការណ៍ដែលរៀបរាប់ដោយលម្អិត ដោយដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺស្ថិតនៅក្រៅវិសាលភាព ព្រោះថា កោះតាម៉ូវមិនមាននិយាយរៀបរាប់នៅក្នុងដីកាដំណោះស្រាយនោះទេ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំធ្វើសំណើជាមុន ដើម្បីសុំពេល ដើម្បីសួរសំណួរទៅលើដើម

បណ្ដឹងរដ្ឋប្បវេណីរូបនេះ។ ខ្ញុំសូមឆ្លៀតឱកាសនេះដើម្បីឆ្លើយតបទៅនឹងការជំទាស់របស់មេធាវី កូប៉េ។ ខ្ញុំសូមបញ្ជាក់ថា ចម្លើយគឺត្រឹមត្រូវ គឺដូចដែលអង្គជំនុំជម្រះបានអនុវត្តពីមុនមក។ អង្គជំនុំជម្រះបានសម្រេចស្ដាប់ដើមបណ្ដឹងរដ្ឋប្បវេណីទៅលើគោលនយោបាយមួយចំនួន ហើយដូចដែលមាននៅក្នុងឯកសារដែលប្ដឹងមកតុលាការ គឺដូចនៅក្នុងឧបសម្ព័ន្ធ E301/9/1.1 ដែលបានបញ្ជាក់អំពីកថាខណ្ឌនៃដីកាដំណោះស្រាយដែលបានប្ដឹងទៅតុលាការសម្រាប់សំណុំរឿង០០២/០២ ហើយយើងមានកថាខណ្ឌមួយចំនួនដែលបង្ហាញឲ្យឃើញថា សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី មានផលប្រយោជន៍សម្រាប់ការបង្ហាញការពិត។

[១៥:០៦:៤៤]

ខ្ញុំសូមលើកជាឧទាហរណ៍ កថាខណ្ឌ២១៣ ដល់ ២១៥ ស្ដីអំពីគោលនយោបាយ និងការកំណត់គោលដៅជាក់លាក់ប្រឆាំងនឹងជនជាតិវៀតណាម នៅក្នុងផ្នែកសហឧក្រិដ្ឋកម្មរួមនៃដីកាដំណោះស្រាយ ឬកថាខណ្ឌ៧៩១ ទៅដល់ ៧៩៦ ឬកថាខណ្ឌពាក់ព័ន្ធទៅនឹងអចេតនានៃអំពើប្រល័យពូជសាសន៍។ ដូច្នេះ អ្វីដែលយើងស្នើអង្គជំនុំជម្រះនោះ គឺយើងនៅតែបន្តអនុវត្ត។ អ្វីដែលយើងបានអនុវត្តពីមុនមកដដែល គឺទុកឲ្យដើមបណ្ដឹងរដ្ឋប្បវេណីផ្ដល់សក្ខីកម្មលើអង្គហេតុទាំងមូលដែលខ្លួនចង់ ហើយភាគីនីមួយៗវាយតម្លៃទៅលើសក្ខីកម្មរបស់ពួកគាត់ អាចនឹងសរសេរនៅក្នុងសារណាចុងក្រោយ ថាតើភស្តុតាងរបស់គាត់ហ្នឹងមានផលប្រយោជន៍យ៉ាងម៉េចខ្លះ? ដូច្នេះ ខ្ញុំសូមអង្គជំនុំជម្រះអនុវត្តនូវអ្វីដែលយើងបានអនុវត្តពីមុនមក ហើយសូមឲ្យអនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ និងក៏ដូចជាដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងៗទៀតដែរ ឲ្យផ្ដល់សក្ខីកម្មទៅលើអង្គហេតុទាំងមូលតាមតែអ្វីដែលពួកគាត់ចង់និយាយ ហើយយើងមើលទៅ គឺយើងថាមានកថាខណ្ឌនៅក្នុងដីកាដំណោះស្រាយរួចមកហើយ ដែលអាចបញ្ជាក់ថាសក្ខីកម្មរបស់ពួកគាត់អាចមានសារៈសំខាន់សម្រាប់ការបង្ហាញការពិត។

ខ្ញុំត្រឡប់មកនិយាយអំពីសំណើដំបូងរបស់ខ្ញុំវិញ។ គឺយើងឃើញថា គាត់មានភាពនឿយហត់ខ្លាំង ដូច្នេះយើងសូមពេលវេលា២០នាទីបន្ថែម ដើម្បីឲ្យយើងអាចផ្ដល់ពេលវេលាគ្រប់គ្រាន់ឲ្យសហព្រះរាជអាជ្ញាអាចបន្តសួរសំណួរទៅលោក ប្រាក់ ខឿន បាន។ នេះជាសំណើរបស់ខ្ញុំ លោកប្រធាន គឺសុំ២០នាទីបន្ថែមសម្រាប់តំណាងដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងការិយាល័យសហព្រះរាជអាជ្ញា។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១៥:០៩:០៣]

**លោក វាំងសង់ វ៉ាយដ៍ ដេស្វាងលេះ**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។ ខ្ញុំសូមឆ្លើយតបទៅនឹងការជំទាស់យឺតពេលរបស់មេធាវីការពារក្ដី។ ខ្ញុំគិតថា មេធាវីការពារក្ដីដឹងតាំងពីយូរណាស់មកហើយថា ដើមបណ្ដឹងរដ្ឋប្បវេណីរូបណាដែលត្រូវបានគ្រោងទុកសម្រាប់ផ្នែកនេះ។ អង្គជំនុំជម្រះបានសម្រេចស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ គឺវាមិនពាក់ព័ន្ធនឹងព្រៃវែង និងស្វាយរៀងទេ គឺពាក់ព័ន្ធនឹងផ្នែកផ្សេងទៀតនៃប្រទេសកម្ពុជា។ ខ្ញុំសូមរំឭកថា មេធាវីការពារក្ដីគួរតែលើកអំពីចំណុចនេះ តាំងពីពេលដែលខ្លួនទទួលបានបញ្ជីដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីតាំងពីដំបូងម្ល៉េះ។ ហើយទី២ នៅក្នុងដីកាដំណោះស្រាយផងដែរ មិនមែនមានត្រឹមតែអង្គហេតុពាក់ព័ន្ធនឹងស្វាយរៀង និងព្រៃវែងដែលមានបញ្ជាក់នោះទេ គឺយើងមានសាក្សីមួយដែលបានផ្ដល់សក្ខីកម្មអំពីអង្គហេតុដែលបានកើតឡើងនៅសៀមរាប នៅវត្តខ្សាច់ទៀតផង។ ហើយពេលនោះ គឺមានការជំទាស់ដូចគ្នាហ្នឹងដែរបើខ្ញុំមិនច្រឡំទេ។ ពិតណាស់ សក្ខីកម្មរបស់បុគ្គលដែលបានមើលឃើញហេតុការណ៍ ដែលបានកើតឡើងចំពោះវៀតណាមនៅទូទាំងប្រទេសនោះ អាចដឹងអំពីគោលនយោបាយដែលអនុវត្តចំពោះជនជាតិវៀត-ណាម គឺគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ មានការបញ្ជាក់នៅក្នុងដីកាដំណោះស្រាយដើម្បីបង្ហាញឲ្យឃើញថា នេះគោលនយោបាយថ្នាក់ជាតិ វាមិនមែនជាគោលនយោបាយថ្នាក់ភូមិភាគ ឬថ្នាក់តំបន់ទេ។ ហើយមានការដកស្រង់នូវទីកន្លែងមួយចំនួននៅក្នុងដីកាដំណោះស្រាយនោះ។

ដូច្នេះ យើងគិតថា ភស្តុតាងទាំងអស់នេះមានសារៈសំខាន់ក្នុងការបង្ហាញអំពីគោលនយោបាយ ឬបង្ហាញអំពីការវាយប្រហារជាទូទៅ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ គឺជាការវាយប្រហារទៅលើប្រជាជនស៊ីវិលជាទូទៅ និងនៅក្នុងករណីយើងនេះ គឺជាការវាយប្រហារទៅលើជនជាតិវៀត-ណាម។ សូមអរគុណ។

[១៥:១១:១៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញក្រុមសហមេធាវីការពារក្ដីលោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឆ្លើយបន្តទៅនឹងការកត់សម្គាល់របស់មេធាវីដើមបណ្ដឹងរដ្ឋ-

ប្បវេណី និងសហព្រះរាជអាជ្ញាអន្តរជាតិ។ ខ្ញុំគិតថា ខ្ញុំគួរតែធ្វើសំណើ គឺថាប្រសិនបើមានការផ្តល់ពេលវេលាបន្ថែមនោះ យើងក៏ត្រូវការពេលវេលាបន្ថែមសម្រាប់ខាងយើងដែរ គឺដោយសារចំណុចពីរ គឺយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងចំណុចនេះ គឺសហមេធាវីបានលើកឡើងមកហើយ ជាពិសេសពាក់ព័ន្ធទៅនឹងឋានៈនៃដើមបណ្តឹងរដ្ឋប្បវេណីនៅពេលដែលមានអង្គហេតុ ដែលមិនមានបញ្ចាក់នៅក្នុងដីកាដំណោះស្រាយច្បាស់លាស់នោះ សំណើសុំពេលវេលាបន្ថែមនេះគឺមានមូលដ្ឋាន។ គឺថានៅពេលមុនរៀបចំខ្លួននោះ យើងមានឯកសារសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ហើយនៅពេលដែលយើងអានព័ត៌មាននៅក្នុងឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ យើងមិនអាចគ្រោងទុកមុនថា តើសក្ខីកម្មនោះនឹងមានយ៉ាងម៉េចទេ។ ហេតុនេះហើយ ខ្ញុំសូមជម្រាបជូនអង្គជំនុំជម្រះថា ដើម្បីឲ្យយើងអាចមានវិធានការសមស្របនោះ គឺយើងត្រូវការពេលវេលាបន្ថែម ដោយសារតែមានព័ត៌មានថ្មីដែលបានលេចឡើងចំពោះពួកយើង។

[១៥:១៣:០៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១៥:៣០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ឆ្លើយតបទៅនឹងសំណើសុំរបស់ភាគីទាំងសងខាងលើបញ្ហាអម្បាញ់មិញនេះទាំងពីរបញ្ហា។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ជាដំបូងពាក់ព័ន្ធនឹងការជំទាស់របស់មេធាវីការពារក្តីលោក នួន ជា អង្គជំនុំជម្រះកត់សម្គាល់ឃើញថាការជំទាស់នេះយឺតពេលទៅហើយ។ ដូច្នេះ យើងបដិសេធការជំទាស់នេះ។ ដោយសារអង្គជំនុំជម្រះយល់ឃើញថាសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមានសារៈសំខាន់អាចឲ្យយើងវាយតម្លៃ ថាតើមានគោលនយោបាយនៅថ្នាក់ជាតិ ឬក៏អត់ ពាក់ព័ន្ធនឹងវិធានការជាក់លាក់ទៅលើជនជាតិវៀតណាម។

ពាក់ព័ន្ធទៅនឹងការសុំពេលវេលាបន្ថែម អង្គជំនុំជម្រះកត់សម្គាល់ឃើញថាពីព្រឹកមិញនេះ យើងចាប់ផ្តើម២៥នាទីមុនពេលសម្រាកអាហារថ្ងៃត្រង់។ ដូច្នេះ អង្គជំនុំជម្រះសម្រេចផ្តល់ជូនសហមេធាវី

នាំមុខ និងសហព្រះរាជអាជ្ញារហូតទៅដល់ចប់រសៀលនេះ។ ហើយនៅពេលព្រឹកនោះយើងនឹងពិនិត្យមើលថាតើយើងនឹងផ្តល់ពេលវេលាបន្ថែមទៅដល់មេធាវីការពារក្តី ឬក៏អត់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញបន្តបាទ។ ច្បាស់លាស់ហើយបាទ។ ផ្តល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបាទ។

[១៥:១៧:១៨]

**សួរដោយកញ្ញា លីម៉ា ង្វៀន៖**

**ស៖** លោក ប្រាក់ ឌឿន មុនពេលដែលយើងឈប់សម្រាក លោកបានជម្រាបតុលាការថា នៅថ្ងៃដែលលោកបែកជារហូតពីប្រពន្ធរបស់លោក គឺកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបានប្រមូលផ្តុំគ្រួសារដែលរៀបការចម្រុះជាតិសាសន៍ចំនួនប្រាំពីរគ្រួសារនៅកោះតាម៉ូវនោះ នៅពេលយប់។ ហើយបន្ទាប់មកទៀត កម្មាភិបាលបាននាំក្រុមគ្រួសារហ្នឹងដើរប្រហែលជា១០គីឡូ។ ហើយបន្ទាប់មកទៀតជនជាតិវៀតណាមនៅក្នុងក្រុមហ្នឹងត្រូវបានបំបែកចេញពីជនជាតិខ្មែរនៅក្នុងក្រុមហ្នឹង។ លោកបាននិយាយថា កូនរបស់លោក កូនប្រុសរបស់លោកទៅតាមប្រពន្ធរបស់លោក។ ដូច្នេះខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ថាតើនៅក្នុងហ្នឹងមានក្មេងៗប៉ុន្មាននាក់ដែរ?

**លោក ប្រាក់ ឌឿន៖**

**ឆ៖** ខ្ញុំបាទក៏សូមបញ្ជាក់ជូននូវបញ្ហាដែលក្មេង ដែលបានធ្វើដំណើរទៅ កម្មាភិបាលដឹកនាំទៅ –មានដែលភ្នែកខ្ញុំឃើញជាក់ស្តែងនៅពេលព្រលប់ផង– មានចំនួនតែពីរនាក់ទេ កូនគេខាងណោះម្នាក់ កូនខ្ញុំបាទម្នាក់។ តែកូនម្នាក់ទៀតហ្នឹង គេជាប់ទៅតាមម្តាយ ដូចខ្ញុំជម្រាបជូនខាងដើម។ តែកូនខ្ញុំនេះវាតាមម្តាយវា គឺស្វរដែរមិត្តយើងមួយចំនួនពិតប្រាកដថា បោះឡើងទៅលើ គេចាក់នឹងកន្ទុយដែអានេតរបស់កាំភ្លើងហើយ។ ក៏អារម្មណ៍ខ្ញុំបែងចែកថា អញប៉ុណ្ណេះអស់ទាំងប្រពន្ធអស់ទាំងកូន អារម្មណ៍ខ្ញុំបែងចែកគិតវាខ្វល់ខ្វាយហ្នឹង គឺគិតក្នុងយប់ហ្នឹងរហូតមកទល់ឥឡូវក៏បាត់ស្មារតីមួយចំនួន។ សូមមេត្តាអធ្យាស្រ័យ។

**ស៖** ដូច្នេះខ្ញុំអាចនិយាយបានថា កូនហ្នឹងដែលមិនមែនជា -- កូនក្មេងដែលមិនមែនជាកូនរបស់លោកហ្នឹង គឺតាមក្រុមជនជាតិវៀតណាម។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ មិនមែនជាក្រុមវៀតណាមទេ គឺពេលហ្នឹងដែលដាច់ពីប្តីពីអីហ្នឹងណាស់ ហើយវា

ចូលទៅជាក្រុមខ្មែរពិតប្រាកដហើយ។

[១៥:១៩:៥៣]

**ស៖** អ៊ីចឹងព្រោះដោយសារតែឪពុករបស់ក្មេងហ្នឹងជាជនជាតិវៀតណាម ហើយម្ដាយជាជនជាតិខ្មែរ ឬទើបគេធ្វើអ៊ីចឹង?

**ឆ៖** ជនជាតិវៀតណាម គេធ្វើយកប្ដីទៅសម្លាប់។ តែបើជនជាតិខ្មែរយើង គេម្ដាយនៅរស់អ៊ីចឹង ដែលគេអត់ឱ្យទៅជាមួយ កូនហ្នឹងក៏នៅរស់ដែរ បាទ។

**ស៖** នៅពេលដែលគេបំបែកលោកចេញពីប្រពន្ធលោក តើលោកមានឱកាសបាននិយាយជាមួយកម្មាភិបាលខ្មែរក្រហមដែរឬទេ?

**ឆ៖** បាទ កាលនៅពេលយប់ហ្នឹងដែលគេធ្វើទារុណកម្ម គេយកទៅធ្វើឃាតហ្នឹង ខ្ញុំបាទអត់មានហ៊ានជជែកទេ គេឱ្យទៅណា ខ្ញុំបាទក៏ទៅតាមទិស។ ពាក្យថា "ទិស" មួយមាត់គឺច្បាប់របស់គេ។ គេបញ្ជាក់ទៅខាងណា ខ្ញុំបាទក៏ទៅតាមដំណើរការដែលចាត់ចែង។

**ស៖** តើលោកមានបានផ្ដាំផ្ញើពាក្យពេចន៍អ្វីទេមុនពេលដែលលោកបែកពីប្រពន្ធរបស់លោកទៅ?

**ឆ៖** បាទ ខ្ញុំបាទសូមជម្រាបទៅតាមត្រង់ គឺគ្មានបាននិយាយការណ៍អីផ្ដាំផ្ញើ ឬក៏ផ្ដល់ព័ត៌មានអីជាអ្វីមួយ គឺអត់។ គឺមានអារម្មណ៍គិតឱ្យសព្វយ៉ាង គេអត់មានការពិគ្រោះជាមួយប្រពន្ធកូន គេឱ្យដើរដាច់ដោយឡែកៗ។ ទៅដល់កន្លែងទីដៅដែលគេសម្លាប់ហ្នឹង គេឱ្យចៀស រឹតតែចេញឆ្ងាយទៀត។

**ស៖** តើលោកមានបានសុំកម្មាភិបាលថា លោកសុំនៅជាមួយប្រពន្ធលោកទេ?

**ឆ៖** ខ្ញុំបាទអត់បានសុំទេ ប៉ុន្តែកូនខ្ញុំបាទសុំ។ ខ្ញុំបាទសុំកម្មាភិបាលហ្នឹងមួយចំនួន គេថាអ៊ីចឹងបើម៉ែវាទៅច្រូតស្រូវខាងណោះ ខ្ញុំសុំកូនហ្នឹងដើម្បីយកមកបំពេ ឬក៏បញ្ចុកបាយ។ គេ មិត្តកម្មាភិបាលនោះ ក៏បានពោលថា មិនបាច់ព្រួយរឿងចែកទេ មិនបាច់បញ្ចុកទេ គេមានសហករណ៍របស់គេ គេមានម៉ែអ្នកការពារ ជួយចិញ្ចឹមរួចអស់ទៅហើយ អង្គការគេចាត់តាំងរួចទៅហើយ មិនបាច់ពួងឯងយកមកនាំអំពល់ទុក្ខទេ វាខាតការងាររបស់បក្ស របស់រដ្ឋយើង។

[១៥:២២:២៧]

**ស៖** តើលោកដឹងទេថា គេយកក្រុមជនជាតិវៀតណាមហ្នឹង យកទៅណាដែរ?

**ឆ៖** គេបានប្រាប់ខ្ញុំថា គេយកទៅសម្លាប់ហើយ គេយកអត់ទុកទេ គេប្រាប់ត្រង់។ មកព្រឹកឡើងបានគេប្រាប់យើងថា គេយកទៅកម្ទេចហើយ។ គេអត់ថាសម្លាប់ទេ គេថាកម្ទេច។ បាទ អង្កាល់

នៅសម័យហ្នឹងគេប្រាប់ថាកម្ទេច គេអត់ប្រាប់ថាសម្លាប់ទេ។ ប៉ុនដែលយើងនេះនៅធម្មតា ដែលយើងប្រើពាក្យសាមញ្ញ យើងប្រាប់ថា បើកម្ទេចមុខតែស្លាប់ហើយ បាទ។

**ស៖** តើអ្នកណាជាអ្នកប្រាប់លោកថា គេកម្ទេចក្រុមជនជាតិវៀតណាមនោះ?

**ឆ៖** ខ្ញុំបាទចាំឈ្មោះ គឺមិត្តហ៊ឹម។ មិត្តហ៊ឹម ប្រធានកងខ្ញុំបាទ គឺថាបានបញ្ជាក់ថា ព្រឹកឡើងបានប្រាប់ខ្ញុំថា ពូតាំងស្មារតីទៅ ព្រោះប្រពន្ធកូនអត់មានកើតមកវិញទៀតទេ។ អង្គការបានកម្ទេចហើយ ហើយក៏បានបន្ទោសពាក្យមួយមាត់ថា ចុះពូឯងពីដើមឡើយក៏មិនយកប្រពន្ធខ្មែរ? ម៉េចបានពូទៅយកប្រពន្ធវៀតណាម? ខ្ញុំរកពាក្យអីឆ្លើយដាក់កំហុសទៅគ្មាន ខ្ញុំក៏នឹកឃើញពីរបបសម្តេច នរោត្តម សីហនុ ខ្ញុំបាទក៏ឆ្លើយក្នុងការដោះស្រាយទៅ។ ខ្ញុំបាទថា អ៊ីចឹងជំនាន់សម្តេច សីហនុ ដែលគាត់ជាទទួលគ្រងរាជ្យមានរាជរដ្ឋាភិបាលត្រឹមត្រូវ ក៏គាត់អត់បញ្ញត្តិថាឲ្យខ្ញុំកុំឲ្យយកប្រពន្ធសញ្ជាតិវៀតណាម! ហើយខ្ញុំគ្រាន់តែថាប៉ុណ្ណឹងទៅ ខ្ញុំឆ្លើយទៅដាក់សម្តេចឪយើងថា បើឃើញខ្ញុំទាស់ខុសអ៊ីចឹង ក៏មិនឲ្យរៀបការថាឥឡូវរៀបការមិនបានទេ។ ហើយស្រាប់ដល់ថាអ៊ីចឹងៗ ពូឯងមិនបាច់និយាយ ទៅទម្លាក់ដាក់អ្នកណាទេ គឺកិច្ចការហ្នឹងរបស់ពូឯងផ្ទាល់ខ្លួនហ្នុង បាទ។

**ស៖** តើគាត់មានប្រាប់លោកទេថាតើគេសម្លាប់មនុស្សហ្នឹងដោយរបៀបណាដែរ?

**ឆ៖** គាត់បានប្រាប់ខ្ញុំថា ពេលដែលយកទៅសម្លាប់ហ្នឹង គេអត់សួរចម្លើយទេ។ គេចងស្លាប់សេក ហើយគេរុំមុខ ហើយគេចងស្នួលឫស្សីមួយ ហើយអន្លុងនៅចម្ងាយប្រហែល ជម្រៅប្រហែលជា១ម៉ែត្រមិនដល់ផង ហើយប្រាំមួយប្រាំពីរទឹកហ្នឹង គេវៃពីខ្នងឫស្សីទៅទម្លាក់ទៅចូលក្នុងរណ្តៅហ្នឹង ហើយខ្ញុំបាទទៅតាមកម្មាភិបាលនិយាយប្រាប់ខ្ញុំបាទ គឺខ្ញុំបាទមិនបានឃើញចំពោះភ្នែកខ្លួនឯងទេ។

**ស៖** តើគាត់មានប្រាប់លោកទេ ថាគេសម្លាប់មនុស្សទាំងអស់នេះនៅពេលណាដែរ?

**ឆ៖** បាទ ដែលអង្គាល់ដែលដឹកនាំកម្លាំងខ្ញុំទៅវារហូតទល់ម៉ោងប្រាំមួយ ដេកផង ដើរផងទម្រាំទៅដល់ ខ្ញុំប៉ាន់ស្មានប្រហែលជាម៉ោងបីកន្លះ។ វៃហ្នឹង បើតាមការពិតវៃជិតរៀបភ្លឺហ្នឹងតែម្តង។

**ស៖** តើលោកដឹងទេថាអ្នកទាំងនោះត្រូវបានគេសម្លាប់ភ្លាមៗក្រោយគេបំបែកចេញពីពួកលោក ឬមួយក៏គេសម្លាប់នៅពេលក្រោយមកទេ គេមានចន្លោះពេលក្រោយមកទៀតទេ?

**ឆ៖** នៅក្នុងពេលនោះ គេបានប្រាប់ខ្ញុំ មិត្តដែលបានប្រាប់ខ្ញុំហ្នឹង ថាវៃភ្លាមៗ បែកកម្លាំងភ្លាមចាត់ការរួចស្រេចតែម្តង អ្នកដែលប្រចាំការចាំវៃទៅ អ្នកដែលដឹកនាំមនុស្សយកទៅកន្លែងរណ្តៅហ្នឹងតែម្តង។

សះ តើគេ តើពួកគេមានប្រាប់លោកទេថា គេសម្លាប់ក្មេងៗហ្នឹងដោយរបៀបណាដែរ?

ឆះ បាទ គេពន្យល់ប្រាប់ខ្ញុំថា –មិត្តដែលបានប្រាប់ខ្ញុំនោះ– គេថា បោះឡើងទៅលើ គេរងអាដែងចំពុះទុង -- ចំពុះទុងចុងកាណុងកាំភ្លើងនោះ ទ្រតែម្ដង បោះទៅមកវិញត្រូវពីរ បីចំពុះទុង ក៏ងាប់ស្រេចតែម្ដង។ ថាអ៊ីចេះ។

សះ ក្រោយពេលដែលលោកបែកចេញពីក្រុមជនជាតិវៀតណាម តើមានអ្វីកើតឡើងចំពោះក្រុមជនជាតិខ្មែរនោះ?

[១៥:២៧:១០]

ឆះ ដែលខ្ញុំបាទ ដែលបានគេសម្លាប់រួចទៅហើយ គេចាត់តាំងឲ្យខ្ញុំទៅក្ដាប់ស្ត្រីចំនួន៨៥នាក់នៅតាមវាលស្រែ។ ឯខ្ញុំបាទគោរពតាមអង្គការដាក់ទិស ដល់ពេលយប់ឡើង ខ្ញុំតាំងស្មារតីភ្ញាក់រលឹកគឺថាឲ្យខ្ញុំទាំងពីរនាក់ដែលជាប្រពន្ធវៀតណាមដែលគេយកទៅទាំងអស់នោះ មួយទៀតឈ្មោះ ហួ ក៏បានស្លាប់បាត់បង់ជីវិតទៅហើយ។ កាលហ្នឹង ជំនាន់ហ្នឹងនៅខ្ញុំពីរនាក់ទៅដេកលើផ្ទះ សូម្បីតែកន្ទេលកាំបិតក៏គេយកចុះមកដែរ គេអត់ឲ្យយើងនៅទេ គេឲ្យនៅលើផ្ទះ ប៉ុន្តែហូបចុកក្នុងរយ:ប្រហែលជាមួយអាទិត្យហ្នឹង គេឲ្យហូបជាមួយគេ គេហូបអី ហូបត្រីអាំង ខ្ញុំហូបត្រីអាំងដែរ បាយឆ្អែត។ តែអស់ពីពេលហ្នឹងទៅ បាយធម្មតា។

សះ បន្ទាប់ពីប្ដីប្រពន្ធជនជាតិវៀតណាមត្រូវបានគេយកទៅសម្លាប់ តើមានប្រជាជនវៀតណាមនៅសល់ទៀតទេ នៅលើកោះតាម៉ូវនោះ?

ឆះ ខ្ញុំបាទជម្រាបជូនថាអស់ហើយពេលហ្នឹង គេប្រមូលសេសសល់ គេប្រមូលដឹងទាំងអស់អ្នកណាឲ្យតែមានសាច់ស និយាយទ្រង់ប៉ែឡាក៏គេចាប់អារម្មណ៍ដែរ គេយកនៅឃុំដទៃទៀតដែលខ្ញុំបានឃើញគឺឈ្មោះមិត្តទី គ្នាជាសញ្ជាតិចិនទេ ប៉ុន្តែដល់និយាយមិនច្បាស់ គេយកគ្នាទៅដែរហៅគ្នាទៅទាំងយប់ដែរ។ ប៉ុន្តែសហករណ៍ដាច់ដោយឡែក ព្រោះរឿងហ្នឹងខ្ញុំអត់ដឹង ប៉ុន្តែមុននឹងយកគេទៅសម្លាប់ ខ្ញុំបាទដឹងនៅកំពង់ទាំងអស់គ្នា ប៉ុន្តែនៅសហករណ៍ខុសគ្នា ប៉ុន្តែសហករណ៍ហ្នឹងនៅជិតគ្នា។

[១៥:២៩:០៧]

សះ ដូច្នេះ ពេលចុងក្រោយដែលលោកនៅជាមួយប្រពន្ធលោកគឺនៅចុងឆ្នាំ៧៧ ប៉ុន្តែឥឡូវនេះខ្ញុំនិយាយអំពីកូនប្រុសពៅរបស់លោកគឺនៅពេលនោះគឺអាយុ១ឆ្នាំកន្លះត្រូវបានយកទៅជាមួយប្រពន្ធ និងម្ដាយក្មេករបស់លោកនៅពេលគេបំបែកគ្នានោះ។ ចុះខ្ញុំចង់សួរថាកូនស្រីប្រាំនាក់របស់លោកផ្សេងទៀត

ហ្នឹង តើទៅណាដែរ?

**ឆ៖** ខ្ញុំបាទក៏ជម្រាបថយឡើងមកវិញ គឺថាខ្ញុំបាទថាកូនដែលនៅសេសសល់ប្រាំនាក់ហ្នឹង កូនទី១ គឺទៅតាមសហករណ៍ កូនទី២ទៅ ដូចថាអង្គការចាត់តាំងថា សហករណ៍ចល័ត។ ឧបមាថាគេចង់ឲ្យទៅណាគេទៅ គេទៅ៤-១០ថ្ងៃទៅ គេចល័តខាងនេះ ចល័តទៅខាងនោះ។ កូនទី៣ នៅគឺដូចថាវាបណ្ដុះបណ្ដាល វាភរយើងថារៀនសូត្រអីអីចឹង ហើយដល់អាកូនទី៤ហ្នឹង ដូចថានៅតាមអាដែងកុមារដូចអាយើងសព្វថ្ងៃ គេហៅថាកុមារនៅតាមសហករណ៍ដែលគេបង្រៀន។ តាមការពិតវាឲ្យស៊ីត្រកួនស៊ីគ្មានថ្នាំទេ វាករូស ដែលខ្ញុំ ភ្នែកខ្ញុំមើលឃើញគឺ ដើមហេតុហ្នឹងគឺនៅព្រែកស្ពាន។ ព្រែកស្ពានហ្នឹងកូនមួយថ្ងៃៗដែលខ្ញុំប៉ាន់ស្មាននឹងគំនិតខ្ញុំ ដែលខ្ញុំមើលឃើញប្រហែលជា ២០ ទៅ ៣០នាក់ ដែលងាប់ហ្នឹង ព្រោះអត់អាហារមួយ បញ្ហាអត់ថ្នាំមួយ អាហារហូបមិនគ្រប់គ្រាន់មួយ។ ហើយមេដោះហ្នឹង វាមានកូនច្រើន មេដោះវាតិច មិនអាចចាត់ចែងបានទេ អាខ្លះវាកទៅ រូសទៅ ស្លាប់ទៅ អាណានៅដង្ហើមផ្ដឹកៗ គេយកទៅកប់ទៅ ដែលខ្ញុំបានមើលឃើញហ្នឹង។

[១៥:៣០:៤៨]

**ស៖** តើលោកជួបកូនស្រីទាំងបីនាក់របស់លោកដែលមុននេះ លោកថាបានស្លាប់ហ្នឹង តើលោកបានជួបពួកគេហ្នឹងចុងក្រោយបំផុតនៅពេលណាដែរ?

**ឆ៖** បាទ ខ្ញុំជម្រាបជូនដោយជ្រាប ជួបគ្នាក្រោយហ្នឹងដោយសារដំណឹង នៅត្រង់មុខកូនខ្ញុំអត់បានជួបទេ តែកូនពីរក្រោយដែលត្រូវជួប ដែលនៅរស់នៅហ្នឹង គឺខ្ញុំបាទដែលខ្ញុំជម្រាបជូនខាងដើមហ្នឹងវាពាក់ព័ន្ធហ្នឹង ថាខ្ញុំបំបែកឈ្មោះហ្នឹងថា មីកំបាក់ មីកំពុកហ្នឹង នៅរស់នៅសល់ពីរ បាទ។ អាកូនដែលស្លាប់ទៅ គឺបីនាក់ទៀតហ្នឹង គឺខ្ញុំអត់បានជួបមុខទេ តែគេបានប្រាប់ខ្ញុំថាងាប់ទៅតាម នៅសហករណ៍នៅតាមមូលដ្ឋាន នៅតាមកងចល័ត។

**ស៖** តើលោកដឹងទេថាកូនពីរនាក់របស់លោកដែលនៅរស់ហ្នឹងតើពួកគេធ្វើបែបណាទើបអាចនៅរស់រានមានជីវិតបាន?

**ឆ៖** ខ្ញុំបាទសូមបញ្ជាក់ជូន បញ្ហាដែលកូនខ្ញុំបាននៅរស់ គឺខ្ញុំបានផ្ដល់នូវបញ្ហាត្រីខ្លះ វាមិនគ្រប់ថ្ងៃ គ្រប់ខែទេ ប៉ុន្តែបីបួនថ្ងៃខ្ញុំលួចផ្ញើទៅចៀន ទៅអាំងទៅ។ លួចតាមកុមារហ្នឹងចែកចាយអ្នកដែលដឹកនាំយកត្រីនេះចែកគេពាក់កណ្ដាលទៅ បានទៅឲ្យកូនពាក់កណ្ដាលទៅ ហើយចេះលាក់ចេះបំពួនស្ងោរត្រកួនខ្លះទៅ លួចពីសណ្ដែកចម្ការខ្លះ ខ្ញុំជម្រាបដោយត្រង់ លួចសណ្ដែកបានក៏ខ្ញុំលួចស្ងោរជា

កំប៉ុងគ្រាប់ពោតដែលគេឲ្យទៅដាំហ្នឹង គឺលួចបែងចែកស្មោរ លួចស្មោរទាំងយប់ ភ្លើងហុយៗហ្នឹង។ បានព្រឹកឡើងក្មេងកុមារមកស្ទូងដកហ្នឹង ខ្ញុំផ្ញើទៅតាមហ្នឹងទៅ បានៗរស់រានមានអាយុដែលខ្ញុំបាទ បានជម្រាបជូនហ្នឹង គឺដែលខ្ញុំបានដាក់ឈ្មោះថា កុំឲ្យរក មីឈ្មោះដើមកំណើតហ្នឹង ថាអត់មានឈ្មោះហ្នឹងទេ បើឈ្មោះកូនខ្ញុំឈ្មោះ មីកំបាក់ មីកំពុក ឲ្យទៅរកវាឃើញទៅបាទ។

[១៥:៣៣:០៥]

**ស៖** កូនស្រីរបស់លោកពីរនាក់ ដែលរស់រានមានជីវិត តើមុខមាត់របស់គេមើលទៅដូចវៀត-ណាម ឬក៏ដូចខ្មែរ?

**ឆ៖** ខ្ញុំបាទជម្រាបជូន ថារស់នៅដល់សព្វថ្ងៃនេះ គេមើលទៅ ដែលខ្លួនខ្ញុំមើលផ្ទាល់ផង ក៏អ្នកដទៃមើលផ្ទាល់ បានន័យថាខ្មែរសុទ្ធ ព្រោះសាច់ក៏ខ្មៅទាំងអស់ កាត់មកខ្ញុំទាំងអស់គ្នាហ្មង។

**ស៖** លោកបានឆ្លើយថា ក្រោយពីការបំបែកវៀតណាមចេញពីគ្រួសារដែលរៀបការជនជាតិចម្រុះ គឺថាមិនមានជនជាតិវៀតណាមរស់នៅលើកោះតាម៉ូវទៀតទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ នៅក្នុងពេលនោះ គឺអស់រលីង អត់មានសេសសល់អីទេ។

**កញ្ញា លីម៉ា ង្វៀន៖**

លោកប្រធានខ្ញុំអស់សំណួរហើយ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទឥឡូវនេះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំចង់សួរសំណួរបន្តទៅទៀត ពាក់ព័ន្ធទៅនឹងអ្វីដែលលោកបានឆ្លើយ បន្ទាប់មកទៀត ខ្ញុំនឹងចូលទៅប្រធានបទផ្សេង គឺពាក់ព័ន្ធនឹងការរៀបចំអាពាហ៍ពិពាហ៍ដោយអង្គការ។ អម្បាញ់មិញនេះលោកនិយាយថា ប្រពន្ធរបស់លោកកើតនៅភូមិកំពង់ព្រះ ស្រុក -- ឃុំឆ្នុកទ្រូ ស្រុកបរិបូរ។ លោកដឹងទេថា គ្រួសារខាងប្រពន្ធរបស់លោកហ្នឹងមករស់នៅកម្ពុជាតាំងពី

ពេលណាមក? តាំងពីមុនពេលប្រពន្ធរបស់លោកកើតទៀត ឬក៏យ៉ាងណា?

[១៥:៣៦:៣២]

**ប្រធានអង្គជំនុំ៖**

បាទ តំណាងសហព្រះរាជអាជ្ញារងអន្តរជាតិ តាំងសំណួរនោះសាជាថ្មីម្តងទៀត! ទំនងភ្លេចសំណួរហើយ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាងលេ៖**

បាទ លោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាងលេ៖**

**ស៖** អម្បាញ់មិញនេះ លោកដើមបណ្តឹងរដ្ឋប្បវេណី លោកថាប្រពន្ធរបស់លោក គឺកើតនៅក្នុងភូមិជាមួយលោក គឺនៅភូមិកំពង់ព្រះ។ ដូច្នេះ ខ្ញុំចង់ដឹងថាតើគ្រួសាររបស់ប្រពន្ធលោកហ្នឹង មករស់នៅក្នុងប្រទេសកម្ពុជាហ្នឹងតាំងពីពេលណាមក?

**លោក ប្រាក់ ឡឿន៖**

**ឆ៖** ខ្ញុំបាទជម្រាបជូនថា ប្រពន្ធកូនខ្ញុំដែលកើតនោះ ខ្ញុំបានទាន់គ្នាដែលដឹងក្តីដែលវ័យចូលសាលាតាំងពីមេឌីជំនាន់ណាគឺខ្ញុំកើតអត់ទាន់ទេបាទ សូមមេត្តាអត់ទោសបាទ។

**ស៖** មិនអីទេ។ កូនទាំងប្រាំមួយរបស់លោក ដែលកើតនៅចន្លោះឆ្នាំ៧៥ និង៧៧ ប្រពន្ធលោកនុំងគឺ ប៊ូ សំបាន នេះ ខ្ញុំចង់ដឹងថាតើលោកអប់រំកូនទាំងប្រាំមួយរបស់លោកហ្នឹងយ៉ាងម៉េច? លោកអប់រំតាមរបៀបប្រពៃណីខ្មែរ ឬប្រពៃណីវៀតណាម ឬក៏ទាំងពីរច្របល់ចូលគ្នា?

**ឆ៖** ដែលកូននៅឡើយ ដែលបានទៅរៀនសូត្រនោះ ខ្ញុំបំពេញតួនាទីឱ្យចេះអក្សរសាស្ត្រខ្មែរហ្នឹងឱ្យពិតប្រាកដ ដែលឲ្យទៅរៀននុំង ហើយប្រពៃណីដែលត្រូវខាងប្រពន្ធខ្ញុំហ្នឹងឱ្យសែនទៅតាមទំនៀមទម្លាប់របស់គេ។ កុងម៉ាសែនចិនយ៉ាងម៉េច ត្រូវធ្វើតាមដំណើរអឺចឹងទៅ ខ្ញុំបាទក៏បានបញ្ជាក់ជូនតែប៉ុណ្ណឹង ក៏វាបែកគ្នាចូលដល់មកបនប្រល័យពូជសាសន៍ទៅ។

[១៥:៣៨:៣៩]

**ស៖** នៅក្នុងរបបខ្មែរក្រហម តើវប្បធម៌សម្លៀកបំពាក់វៀតណាម ត្រូវបានគេហាមឃាត់ទេ?

**ឆ៖** មិនសូម្បីតែប្រាប់ខាងវប្បធម៌ខាងខ្មែរក្រហមដែលសម្លៀកបំពាក់ទេ ប្រាប់ដល់ខ្មែរយើងសុទ្ធសាធទាំងអស់ថា បើខោ-ស ឬក៏ខោពណ៌ អាវក្រឡាណាមួយ អត់ឱ្យទេ បើ-- ឱ្យជ្រលក់ពាក់ទេ។

ឲ្យពាក់ខ្មៅ សុទ្ធខ្មៅ អត់ឲ្យពាក់តែតារ៉ុងខ្មៅទៀត ឲ្យពាក់ផាឌិបខ្មៅ ឲ្យធុំក្លិនស្អុយ អាហ្នឹងបានន័យថា បក្សទទួលស្គាល់ជាបដិវត្តន៍។

**សៈ** ឥឡូវនេះ ខ្ញុំចូលទៅដល់ហេតុការណ៍រន្ធត់នៅពេលដែលប្រពន្ធរបស់លោក ម្ដាយក្មេករបស់លោក និងកូនរបស់លោកត្រូវបានសម្លាប់ចោល គឺប្រហែលនៅឡូលរកា ឃុំមេលំ។ លោកដឹងទេថា អ្នកណាជាអ្នកសម្លាប់ពួកគាត់ ឬក៏លោកដឹងទេ លោកឃើញទេ?

**ផៈ** ហើយខ្ញុំបាទក៏ជម្រាបជូនដោយស្មោះត្រង់ គឺថាបញ្ហាដែលយកទៅសម្លាប់នោះ ខ្ញុំបាទអត់ដឹងទេ។ ប៉ុន្តែអ្នកនាំធ្វើដំណើរឆ្ពោះពីសហករណ៍ដល់កន្លែងគោលដៅដែលត្រូវសម្លាប់ ហើយខ្ញុំដឹងថានារីហ្នឹងចំនួនអាយុហ្នឹងប្រហែលជា១៨ ហើយនៅកុមារហ្នឹង ខាងប្រុសហ្នឹង មានអាយុប្រហែលជា១៤ ការប៉ាន់ស្មានបាទ។ តែត្រង់ទៅសម្លាប់នោះ គឺខ្ញុំបាទអត់ដឹងទេ។ ទាល់តែព្រឹកឡើងបានកម្មាភិបាលប្រាប់ខ្ញុំថាគេយកទៅសម្លាប់ហើយ ពូកុំសង្ស័យ គិតការងារជូនបក្ស ជូនរដ្ឋទៅ។ យើងពីត្រឹមថ្ងៃហ្នឹងទៅ ខ្វះអីស្រីគរគោក មិត្តយើងគរគោក ស្នើទៅ ដណ្ដឹងទៅ អង្គការរៀបឲ្យ មិនបាច់អស់លុយអស់កាក់ផង។ វាធ្វើនយោបាយដាក់ខ្ញុំ វាត្រូវនឹងអង្គការចាត់តាំង វាត្រូវម៉ាច់បណ្ដោយ។ គេពន្យល់ហេតុថា មិនបាច់គិតគូទេ អាលុយក៏អស់ដែរ ខំតែបំពេញតែការងារទៅ បក្ស និងរដ្ឋទទួលស្គាល់ជាផ្លូវការហើយ។

[១៥:៤១:០៦]

**សៈ** អ្នកទាំងពីរដែលនាំក្រុមរបស់លោកមានចម្រុះជាតិសាសន៍ មានក្មេងអាយុ១៤ឆ្នាំ មានក្មេងប្រុស ក្មេងស្រី។ លោកសំដៅលើកម្មាភិបាល ឬក៏ជាឈ្លប?

**ផៈ** ខ្ញុំដែលខ្ញុំ ខ្ញុំបាទប៉ាន់ស្មានទៅ មិនមែនកម្មាភិបាល ឬក៏មិនមែនឈ្លបទេ។ ខ្ញុំថា ដូចថាកងទ័ពតែម្ដងទៅ ដែលគេចាត់តាំងកងទ័ពណាមួយដែលត្រូវមានឈ្មោះសម្រាប់តែធ្វើឃាតទេ គេហៅឈ្មោះ ដែលទូទៅទាំងអស់ ដែលខ្ញុំចាំឈ្មោះ តែភ្នែកខ្ញុំមិនឃើញទេ ហើយដែលភ្នែកខ្ញុំឃើញ គឺឈ្មោះមិត្តប៊ិន អាហ្នឹងគឺសម្លាប់គ្រប់ហ្នឹង។ តែគេរាយការណ៍ទៅ គេជូនដល់ មិត្តប៊ិន ហើយ។ មិត្តប៊ិន ហ្នឹងសម្រាប់ធ្វើឃាតទូទាំងឃុំ ទូទាំងស្រុកបណ្ដោយ។ ឧបមានារីធ្វើរួមភេទអីជាមួយគ្នា ទាស់ទែងខ្វែងគំនិតអី អាហ្នឹងបញ្ជូនទៅហ្នឹងហើយ អ្នកនិយាយថាអញឆ្លងកាត់ប្រទេស ទៅនៅប្រទេសនោះៗ អាហ្នឹងតែគេបញ្ជូនទៅ មិត្តប៊ិន ដឹងតែស្លាប់ហ្នង។ មិត្តប៊ិន មានរាងទាបកន្ដាល់ មាននីរសារបីនាក់ទៀត ដែលខ្ញុំបានឃើញ មិត្តប៊ិន ហ្នឹង។ ស្រុកកំណើតហ្នឹងនៅ គេហៅថា វត្តកំពង់សាមគ្គី ពីដើមគេហៅថា វត្តរន្ទះបាញ់ ស្រុកកំណើតនៅហ្នឹង ខ្ញុំបានស្គាល់ច្បាស់។ ឲ្យតែឮមិត្តប៊ិន ចម្ងាយ១គីឡូ គឺខ្លាចញ័រសាច់ហ្នង។

**ស៖** បាទ សូមអរគុណ។ ដូច្នេះ មិត្តប៊ិន នេះ គឺជាឃាតករនៅក្នុងតំបន់នោះ អ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំជម្រាបជូនពិតប្រាកដហ្នឹង។

**ស៖** នៅពេលដែលប្រពន្ធ ម្ដាយក្មេក និងកូនរបស់លោកត្រូវបានគេសម្លាប់ជាមួយនឹងជនជាតិវៀតណាមផ្សេងទៀត តើកម្លាំងវៀតណាមមានបានវាយលុកចូលមកកម្ពុជាហើយឬនៅ ពេលនោះ?

[១៥:៤៣:១៥]

**ឆ៖** ខ្ញុំបាទជម្រាបជូន អង្កាល់នៅជំនាន់ហ្នឹងអត់ទាន់មានចូលទេ។ ប៉ុន្តែគ្រាន់តែឮថា ដូចខ្ញុំជម្រាបជូនពីខាងដើមថា "ស៊ីរ៉ូងផ្ទៃក្នុងហើយ" គ្រាន់តែប៉ុណ្ណឹងទេ។ ដល់មួយឆ្នាំ ចូលជិតចុង៧៨ហ្នឹងដាច់ជិតចូល៧៩ ស្រាប់តែឃើញវៀតណាមមកតែម្ដង។ ដល់វៀតណាមមក ខ្ញុំថា អូ្ហ! ប៉ុណ្ណេះប្រពន្ធអញស្លាប់ចោលខ្ញុំហើយ ខ្ញុំបាទគឺបាននៅរស់ហើយ សាងជាតិជាថ្មីហើយ បានវៀតណាមមកជួយរំដោះ អាខ្មែរក្រហមចេញ យើងបានរស់រានមានអាយុ បានបាយ អង្ករបបរអីហូបចុកណែនណាន់ពេញពោះពេញអី ហូរហៀរហើយ។ ហ្នឹងខ្ញុំបាទនឹងច្បាស់អ៊ីចឹង បាទ។

**ស៖** តាមពិតទៅ គឺមានការវាយសម្រុកពីរដង។ ទី១ គឺដើម៧៨ ហើយនិងទី២ គឺការវាយផ្ដួលរលំរបបខ្មែរក្រហម។ ខ្ញុំនិយាយអំពីការវាយប្រហារលើកដំបូងនោះ តើនៅពេលដែលគេសម្លាប់ប្រពន្ធរបស់លោកនោះ គឺនៅពេលដែលមុន ឬក៏ក្រោយពេលវៀតណាមវាយចូល?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញារងអន្តរជាតិបានផ្ដល់សក្ខីកម្មអម្បាញ់មិញជូនទៅដើមបណ្ដឹងរដ្ឋប្បវេណី អំពីការវាយចូលរបស់កងទ័ពវៀតណាម។ ហើយទាក់ទងនេះដែរ នឹងសំណួរចុងក្រោយមួយរបស់លោក ដែលសួរទៅដើមបណ្ដឹងរដ្ឋប្បវេណីថា មានកងទ័ពវៀតណាមវាយចូលហើយឬនៅ? ចំណុចនេះ វាអាចជាការលំបាកសម្រាប់ដើមបណ្ដឹងរដ្ឋ-ប្បវេណីក្នុងការឆ្លើយតបវិញ។ ពីព្រោះថា គាត់ស្ថិតនៅក្នុងទីតាំងមួយដាយឡែក ដែលគាត់មិនអាចដឹងការវាយចូលរបស់កងវៀតណាមនៅទូទាំងប្រទេសកម្ពុជាបានទេ។ បើសិនជាសំណួរនេះ សួរត្រឹមតែបញ្ជាក់ទៅលើទីតាំងជាក់លាក់នៃមូលដ្ឋានដែលគាត់រស់នៅ ប្រហែលជាអាចទទួលយកបាន។

បាទ សូមអរគុណ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

ខ្ញុំនឹងសួរតាមរបៀបផ្សេងលោកប្រធាន។

[១៥:៤៥:៣៩]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** ខ្ញុំនឹងអាននៅចម្លើយរបស់លោកដើមបណ្ដឹងរដ្ឋប្បវេណី គឺឯកសារ E3/4989 ជាភាសាបារាំងគឺ 00891035, ជាភាសាអង់គ្លេស 00891032 និងជាភាសាខ្មែរគឺ 00556217។ នេះជាចម្លើយរបស់លោក លោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំសូមដកស្រង់៖ "ចុងឆ្នាំ៧៧ ដើមឆ្នាំ៧៨ ពួកខ្មែរក្រហមមានគោលការណ៍ស្រាវជ្រាវយកវៀតណាមទៅសម្លាប់។" សូមបញ្ចប់ការដកស្រង់។ និងនៅទំព័របន្ទាប់មកទៀតជាភាសាបារាំង និងជាភាសាអង់គ្លេសគឺ 00891034, ជាភាសាខ្មែរគឺ 00556218 លោកបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ "ខ្ញុំសូមបញ្ជាក់ថា គោលនយោបាយស្វែងរកជនជាតិវៀត-ណាមណាមដើម្បីសម្លាប់ចោលនេះ គឺត្រូវបានអនុវត្តនៅពេលដែលកងទ័ពវៀតណាមឈ្លានពានចូលមកក្នុងទឹកដីកម្ពុជា។" សូមបញ្ចប់ការដកស្រង់។ ដូច្នេះលោកនឹកឃើញឡើងវិញទេ នៅពេលដែលគេសម្លាប់ប្រពន្ធ និងម្ដាយក្មេករបស់លោកនោះ? លោកនឹកឃើញពីកាលៈទេសៈហ្នឹងឡើងវិញទេ?

**លោក ប្រាក់ ឌឿន៖**

**ឆ៖** ខ្ញុំក៏បានឈឺចាប់បាត់បង់ស្មារតីមួយចំនួនដែលខ្ញុំបានគិតគូរ គឺថា បញ្ហាតែពេលខ្ញុំដេកគេងយប់ទៅ ឃើញស្រម័យតែប្រពន្ធកូននៅមុខៗអស់រយៈកាលពីរបីឆ្នាំមុនដែលបានស្លាប់ក្នុងពេលឆាប់មុននោះ។ ខ្ញុំក៏គិតឃើញអារម្មណ៍ហ្នឹងបែងចែកកើតទៅជាមានឈឺ រោគាព្យាធិហ្នឹងប្រចាំកាយហ្នឹងតែម្ដងរហូតទល់ឥឡូវ។ ហ្នឹងសូមមេត្តាប្រធានតុលាការជួយវិនិច្ឆ័យ ហើយជួយដោះស្រាយសំណុំបែបបទហ្នឹង។

[១៥:៤៧:៤៨]

**ប្រធានអង្គជំនុំ៖**

លោកៗចាំស្ដាប់សំណួរ លោកមិនស្ដាប់សំណួរអត់យល់ផង ចាំស្ដាប់សំណួរ បើសិនស្ដាប់មិនយល់ លោកអាចសុំឱ្យម្ចាស់សំណួរហ្នឹងសួរលោកម្ដងទៀត។ លោកចាំស្ដាប់សំណួរ លោកសហព្រះរាជអាជ្ញារងអន្តរជាតិបង្ហាញ សួរសំណួរដែលលោកសួរអំមិញនោះសាជាថ្មីម្ដងទៀតចំពោះដើមបណ្ដឹង

រដ្ឋប្បវេណីរូបនេះ គាត់ស្តាប់សំណួរអំមិញមិនយល់ទេ ស្តាប់មិនបានទេមើលទៅ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** អម្បាញ់មិញនេះ ខ្ញុំបានដកស្រង់នូវចម្លើយរបស់លោក នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក។ លោកបានឆ្លើយថាចុង៧៧ ដើម៧៨ គឺនៅពេលដែលវៀតណាមវាយចូលកម្ពុជានោះ មានគោលការណ៍ស្រាវជ្រាវស្វែងរកចាប់ខ្លួន និងសម្លាប់ជនជាតិវៀតណាម។ ដូច្នេះ ខ្ញុំចង់ដឹងថាលោកនឹកឃើញអំពីរយៈពេលដែលប្រពន្ធ និងម្តាយក្មេករបស់លោកនោះត្រូវបានគេសម្លាប់ទេ?

**លោក ប្រាក់ ឌឿន៖**

**ឆ៖** ថាម៉េចខ្ញុំស្តាប់អត់ទាន់បាន សូមមេត្តាជួយផ្តល់ព័ត៌មានម្តងទៀត។

[១៥:៤៩:២១]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ខ្ញុំមិនមានពេលច្រើនទេលោកប្រធាន។ អ៊ីចឹងខ្ញុំចូលទៅប្រធានផ្សេងតែម្តងទៅ ខ្ញុំមិនចង់សួរដដែលៗទៀតទេ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី លោកបាននិយាយអំពីគោលការណ៍របស់ខ្មែរក្រហមក្នុងការស្រាវជ្រាវស្វែងរកវៀតណាមដើម្បីសម្លាប់ចោល។ អម្បាញ់មិញនេះលោកឆ្លើយមិនសូវច្បាស់សោះ តើលោកស្តាប់ឮដោយផ្ទាល់ត្រចៀកតាមវិទ្យុពាក់ព័ន្ធនឹងគោលការណ៍នេះ ឬក៏លោកស្តាប់ឮពីកម្មាភិបាលខ្មែរក្រហមនិយាយអំពីការស្រាវជ្រាវស្វែងរកវៀតណាមយកទៅសម្លាប់ចោលនេះ?

[១៥:៥0:00]

**ឆ៖** បាទ វាដើរស៊ើសួរខ្ញុំថា ពួងឯងដែលធ្លាប់នៅស្រុកនៅភូមិដែលមកតាមសហករណ៍ តើសេសសល់ហើយនៅ? ហើយៗវាក៏អស់ហើយរលីងនៅ? ខ្ញុំបាទក៏ឆ្លើយតបនឹងមិត្តយើងមួយចំនួនថា ខ្ញុំអត់ឃើញទេ ខ្ញុំអត់ឃើញមានទេ។ ហើយនៅនេះ ពួងឯងមានអ្នកណាលាយសាសន៍ជាតិអីទេ? ថាខ្ញុំអត់ដឹងទេ ហើយខ្ញុំដឹងតែខ្លួនខ្ញុំផ្ទាល់តែម្តង វាសួរខ្ញុំម្តងហើយ ពីរដងទៀតក៏វាឈប់សួរទៅ។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅប្រធានបទចុងក្រោយ ពីព្រោះថាខ្ញុំមានពេលវេលាតិចណាស់។ ខ្ញុំ

និយាយអំពីការរៀបអាពាហ៍ពិពាហ៍។ តើលោកដឹងអ្វីខ្លះអំពីការរៀបចំ ការរៀបអាពាហ៍ពិពាហ៍នៅឆ្នាំ៧៧ និងឆ្នាំ៧៨ ដោយកម្មាភិបាលនៃកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** ខ្ញុំបាទក៏ជម្រាបជូនពេលហ្នឹង វាប្រធានកងកម្មាភិបាលខ្ញុំបញ្ជូនខ្ញុំឱ្យទៅកាប់បង្គោល ធ្វើសសរផ្ទះសព្រែកដើម្បីចាប់ត្រី ហើយខ្ញុំបាទក៏នៅជាមួយចៅហ្វាយស្រុក ហើយកម្មាភិបាលគេថាគណៈស្រុកនៅស្រុក២០ហ្នឹង។ ដល់ខ្ញុំបាទក៏អត់ដឹងខ្លួនដែរ កម្លាំងខ្ញុំបាទទៅកាប់បង្គោលហ្នឹងមានចំនួនប្រហែលប្រាំបីនាក់ ឬក៏ប្រាំពីរនាក់អង្គាល់ហ្នឹង ខ្ញុំក៏ភ្លេចដែរ បើមិនប្រាំពីរ ក៏ប្រាំបីហើយ ហើយគេហៅតែខ្ញុំម្នាក់ទៅ។ គេថាមិត្តអ៊ឹងឯងថ្ងៃនេះ ពេលនេះ ម៉ោងនេះ ត្រូវទៅជួបខ្ញុំនៅសហករណ៍ ហើយខ្ញុំក៏ចាប់អារម្មណ៍ដែរ ខ្ញុំមានការគិតថាអញប្រហែលជាលួចអីគេអី ឬក៏យកអីរបស់គេ ចេះតែភ័យ ហើយមិនដឹងគេៗឱ្យធ្វើអីទៅដឹង ហើយឋានៈគេកម្មាភិបាល ហើយឋានៈគេចៅហ្វាយស្រុកទៀត ហើយខ្ញុំចេះតែមានការអារម្មណ៍បែងចែកទៅ។ ស្រាប់តែដល់ពេលជិតព្រលប់ ខ្ញុំឃើញគេកាត់ចន្ទុះក្នុងរយៈពីរដើមហ្នឹងគេចងជាសសរហ្នឹងបួនៗហ្នឹងគេកាត់ជាបួនកំណាត់ ហើយបួនកំណាត់ហ្នឹង ដូចជាជើងម៉ាគេអង្គុយបង្គួតដូចអង្គុយទៅ អាតុចំកណ្តាលទៅ អាជើងម៉ាសងខាងអ៊ីចេះទៅរាប់តាមគូ។ ហើយខ្ញុំក៏បានគេហៅទៅ ខ្ញុំក៏ទៅមុនដំបូងគេ រៀបចាត់ចែងហ្នឹង ឃើញទំអន្សមជ្រូកហ្នឹងមួយកូនក្រឡោ តែគេឱ្យយើងហូបចុកហ្នឹងតែក្នុងម្នាក់ហ្នឹងតែមួយកង់ទេ គេអត់ឱ្យយើងច្រើនទេ។ ដល់ខ្ញុំមើលទៅ អ៊ូ! នែដល់គេប្រាប់ទៅ តែប្រាប់តាមដូចជាថារៀបមង្គលការប្តីប្រពន្ធនឹងគេអត់ប្រាប់គ្នាទេ អាខ្លះក៏បានដឹង ខ្លះក៏អត់ដឹងដែរ ចាប់ញាត់ដូច -- ការហ្នឹងយើងនិយាយក្រៅ ថាយើងបង្ខំក្នុងពេលរៀបមង្គលការគូស្វាមីភរិយាហ្នឹងឯង។ បានគេលើកខ្ញុំឱ្យធ្វើអត្ថាធិប្បាយបំពេញតួនាទី ដូចយើងថាប្រោះព្រំជាអាចារ្យទៅចុះអង្គាល់នៅជំនាន់ហ្នឹងនោះ ហើយខ្ញុំក៏ព្រួយផង ភ័យផង អរផង ហើយដែលបានទំស៊ីមួយកំណាត់ហ្នឹង។ ហើយគេរៀបមង្គលការហ្នឹង គេដាក់បញ្ញត្តិ គេឱ្យខ្ញុំមានយោបល់មុនគេ ខ្ញុំក៏បានលើកឡើងថា អង្គការដែលបានប្រគល់ភារកិច្ចចាត់តាំងឱ្យគូស្វាមីភរិយាដែលបានរៀបចំចាត់ចែងជាមង្គលការនេះ គឺថាសូមមិត្តយើងទាំងអស់ឱ្យរក្សាទុកនៅបញ្ហាទី១ គឺរក្សាជាសម្ងាហភាពធំ គ្រួសារធំបាទ។ ទី២ គឺគិតគ្រួសារតូច បើយើងបានជាគូស្រករហើយ។ ទី៣ គឺយើងដូចថាអង្គការត្រូវប្រគល់ភារកិច្ចចាត់តាំងជាវិន័យអី គឺត្រូវតែយើងធ្វើ យើងមិនតវ៉ា យើងមិនប្រកែកថាក្តៅរងា ឬក៏ការងារនោះធ្ងន់ស្រាល បាទ។ អាហ្នឹងក៏ខ្ញុំឱ្យយោបល់ទៅ គេក៏ឱ្យហើយកម្មាភិបាលគេមកជំនាន់ក្រោយទៅ ខ្ញុំក៏បានសួរប្អូនមួយដែលៗធ្លាប់លេងសើចហ្នឹង សួរថាប្អូនឯងយប់មិញហ្នឹងប្រោះព្រំយ៉ាងម៉េចទៅ? វាថាពូអត់បានទេពូ ទ័ពវាដើរស្មើនៅក្រោមផ្ទះហ្នឹង វាចាំស្តាប់

ថាយើងយល់ព្រមឬអត់ បើមិនយល់ព្រមវាហៅមកណែនាំមួយលើកហ្នឹងថាបើមិនព្រមទេ វាយកទៅព្រៃហើយ ពាក្យទៅព្រៃមួយម៉ាត់ប្រាកដជាវាសម្លាប់ចោលហើយ។ អ៊ីចឹងមនុស្សណាអត់ស្រឡាញ់យ៉ាងណាក៏ដោយ មិនស្រឡាញ់យ៉ាងណាក៏ដោយ វាត្រូវវាខំឯកភាពដែរ។ អាហ្នឹង សូមមេត្តាអត់ទោសបាទ ខ្ញុំចាំតែប៉ុណ្ណឹងដែលគេហៅខ្ញុំទៅមង្គលការក្នុងសម័យបង្ខំរៀបមង្គលការគូស្វាមីភរិយា ខ្ញុំបាទដឹងរឿងតែប៉ុណ្ណឹងបាទ។

[១៥:៥៤:៤៣]

**ស៖** ក្នុងពិធីរៀបការដែលលោកបានចូលរួមនោះ មានប៉ុន្មានគូដែលគេរៀបការនៅថ្ងៃនោះ? សូមលោកឆ្លើយខ្លីបានហើយ។

**ឆ៖** បាទ ខ្ញុំបាទជម្រាបជូន២៥គូ ដែលខ្ញុំបានរាប់ត្រឹមត្រូវ២៥គូ។

**ស៖** លោកដឹងទេថាក្នុងចំណោមអ្នកទាំង២៥គូហ្នឹង គេជ្រើសរើសប្ដីប្រពន្ធហ្នឹងដោយខ្លួនឯងឬក៏មានអ្នកណាគេអ្នករើសឲ្យ។

**ឆ៖** អានេះគឺខ្ញុំបាទជម្រាបជូន គឺថាស្នើទៅកម្មាភិបាលគ្រប់កង គ្រប់កម្មាភិបាលទាំងអស់ដែលថាត្រូវពេលវេលាហ្នឹង ត្រូវរៀបចំជាគូស្វាមីភរិយាអត់ទេ អត់មានចាំបាច់យើងស្នើ។ អ្នកខ្លះគេមានស្នើខ្លះដែរ ដែលបានប្រាប់ខ្ញុំទៅ អ្នកខ្លះស្នើហើយមិនឲ្យទៀត ចាំអង្គការរៀបឲ្យបណ្ដោយ ចាប់ញាត់ៗបណ្ដោយ។ បានន័យថាត្រង់ហ្នឹងហើយដែលរៀបគូស្វាមីភរិយាដែលត្រូវយើងបង្ខំនោះ។

**ស៖** ក្នុងចំណោមអ្នកទាំង២៥គូនោះ មានអ្នកណាដឹងថានៅថ្ងៃការហ្នឹងខ្លួនត្រូវការជាមួយអ្នកណាៗ ដឹងទេ?

**ឆ៖** បាទ អង្កាល់ហ្នឹងដែលខ្ញុំបានសួរ អត់ដឹងនរណាមួយទេ អត់ដឹងទាល់តែសោះហ្នង។ បាទខ្ញុំសួរពីគូស្វាមីភរិយាដែលគេរៀប ខ្ញុំលួចសួរ ប៉ុន្តែខ្ញុំមិនបានសួរគ្រប់ទាំងអស់ទេ ខ្ញុំសួរតែពីរបីគ្រួសារថាអត់ដឹងទេស្រាប់តែអង្គការស្នើថាឲ្យមកប្រជុំ ក៏មកប្រជុំនឹងគេ ស្រាប់តែមកដល់ ស្រាប់តែឃើញគេឲ្យរៀបចំប្ដីប្រពន្ធតែម្ដង នំមួយក្រឡោហ្នឹងក៏កាត់ចែកគ្នាមួយកង់ៗម្នាក់ទៅ ហើយចន្ទុះបួនដើមបំភ្លឺដូចម៉ាំងសុងពីដើមហ្នឹង ដូចចង្កៀងអគ្គីសនីពីដើមអ៊ីចឹងឯង។

[១៥:៥៦:៤៨]

**ស៖** គូស្វាមីភរិយាដែលត្រូវរៀបការហ្នឹង មានត្រូវប្ដេជ្ញានៅចំពោះមុខអង្គការទេ? ហើយមានអ្នកណាប្រកែកថាពេលហ្នឹងថាមិនព្រមរៀបការទេ?

**ឆ៖** បាទ ខ្ញុំជម្រាបជូនថា ពេលដែលរៀបមង្គលការហ្នឹងគឺថា ក្នុងមួយគូគេឲ្យឡើងចាប់អារម្មណ៍ម្តង ហើយត្រង់ថាប្រកែកថា រៀបយកមិនយក គឺអត់មានប៉ានប្រកែកទេ ថាបើមួយគូឡើងម្តងប្តេជ្ញាថា "សូមស្នើដល់អង្គការដែលបានរៀបចំចាត់ចែងមង្គលការហ្នឹងឲ្យបានជោគជ័យ សូមសរសើរអង្គការ ជួយអង្គការ" ហើយដែលគ្រួសារធំគឺអត់ភ្លេចពីរឿងការងារ គ្រួសារតូចក៏អត់ភ្លេចពីការងារដែរ សមូហភាពក៏អត់មានភ្លេចដែរ អង្គការចាត់តាំងគឺគោរពវិន័យតាមអង្គការចាត់ហ្នឹងដែរ។

**ស៖** ក្រោយពីរៀបការរួច គឺក្រោយពីពិធីប្តេជ្ញាហ្នឹងរួច តើគូស្វាមីភរិយាថ្មីហ្នឹងត្រូវរស់នៅជាមួយគ្នា ហើយត្រូវរួមដំណេកជាមួយគ្នាទេ?

**ឆ៖** ក្នុងពេលយប់ហ្នឹង គឺមានកម្មាភិបាលកងឈ្លបដើរស៊ើបអង្កេត ដែលគេឲ្យតែកន្ទេលមុងខ្នើយទៅតាមគ្រួសារនីមួយៗ មានអ្នកខ្លះចាប់បានខ្លះ ចាប់បានថាមិនព្រមរស់នៅផ្សំដំណេកជាមួយគ្នាដូចជាថាមានការអៀនខ្មាសចំពោះមុខគ្នានឹងគ្នា វាមិនដែលបានស្គាល់សោះ ក៏វាចាប់បានខ្លះ ចាប់បានប្រហែលជាពីរគ្រួសារអី ប្រាំមួយគ្រួសារដែលខ្ញុំបាននៅជិតខាងនៅកាប់សរសរហ្នឹងបានឮ។ តែមួយចំនួនចេះតែទ្រាំទាំងអស់គ្នាទោះបីស្រឡាញ់ក៏ដោយ មិនស្រឡាញ់ក៏ដោយ នៅស្ងៀមទាំងអស់គ្នា អត់មាននិយាយស្តីអីទេ តែរឿងប៉ុណ្ណឹងគឺចប់ហ្នងបាទ។

[១៥:៥៨:៥៥]

**ស៖** អ្នកទាំងពីរគូដែលត្រូវបានគេចាប់ខ្លួននោះគេមានគំរាមកំហែង ឬក៏ដាក់ទណ្ឌកម្មទេ?

**ឆ៖** បាទដែលខ្ញុំបានឮច្បាស់ គឺអត់មានដាក់ទណ្ឌកម្មទេ គឺគ្រាន់តែយកទៅណែនាំជាលើកទី១ដែលអង្គការបានស្រឡាញ់ ហើយនិងជួយសម្រួលដោះស្រាយពីត្រឹមថ្ងៃហ្នឹង យកចិត្តទុកដាក់ជាមួយគ្នាដើម្បីរស់រានមានជីវិតដេកនៅជាមួយគ្នា កុំឲ្យមានពាក្យធំ ពាក្យតូច កុំឲ្យបន្ទោសទៅដល់អង្គការថាអីចេះ ថាអីចុះ តែបន្តិចទៅគេចាប់ខ្លួនហើយ។ អ្នកទាំងពីរនាក់ហ្នឹង ខ្ញុំក៏បានដើរឆ្លាយ ដឹងជាស្លាត់ ដឹងជាបាត់យ៉ាងម៉េច ក៏ខ្ញុំបានលែងទៅកាប់សរសរដែរ ក៏ពាក្យហ្នឹងបញ្ចប់ត្រឹមហ្នឹងទៅ។

**ស៖** ក្នុងពេលរៀបការនោះក្រៅពីលោក មានកម្មាភិបាលខ្មែរក្រហមណាឡើងនិយាយទេ? ហើយបើមាននោះតើគេនិយាយអ្វីខ្លះ? គេមានណែនាំអ្វីដល់គូស្វាមីភរិយាថ្មោងថ្មីហ្នឹងទេ?

**ឆ៖** បាទ អង្កាល់ហ្នឹងដែលខ្ញុំនៅចំនួនប្រហែលមួយម៉ោង វត់ផុតពីខ្ញុំទៅ កម្មាភិបាលហ្នឹងផ្នែកខាងទទួលខុសត្រូវរៀបចំមេគ្រួសារ គេឲ្យយោបល់ដែរ "សូមមិត្តទាំងអស់គ្នា ណ៎ះ! មិត្តខ្ញុំដែលទទួលប្រគល់ភារកិច្ចអង្គការចាត់តាំងមកឲ្យរៀបមង្គលការ តើគូស្វាមីភរិយាហ្នឹងពេញចិត្តនឹងអង្គការឬក៏អត់?"

គេបានថាអ៊ីចឹង។ “បើពេញចិត្តហើយ អង្គការចាត់តាំងទៅកន្លែងណាត្រូវគោរពភារកិច្ច ហើយអ្នកដែលទាំងអស់គ្នាជាគូស្វាមីភរិយាបានទទួលបញ្ជាដែលគេចាត់តាំងដាក់ទិសហ្នឹងឲ្យគ្រប់ៗគ្នា។” ខ្ញុំបាទបានឮតែប៉ុណ្ណឹង ខ្ញុំក៏បានធ្វើដំណើរទៅដេកវិញទៅ។

**ស៖** សំណួរចុងក្រោយ ដើម្បីឲ្យយល់ច្បាស់ លោកបានចូលរួមក្នុងពិធីរៀបអាពាហ៍ពិពាហ៍ក៏ប៉ុន្តែនៅថ្ងៃហ្នឹង គឺលោកមិន -- គេមិនរៀបការលោកទេមែនទេ? អ៊ីចឹងខ្ញុំចង់ដឹងថា លោករៀបការម្តងទៀតហ្នឹងនៅក្នុងរបបខ្មែរក្រហម ឬក្រោយរបបខ្មែរក្រហម?

**ឆ៖** បាទ ដែលខ្ញុំរៀបការហ្នឹង វៀតណាមចូលហើយ ៧៩ហ្នឹង ខ្ញុំរៀបការនៅនឹងខេត្តកំពង់ឆ្នាំងបាទ។ ស្មើទៅតាមប្រពៃណីរបស់ខ្មែរ មានអាចារ្យ ខ្មែរ មានព្រះសង្ឃសូត្រមុនអីបាទ ដូចពីសង្គមដើមឡើយអ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

សវនាការនៅថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ទី០៣ ខែធ្នូ ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ខឿន និងផ្តើមស្តាប់សក្ខីកម្មដែលមានរហស្សនាម 2-TCW-886។ សូមភាគីជ្រាប និង អញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក ប្រាក់ ខឿន ដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ ហើយអង្គជំនុំជម្រះក៏សូមអរ-គុណលោក លឹម ប៊ុនហួរ បុគ្គលិកអង្គការ ធី.ភី.អូ លោកអាចសម្រាកបានហើយ ហើយអង្គជម្រះក៏អញ្ជើញលោកមកបន្តផ្តល់អង្គុយនៅអមដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលផ្តល់សក្ខីម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និង អ្នកជំនាញជូនលោក ប្រាក់ ខឿន វិលត្រឡប់ទៅកន្លែងដែលគាត់ស្នាក់នៅវិញចុះ និងឲ្យអញ្ជើញគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅថ្ងៃស្អែក ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងពីររូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកវិញឲ្យបានម៉ោងប្រាំបួនព្រឹក។ បាទ សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*